









# រាជបណ្ឌិត្យសភាកម្ពុជា

## មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ី

## សិក្ខាសាលាជាតិ ស្តីពី

# «ការវិវត្តនៃរចនាបថ និងសំណង់ស្ថាបត្យកម្មប្រាសាទខ្មែរ ពីសម័យនគរភ្នំដល់សម័យបច្ចុប្បន្ន»

## National Seminar on

# "The Evolution of Khmer Architectural Styles from the Funan Period to the Present"

ថ្ងៃសៅរ៍ ៨កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ២៥៦២

រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨







រៀបចំដោយ៖ មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ឧបត្ថម្ភដោយ៖ មូលនិធិកូរ៉េសម្រាប់ការសិក្សាជាន់ខ្ពស់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជបណ្ឌិត្យសភាកម្ពុជា**
**មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ី**

# សិក្ខាសាលាជាតិ ស្តីពី
# «ការវិវត្តនៃរចនាបថនិងសំណង់ស្ថាបត្យកម្មប្រាសាទខ្មែរ ពីសម័យនគរភ្នំដល់សម័យបច្ចុប្បន្ន»

ថ្ងៃសៅរ៍ ៨កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨
នៅសាលប្រជុំ"នាងនួន" អគារ F នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីព្រាងកម្មវិធី

០៧:៣០-០៨:៣០ : ចុះឈ្មោះអ្នកចូលរួម

០៨:៣០-០៩:០០ : ពិធីបើកអង្គសិក្ខាសាលា ៖
- សុន្ទរកថាស្វាគមន៍ដោយលោក **សាន សុរាវនិត** នាយករងមជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា
- សុន្ទរកថាបើកដោយឯកឧត្តមបណ្ឌិត **យស់ ពៅ** អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

០៩:០០-០៩:១៥ : **សម្រាកនិងពិសាអាហារសម្រន់**

០៩:១៥-១២:៣០ : ដំណើរការសិក្ខាសាលា (បទអន្តរាគមន៍របស់វាគ្មិន)៖
អ្នកសម្របសម្រួល បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** និងសាស្ត្រាចារ្យ **មាឃ សារី**
១. លោក **ហ៊ាង ផេង** និស្សិតបរិញ្ញាបត្រជាន់ខ្ពស់នៃស.ភ.ភ.ព (និងលោកស្រីបណ្ឌិត **ជា វណ្ណី**)
២. លោក **សេង សុវណ្ណដារ៉ា** និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ នៃស.ភ.ភ.ព (និងឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង**)
៣. លោក **អ៊ូ វណ្ណាច័ន្ទបញ្ញា** និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ នៃស.ភ.ភ.ព (និងបណ្ឌិតសភាចារ្យ **សោម សុមុនី**)
៤. សាស្ត្រាចារ្យ **ផល ពុទ្ធិ** សាស្ត្រាចារ្យមហាវិទ្យាល័យសូន្យរូបនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

៥. លោក **ហៀង លាងហុង** ប្រធានផ្នែកវប្បធម៌វិទ្យាវិទ្យាស្ថានវប្បធម៌
និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា

៦. លោក **ភុល សារុ** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ
នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (និងលោកសាស្ត្រាចារ្យ **ឡោ សាន**)

៧. លោកបណ្ឌិត **ធុយ ចាន់ធួន** អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ
នៃរាជបណ្ឌិត្យសភាកម្ពុជា

៨. សាស្ត្រាចារ្យ **ខៀវ កុសល** អនុប្រធានសមាគមអ្នកនិពន្ធខ្មែរ

*(ដំណើរការសិក្ខាសាលា៖ ចាប់ពីម៉ោង៩.១៥នាទី ដល់ម៉ោង១២.៣០នាទី ស្មើនឹង១៩៥នាទី
វាគ្មិនចំនួន៩នាក់ ក្នុងម្នាក់១៥នាទី ស្មើនឹង១៣៥នាទី សំណួរនិងផ្សេងៗ៦០នាទី សរុបរួម១៩៥នាទី)*

**១២:៣០-១២:៤៥** : ពិធីបិទអង្គសិក្ខាសាលា ៖

- របាយការណ៍បូកសរុប ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សោម សុមុនី**
  សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា
- សុន្ទរកថាបិទ ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន**
  នាយកមជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា

**ចប់កម្មវិធី**

*******

*សូមរក្សាសិទ្ធិកែប្រែកម្មវិធីសិក្ខាសាលាក្នុងករណីចាំបាច់ !*

# "រចនាបថសំណង់ស្ថាបត្យកម្មប្រាសាទខ្មែរ នៅសម័យនគរភ្នំ និងចេនឡា"

ដោយលោកស្រីបណ្ឌិត **ជា វណ្ណី** ប្រធានផ្នែកជម្មសាស្ត្រ និងចរិយាសាស្ត្រនៃវ.ម.វ.ស
និងលោក **ហ៊ាង ផេង** និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃស.ភ.ភ.ព.

## សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានវ័យចំណាស់ជាងគេបំផុត នៅលើទឹកដីអាស៊ីអាគ្នេយ៍។ តាមរយៈប្រវត្តិសាស្ត្រ បានបង្ហាញឱ្យមនុស្សជាតិដឹងថា សម័យអង្គរគឺជាសម័យដ៏រុងរឿងបំផុតរបស់ប្រទេសកម្ពុជាដែលមានការរីកចម្រើនគ្រប់វិស័យ ជាពិសេសក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដែលប្រទេសកម្ពុជាឡើងដល់កម្រិតកំពូល ហើយវប្បធម៌-អរិយធម៌ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់ក្រៅប្រទេស ដែលគេកោតសរសើរ ដោយឥតដាច់ពីមាត់។ ប្រាសាទអង្គរវត្ត មិនត្រឹមតែតំណាងឱ្យព្រលឹងជាតិរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជាសម្បត្តិរបស់មនុស្សជាតិផងដែរ។ ជាតិសាសន៍នានាលើពិភពលោក ស្គាល់ប្រទេសកម្ពុជាតាមរយៈប្រាសាទអង្គរវត្តនេះឯង។

យើងបានដឹងហើយថា មុននឹងឈានចូលដល់សម័យអង្គរ ត្រូវឆ្លងកាត់សម័យមុនអង្គរ ជាមុនសិន នោះគឺសម័យនគរភ្នំ និងសម័យចេនឡា។ សម័យកាលទាំងពីរនេះ ក៏បានបន្សល់ទុកនូវវប្បធម៌-អរិយធម៌យ៉ាងច្រើនសន្ធឹកសន្ធាប់ មកដល់កូនចៅជំនាន់ក្រោយដែរ ដែលអាចនិយាយបានថា ជាឫសគល់នៃស្ថាបត្យកម្មនៃសម័យអង្គរហើយមានលកលក្ខណៈសម្បូរបែប មិនចាញ់សម័យអង្គរប៉ុន្មាននោះឡើយ ដែលក្នុងនោះ ក៏យើងសង្កេតឃើញមានប្រាង្គប្រាសាទនានាក៏ដូចជារូបបដិមាផងដែរ។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំលើកយកប្រធានបទ៖" រចនាបថសំណង់ស្ថាបត្យកម្មនិងប្រាសាទខ្មែរនាសម័យនគរភ្នំនិងចេនឡា" នេះមកសិក្សាគឺផ្តោតសំខាន់ទៅលើរចនាបថនៃប្រាសាទ និងរូបបដិមានានាដែលមាននៅក្នុងសម័យកាល គឺសម័យនគរភ្នំ និងសម័យចេនឡាដើម្បីឱ្យដឹងថា តើវាមានលក្ខណៈពិសេសយ៉ាងដូចម្តេចខ្លះ? ជាពិសេស គឺប្រមូលយកមកចងក្រងទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ។

ដោយសារពេលវេលា និងបញ្ហាឯកសារ យើងខ្ញុំមិនបានសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ក៏ប៉ុន្តែយើងខ្ញុំសង្ឃឹមថា ឯកសារមួយនេះ នឹងក្លាយជាទុនតូចមួយសម្រាប់អ្នកសិក្សា អ្នកស្រាវជ្រាវ អ្នកសិល្បៈ ជាពិសេសសម្រាប់ អ្នកសិក្សាវិស័យអក្សរសាស្ត្រ ក៏ដូចជាអ្នក

ប្រវត្តិសាស្ត្រផងដែរ ដើម្បីយកទៅសិក្សាបំពេញបន្ថែម ស្រាវជ្រាវបន្តដើម្បីធ្វើឱ្យស្នាដៃមួយនេះ កាន់តែល្អទ្វេឡើង។

## ១-រចនាបថនៅសម័យនគរភ្នំ( ហ្វូណន )

រចនាបថនៅក្នុងសម័យនគរភ្នំ ស្ថិតនៅក្នុងស.វ.ទី១គ.ស.ដល់ស.វ.ទី៦គ.ស.។ បើតាមការធ្វើកំណាយនៅក្នុងអង្គបុរីនិងនៅកំពង់ផែអូកែវ( កម្ពុជាក្រោម ) សិល្បៈនៅសម័យហ្វូណន ដែលគេដាក់បញ្ចូលក្នុងរចនាបថភ្នំដាគឺយកប្រាសាទភ្នំដាធ្វើជាគោល។ ភ្នំដាស្ថិតក្នុងស្រុកអង្គបុរីក្នុងខេត្តតាកែវ។

ប្រាសាទដំបូងគេ គឺប្រាសាទភ្នំដា ដែលសង់ឡើងតាមរចនាសម្ព័ន្ធប្រាសាទនៅប្រទេសឥណ្ឌា គឺចោះភ្នំធ្វើជាប្រាសាទ ហើយប្រាសាទក្រោយៗទៀត ខ្មែរបុរាណបានធ្វើអំពីដីឥដ្ឋបាយអរមួយបែបដែលផ្សំឡើងដោយកំបោរនិងស្ករមួយចំនួនដែលធ្វើពីថ្មភក់និងខ្លះទៀតធ្វើពីថ្មបាយក្រៀម។ តាមពិតទៅ ប្រាសាទខ្មែរបុរាណទាំងឡាយគឺធ្វើឡើងសម្រាប់ឧទ្ទិសថ្វាយអាទិទេពផ្សេងៗនៅក្នុងសាសនាព្រាហ្មណ៍ខ្លះទៀត ឧទ្ទិសជូនចំពោះពោធិសត្វនៅក្នុងព្រះពុទ្ធសាសនាមហាយាន ខ្លះទៀតសង់ឡើងសម្រាប់ឧទ្ទិសថ្វាយទេវរាជ(តម្កល់លិង្គព្រះឥសូរក្នុងប្រាសាទជាតំណាងឱ្យព្រះរាជា) និងខ្លះទៀតឧទ្ទិសថ្វាយបុព្វបុរសព្រះរាជា មានដូចជា ព្រះបិតា ព្រះមាតា និងវរជនជាដើម ។ ដោយសារតែស្ថាបត្យកម្មប្រាសាទធ្វើឡើងសម្រាប់ឧទ្ទិសបែបនេះហើយ ទើបគេប្រទះឃើញតាមសិលាចារឹកខ្មែរបុរាណសម័យមុនអង្គរក្តី សម័យអង្គរក្តី បានលេចឡើងនូវឈ្មោះប្រាសាទ ឬ បុរីយ៉ាងច្រើនគឺជាពាក្យសំស្ក្រឹតពីព្រោះដើម្បីឱ្យសក្តិសមគឺជាឋានរបស់ព្រះ ឬ អាទិទេព(បានសេចក្តីថា ឋានរបស់ព្រះ ឬអាទិទេពដាច់ខាតត្រូវយកភាសាអាទិទេពមកដាក់ ទើបសម)។ មិនត្រឹមតែប៉ុណ្ណោះ ទៀតសោធ សូម្បីតែបច្ចេកស័ព្ទមួយចំនួនដែលស្ថិតក្នុងវិស័យស្ថាបត្យកម្ម ក៏ត្រូវបានខ្មែរបុរាណយកពាក្យសំស្ក្រឹតសម្រាប់វិស័យប្រើក្នុងវិស័យនេះដែរ ដែលមានជាអាទិ៍៖

-កល្បនា ( ពាក្យសំស្ក្រឹត នៅសិលាចារឹក K34IS,673,A.D,18 ប្រែថា ស្ថាបត្យកម្ម សំណង់ )

-សុប្រតិម្ន ( ពាក្យសំស្ក្រឹត នៅសិលាចារឹក K.1.VIII.A.D,1.5 ប្រែថា ស្ថាបនា កសាង )

-ស្ថាបនា ( ពាក្យសំស្ក្រឹត នៅសិលាចារឹក K.34,674.A.D,1.5 ប្រែថា ស្ថាបនា កសាង សាងសង់ )

ប្រវត្តិទាំងឡាយ ត្រូវបានគេស្គាល់តាមរយៈឯកសាររបស់ចិន ពីព្រោះថា៖ "មានការទាក់ទងប្រទេសខ្មែរ និងប្រទេសចិនតាំងពីមុនគ.ស. អស់រយៈពេលជាច្រើនរយឆ្នាំដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រទុកជាផ្លូវការរាប់ពីស.វ.ទី៣នៃគ.ស.រៀងរហូតមក"។ កាលនោះ ប្រទេសកម្ពុជាយើង មានឈ្មោះថាប្រទេស "នគរភ្នំ"។ ឈ្មោះថានគរភ្នំនេះ ពួកចិនហៅថាហ្វូណន ហើយរាជធានីហៅថាទូមូ ត្រូវនឹងពាក្យខ្មែរបុរាណថាទម្នាក់ = ទ្រមាក់ ដែលប្រែថា អ្នកបាញ់ គឺស្របទៅនឹងសិលាចារឹកជាភាសាខ្មែរថាកុរុងភ្នំ ឬក៏វ្រះវ្នំ ជាសំស្ក្រឹតថាបវត៌ភូបាល ប្រែថាស្តេចភ្នំ រាជធានីថាវ្យាធបុរៈ បុរីអ្នកបាញ់ ជាទីក្រុងតាំងនៅនឹងតំបន់បាភ្នំ ព្រោះទីឋាននោះ មានបុរាណទេវរូបសម័យនគរភ្នំច្រើនណាស់។ ម៉្យាងទៀតកំណាយនៅអង្គបុរីនិងនៅអូរកែវ( កម្ពុជាក្រោម ) បានបង្ហាញសិល្បៈសម័យហ្វូណន ដែលគេរកឃើញនៅអង្គបុរីត្រូវបានចារជាភាសាខ្មែរដំបូង(ភាសាខ្មែរបុរាណអក្សរខ្មែរបុរាណ) ហើយដែលមានកំណត់នូវ

កាលបរិច្ឆេទ៦១១គ.ស. កាន់តែធ្វើឱ្យគេជឿជាក់នៅលើរាល់សំណង់ទាំងឡាយ ដែលមាននៅទីនេះ ហើយអាចធ្វើសន្និដ្ឋាន ពីអាយុនៃសម័យកាលរបស់សំណង់ទាំងនេះបានថែមទៀត។

កំណាយទាំងឡាយ ដែលគេបានធ្វើឡើងនៅអង្គរបុរីនោះ បានបង្ហាញឱ្យគេឃើញថា នៅខាងក្នុងទីក្រុងនេះ មានតួប៉ម"គ្រឹះប្រាសាទ" ធ្វើអំពីឥដ្ឋមិនទាន់ហើយ និងទីលាននានាអំពីឥដ្ឋ សម្រាប់សំណង់ស្រាលៗ។ នៅលើភ្នំដាដែលជាកូនភ្នំតូចមួយនោះ នៅចង្កេះភ្នំ គេសង្កេតឃើញមាន ចោះរូងភ្នំដែលសម្រាប់ធ្វើប្រាសាទ ដែលជាលំនាំតាមបែបឥណ្ឌា ហើយនៅក្បែរជើងភ្នំ មានប្រាសាទមួយដែលចាស់ជាងគេបំផុតនៅក្នុងចំណោមប្រាសាទនានារបស់ខ្មែរគឺអាស្រមមហាឫសី។

តាមការសិក្សា គេអាចសន្និដ្ឋានបានថា ប្រាសាទដែលមាននៅចង្កេះភ្នំដាថាគឺជាស្នាដៃរបស់មនុស្ស ពីព្រោះគេឃើញមាននូវក្បាច់លម្អ តាមដំបូល ដែលក្បាច់ទាំងនោះ មានលក្ខណៈសាមញ្ញ តែវាមានអាយុចំណាស់បំផុតនៅក្នុងប្រវត្តិសិល្បៈខ្មែរយើង។

ចំពោះរូបបដិមានៅក្នុងរចនាបថភ្នំដា គឺសុទ្ធតែមានទម្រ ឬទំនប់មានរាងមាំហើយសមសួនត្រឹមត្រូវតាមខ្នាតទៀតផង។ ជាទូទៅ រូបបដិមាខ្មែរយើងនៅសម័យនោះ មានរាងកាច់ចង្កេះនិងមានសម្លៀកបំពាក់ដូចប្រទេសឥណ្ឌាក៏ប៉ុន្តែ ខ្លះក៏ឈរត្រង់បង្ហាញអំណាច។ យើងអាចបែងចែកបដិមារចនាបថភ្នំដាបានជាក្រុម ដែលក្រុមនីមួយៗ មានលក្ខណៈខុសប្លែកគ្នា។ បដិមារចនាបថភ្នំដា ចែកចេញជាពីរ គឺ បដិមារចនាបថភ្នំដាA និងបដិមារចនាបថភ្នំដាB។

ក្រៅពីស្ថាបត្យកម្មខ្មែរសម័យនគរភ្នំដែលបានទុកស្នាដៃជាច្រើន រួមទាំងរូបដិមាដែលគេបានប្រទះឃើញនៅអង្គរបុរីនិងទីកន្លែងផ្សេងជាច្រើនទៀតនោះ គេក៏ឃើញការធ្វើកំណាយនៅអូកែវ បាននាំឱ្យគេស្គាល់គ្រឿងឧបករណ៍និងគ្រឿងអលង្ការ ដែលខ្មែរសម័យនោះបានប្រើប្រាស់ផងដែរ។

### **១.១- បដិមារចនាបថភ្នំដា** A

បដិមារចនាបថភ្នំដា A បានកសាងឡើងក្នុងឆ្នាំ៥១៤គ.ស ដល់ ៥៣៩គ.ស ក្នុងរជ្ជកាលព្រះបាទរុទ្រវរ្ម័ន។ បដិមាដែលស្ថិតនៅក្នុងរចនាបថភ្នំដាមានដូចជា៖

+ ព្រះគ្រឹស្នៈទ្រភ្នំគោវធ៌ន
+ ព្រះវិស្ណុដៃប្រាំបី
+ ព្រះពលរាម
+ ព្រះបរសុរាម
+ ព្រះពុទ្ធអវលោកិតេស្វរសំរឹទ្ធ
+ ព្រះហរិហរៈ (ប្រាសាទអាស្រមមហាឫសី)

សព្វថ្ងៃ បដិមាទាំងអស់នេះបានយកមកថែរក្សាទុកនិងដាក់តាំងបង្ហាញនៅឯសារមន្ទីរជាតិទីក្រុងភ្នំពេញ។

បដិមារចនាបថភ្នំដាA បានកសាងឡើងពីដីភក់ មានរបៀបតុបតែងលម្អប្រហាក់ប្រហែលគ្នា រង្វង់មុខរាងមូលទ្រវែងវែង ភ្នែកក្រឡោត គ្របកភ្នែករាងកោងស្រួច ចង្ការាងខ្លី ស្លឹកត្រចៀកវែង សក់រួញរមូលដូចគូទខ្យង ពាក់មកុដរាងបំពង់(ចំពោះរូបដិមាព្រះវិស្ណុប៉ុណ្ណោះ) ចង្កេះរាងរៀវ ស្មាបើកធំ

ស្លៀកសំពង់ខ្លី ខ្លះជាសំពត់ចងក្បិនសារបាប់ ចាប់ក្លីចេញពី ប្រភពតែមួយ ក្បាលក្លីរបស់សំពត់មួល ញាត់ចូលក្នុងខ្សែក្រវាត់តូចឆ្មារ មានក្បាលរាងកំប៉ោងបន្តិច ពីខាងមុខ មានជាយផ្នត់ធ្លាក់សំយ៉ុងចុះ។ បដិមាខ្លះ ស្លៀកសំពត់លាត គ្មានចាប់ក្លី រីឯពុទ្ធបដិមាវិញ គ្រងចីវរលាតស្តើងធម្មតា មិនមានប្រើ ចន្ទល់ទប់ដងខ្លួនបដិមាទេ។




ព្រះគ្រឹស្នៈទ្រភ្នំគោវធ៌ន





ចម្លាក់នៅបាតប្រាសាទភ្នំដាព្រះពលរាមរចនាបថភ្នំដា សវទី៥.-៦



ព្រះហរិហរៈរចនាបថភ្នំដា



ព្រះវិស្ណុដៃ៨

## ១.២-បដិមារចនាបថភ្នំដា B

បដិមារចនាបថភ្នំដា B បានកសាងឡើង នៅឆ្នាំ ៥៤០គ.ស ដល់ឆ្នាំ៦០០គ.ស ស្ថិតនៅក្នុង រជ្ជកាលរបស់ព្រះបាទភវវរ្ម័នទី១។ បដិមាសំខាន់ៗមានដូចជា៖

+ ព្រះវិស្ណុ ដែលមានប្រភពពីកំពង់ចាមដាក់តាំងនៅសារមន្ទីរភ្នំពេញ

+ ព្រះហរិហរៈ ដែលមានប្រភពពីអាស្រមមហាឫសី ដាក់តាំងនៅសារមន្ទីរប្រទេសបារាំង

+ វិស្ណុដៃបួន (សារមន្ទីរហ្គីមេ)

រូបបដិមាគឺមានរាងធំ មាឌធំ ឈរទ្រឹងយ៉ាងសង្ហា តែជួនកាលមានរាងកាច់ចង្កេះ។ បដិមាមានលក្ខណៈលម្អនិងសោភ័ណដូចរចនាបថភ្នំដាA តែរាល់គ្រឿងទម្រឬជន្ទល់ត្រូវបានបង្រួមឱ្យមកនៅត្រឹមតែជាអ័ក្សតូចមួយបំណែកឬមួយដំណាក់នៅចន្លោះក្បាលទៅដៃខាងលើ។ ចម្លាក់ គឺធ្វើឡើងពីថ្មភក់។ ឯសម្លៀកបំពាក់វិញ សំពត់របស់ព្រះវិស្ណុថ្នល់ទទឹងថ្ងៃ មានផ្នត់ជាច្រើន និងមានផ្នត់ជាយធ្លាក់ជារាងយុថ្កា ឬកន្ទុយត្រី។ បដិមាផ្សេងទៀត គឺស្លៀកពាក់លាតគ្មានក្លី តែមានផ្នត់ធ្លាក់ជារាងយុថ្កា និងមានផ្នត់មួយជារាង (ហោប៉ៅ?) លេចឡើងពុំសូវច្បាស់។ ការតុបតែងសក់ដូចរចនាបថភ្នំដាA នៅតែបានរក្សាទុក។ មួកឬម្កុដរបស់ព្រះវិស្ណុមានរាងមូល ហើយរីកធំទៅលើបន្តិច បានធ្លាក់គ្របសំយ៉ាករហូតដល់កញ្ចឹងក។

រូបបដិមាដែលប្រហាក់ប្រហែលនឹងរចនាបថភ្នំដា បានកើតឡើងនៅមួយភាគនៃសតវត្សទី៦។ ក៏ប៉ុន្តែស្នាដៃទាំងនោះ ត្រូវបានគេកំណត់នៅក្នុងសតវត្សទី៧។ បដិមាសំខាន់ៗ រួមមាន៖

+ លោកេស្វរៈនៅ Rach Gia

+ សុរិយនៅ តៃនិញ (សារមន្ទីរព្រៃនគរ)

+ ពោធិសត្វនៅអង្គរបុរី (សារមន្ទីរជាតិ)

សរុបសេចក្តីមក គេឃើញថា ប្រាសាទនិងរូបបដិមានៅក្នុងរចនាបថភ្នំដា បានផ្សារភ្ជាប់ទៅនឹងចរន្តវប្បធម៌ប្រទេសឥណ្ឌា។ ចំណែកកំណាយនៅអូរកែវវិញ បានធ្វើឱ្យយើងស្គាល់គ្រឿងឧបករណ៍ គ្រឿងអលង្ការ ដែលគេបានប្រើក្នុងសម័យនោះ។



រចនាបថ ភ្នំដាដងខ្លួន ព្រះវិស្ណុថ្ម
នៅអង្គរបុរី សវទី៤.-៥



ព្រះវិស្ណុដៃបួន

## ១.៣- ប្រាសាទអាស្រម មហាឫសី

ប្រាសាទអាស្រមមហាឫសីសង់នៅលើភ្នំមួយជាប់នឹងភ្នំដា ចំងាយប្រមាណជា៣០០ម៉ែត្រ នៅទិសនីរតីនៃប្រាសាទភ្នំដា។ ប្រាសាទអាស្រមមហាឫសីសាងសង់នៅលើភ្នំដែលមានប្លង់ជាការេ។

ថ្មដែលយកមកទៅសាងសង់ប្រាសាទជាប្រភេទថ្មរឹងមួយប្រភេទហៅថា*ថ្មបាសាល់* ។ គេឃើញមានថ្មនេះនៅខេត្តកំពង់ចាម។ ប្រាសាទនេះ មានទ្វារចូលតែមួយគត់គ្មានទ្វារបញ្ឆោតទេ។ នៅអមសងខាងទ្វារចូល មានសសរពេជ្ររាងមូលលម្អ ដោយក្បាច់រំយោលដែលប្រទាក់គ្នាដូចជាទឹករលក។ ហោជាងគ្មានក្បាច់ចម្លាក់អ្វីទេ វាមានប្រហោងរាងបួនជ្រុងតូចមួយដូចជាប្រហោងខ្យល់នៅចំកណ្ដាល។ តាមជញ្ជាំងពីខាងមុខ និងពីចំហៀងទាំងសងខាង មានបង្អួចចំហ ដែលតុបតែង ដោយក្របពីខាងក្រៅ តែគ្មានចម្រឹងទេ។ ខាងក្នុងប្រាសាទមានបន្ទប់នៅចំកណ្ដាល ហើយមានផ្កាព័ទ្ធជុំវិញខាងក្រៅបន្ទប់។



ការគោរពបូជាមហាឬសី វាល្មិកិសម័យនគរភ្នំ ដើមសវ ទី១.

## ១៤.- ប្រាសាទរូងភ្នំ

ការអនុវត្តនូវប្រព័ន្ធមនោគមវិជ្ជាសាសនាឥណ្ឌា គឺតម្រូវឱ្យមានការសាងសង់ប្រាសាទ ទៅតាមបែបឥណ្ឌា ដែលជាទីគោរពសក្ការៈព្រះអាទិទេព។

ជាទូទៅជនជាតិខ្មែរនៅសម័យបុរេប្រវត្តិ បានទុករូងភ្នំ ឬគុហា ថាជាកន្លែង ដែលមានព្រលឹងដូនតាប្រថាប់ក្រោយពីទទួលអនិច្ចកម្មទៅ។ ក៏ប៉ុន្តែ នៅក្នុងជំនឿសាសនា គេប្រៀបធៀបរូងភ្នំទៅនឹងផ្ទៃរបស់ម្ដាយ ឬទ្វាមាស របស់ស្ត្រី ដែលមិនគ្រាន់តែការពារកូនចៅរបស់ខ្លួន ដែលស្លាប់ ឬ កុំឱ្យគេបំផ្លាញសព ទម្រាំព្រលឹង នឹងទៅចាប់ជាតិថ្មីម្ដងទៀតនៅពេលខាងមុខតែប៉ុណ្ណោះទេ ថែមទាំងជាប្រភពនៃជីវិតទៀតផង។ ដូច្នេះនៅសម័យបុរាណ រូងភ្នំគឺជាកន្លែងអាថ៌កំបាំងស្ងប់ស្ងាត់ គួរឱ្យខ្លាចក្រៃលែង ពីព្រោះវាជាកន្លែងដ៏ពិសិដ្ឋ ដែលមានឫទ្ធិអំណាច ។

តាមការបកស្រាយរបស់ អ្នកបុរាណវិទ្យា បានឱ្យដឹងថា រូងភ្នំ គឺជាប្រាសាទធម្មជាតិមួយយ៉ាងពិតប្រាកដ ក៏ប៉ុន្តែដោយសារតែកន្លែងនេះ ជាកន្លែងដ៏ស្ងប់ស្ងាត់ ក៏ត្រូវបានខ្មែរបុរាណគេនាំគ្នាគោរពធ្វើជាទីសក្ការៈបូជាហាក់បីដូចជាទេវស្ថានឬប្រាសាទដ៏ស័ក្តិសិទ្ធិមួយយ៉ាងពិតប្រាកដ។ នេះបើតាមការបកស្រាយតាមបែបមនុស្សបុរាណដែលជឿលើឥទ្ធិពល ធម្មជាតិទាំងស្រុង ហើយដែលគ្មានការបែងចែកឱ្យដាច់ស្រឡះ អ្វីជាធម្មតា អ្វីជាអច្ឆរិយភាព ហើយអ្វីជាភាពធម្មតា។

យោងតាមការស្រាវជ្រាវផ្នែកបុរាណវិទ្យា យើងអាចដឹងទៀតថា ក្នុងអតីតកាល ប្រាសាទរូងភ្នំទាំងអស់នេះមានប្រជាប្រិយភាពណាស់ ហើយធ្លាប់ទាក់ទាញសាសនិកជន គ្រប់មជ្ឈដ្ឋានវណ្ណៈ ខ្ពស់ទាប ក្នុងព្រះរាជាណាចក្រភ្នំ មកបន់ស្រន់សុំសុខសិរីមង្គល។ គឺក្នុងទិដ្ឋភាពនេះហើយ ដែលគេបានជីករូងភ្នំថ្មីៗថែមទៀតដូចជានៅក្រោមជើងភ្នំជាជាដើម ដើម្បីឆ្លើយតបទៅ នឹងសេចក្តីត្រូវការ របស់មហាជនខ្មែរ ។



ប្រាសាទរូងភ្នំ នៅអង្គរបុរី



ប្រាសាទរូងភ្នំ នៅជើងភ្នំ

## ១.៥- រចនាបថសំណង់ផ្ទះនៅសម័យនគរភ្នំ

ដោយបានការបញ្ជាក់ពីកំណាយស្ថានីយ៍ប្រវត្តិសាស្ត្រនានា គេអាចដឹងថាផ្ទះនាសម័យនគរភ្នំត្រូវបានសាងសង់អំពីឈើ ហើយស្ថិតខ្ពស់ពីដី មានប្រយោជន៍នឹងការពារសត្វសាហាវឬក៏ទឹកជំនន់។ ម៉្យាងទៀតតាមរយៈកំណត់ហេតុរបស់ចិន យើងក៏អាចដឹងដែរថា ផ្ទះនៅសម័យនគរភ្នំដែលស្ថិតនៅជិតមាត់សមុទ្រ គឺប្រក់ស្លឹកចាក ក៏ប៉ុន្តែជាក់ស្តែង ផ្ទះអ្នកមានប្រក់ក្បឿងធ្វើអំពីដីដុត។ កន្លងមកនេះ

យើងបានរកឃើញរូបភាពនៃផ្ទះព្រមទាំងគ្រឿងដីដុតមួយចំនួននៅឯស្ថានីយ៍អង្គរបុរីដែលជាភស្តុតាងនៃផ្ទះសម្បែងនាសម័យកាលខាងលើនេះ។

ប្រការមួយទៀត ដែលគេបានត្រូវកត់ត្រា គឺផ្ទះនាសម័យនគរភ្នំ ត្រូវបានគេតុបតែងដោយក្បាច់ក្បូរយ៉ាងល្អប្រណិត។

មួយវិញទៀត ផ្ទះនីមួយៗមាន របងឈើឡោមព័ទ្ធ ហើយឈើទាំងនោះ គឺត្រូវបានគេកាប់យកចេញពីព្រៃ។ ដូច្នេះហើយ បានជាគេអាចសន្និដ្ឋានថា ដីធ្លីខ្មែរនាសម័យនោះគឺសុទ្ធសឹងតែមានកម្មសិទ្ធិលើកលែងតែដីព្រៃ ហើយសិទ្ធិទៅលើដីធ្លីនេះ ត្រូវបានផ្ទេរទៅគ្រួសារញាតិសន្តានជាបន្តបន្ទាប់គ្នាដោយមិនដាច់ខាត។

## ១.៦- គ្រឿងអលង្ការ ឧបករណ៍ប្រើប្រាស់

គ្រឿងអលង្ការជាច្រើន គេឃើញមានក្រវិលច្រមុះ ក្រវិលត្រចៀក ត្រសាលត្រចៀក បន្តោងកអង្កាំគ្រប់ខ្នាតចិញ្ចៀនដៃនិងជើង។ ចិញ្ចៀនមាសទាំងនោះមានដាំត្បូង ធ្វើអំពីកែវស្ល ឬធ្វើអំពីថ្មដែលមានគោនន្ទិន ព្រះនាងលក្សីជួនកាល គេក៏បានឃើញដែរ នូវរូបទន្សាយ ខ្យងស័ង្ខ ឬផ្កា។

ក្រៅពីវត្ថុខាងលើ គេនៅឃើញមានកាក់មាសមួយចំនួនទៀត ជាភស្តុតាងនៃការជួញប្រែជាមួយប្រទេសជិតខាង ដូចជាប្រទេសចិន ប្រទេសមនជាដើម។ កាក់មាស ខ្លះមានរូបមាន់កំពង់រងាវនៅម្ខាង ហើយម្ខាងទៀត មានរូបព្រះអាទិត្យរះ និងលិច ឬក៏ជារូបសត្វ...។

មាសសន្លឹកស្តើងៗជាច្រើន ត្រូវបានគេរកឃើញ នៅក្រោមខឿនបូជនីយដ្ឋាន។ នៅលើសន្លឹកមាស គេបានឃើញនូវសញ្ញានិមិត្ត ដូចជា ព្រះពុទ្ធអង្គ ព្រះនារាយណ៍ សត្វអណ្តើក ស្លឹកពោធិ រូបហនុមានកាន់ដំបង គោនន្ទិននិងខ្យងស័ង្ខកងចក្រ។

នៅដើមសតវត្សទី១ មានការពិពណ៌នា នៅនគរភ្នំ អំពីការនិយម ស្ពាន់ និងសំណ ដោយអ្នកស្រុកនគរភ្នំ។

នៅកម្ពុជាក្រោម ជាពិសេស នៅម៉ុអូរកែវនិងនៅកោះត្រល់ គេបានឃើញអណ្តូងរ៉ែស្ពាន់ជាច្រើន។ ស្ថានីយបុរេប្រវត្តិមួយចំនួន គេបានឃើញនូវឧបករណ៍ប្រើប្រាស់អំពីស្ពាន់ឬសំរឹទ្ធ ដែលមានអាយុប្រមាណជា១៥០០ឆ្នាំ ទៅ២០០០ឆ្នាំមុនគ.ស។

ចំណែករ៉ែសំណវិញ ដែលគេបាននិយមច្រើនជាងគេបំផុតនាសម័យដើមប្រវត្តិសាស្ត្រខ្មែរ ហើយដែលយើងអាចចាត់ទុកថាៈវប្បធម៌សំណសម័យនគរភ្នំ។ តាមការស្រាវជ្រាវរបស់លោកល្វីអ៊ីម៉ាឡឺរ៉េ នៅក្នុងដែនដីសណ្តកម្ពុជាក្រោម បានឱ្យដឹងថា អណ្តូងរ៉ែជាច្រើន ត្រូវបានគេរកឃើញនៅភូមិភាគកណ្តាលនៃប្រទេសលាវសព្វថ្ងៃ។ វត្តមានរបស់អណ្តូងរ៉ែស្ពាន់ សំណ ព្រមទាំងគ្រឿងអលង្ការជាច្រើនដូចជា ចិញ្ចៀន បន្តោង ខ្សែក រូបបដិមាតំណាងទេវតា ឬក៏កាក់ដែលគេប្រើនៅអូរកែវ អង្គរបុរី និងអ៊ូថង អាចបញ្ជាក់ថា ជាតុរ៉ែខាងលើនេះ ពុំបានដឹកចូលពីប្រទេសក្រៅទេ។[1]

---

[1] ម.ត្រាណេ ប្រវត្តិសាស្ត្រកម្ពុជា(អាណាចក្រភ្នំ) ការផ្សាយពុទ្ធសាសនបណ្ឌិត្យ ២០០២ ទំព័រ៧៣ -៧៤









កែវនៅសម័យអង្គរបុរី



ចម្លាក់សត្វហង្ស

## ២-រចនាបថសម័យចេនឡា

រចនាបថនេះការសាងសង់ប្រាសាទច្រើនមានរាងតូចៗ ធ្វើអំពីឥដ្ឋបូកកំបោរលាយស្ករ រីឯផ្តែ និងជើងទៀនធ្វើអំពីថ្មភក់។ ក្បាច់ផ្តែកណ្តាលមានដងធ្នូ មានក្បាច់ផ្កាចន្ទន៍បីទូររូបមនុស្សគឺនៅកណ្តាល១ និងនៅឆ្វេងស្តាំ២ខាងចុងឆ្វេងស្តាំ មានរូបមករ ហាមាត់ខាំដងធ្នូខាងក្រោម ដងធ្នូខាងក្រោម ដងធ្នូមានក្បាច់រំយោលក្បាច់ កម្រងជាងទងនៅចន្លោះក្បាច់ទាំង២នេះ មានរូបស្លឹកឈើតូចៗផង។ ផ្តែខ្លះមានរូបមនុស្សនៅក្រោមដងធ្នូថែមទៀត។ ជើងទៀនរាងមូលធ្វើពីថ្មភក់។ ហោជាងមានរាងក្រចកសេះ។ ផ្ទៃជញ្ជាំងលម្អ ដោយប្រាសាទតូចៗ។

ផ្នែករូបបដិមា ក្នុងសម័យនោះ គេប្រទះឃើញរូបស្រ្តី មានរាងតូចៗ ត្រគាកធំសាយ ពាក់មកុដរាងមូលភេទប្រុស មានរាងធំមាំ រូបទាំងនេះ មានទ្រនាប់ទម្រ ដូចក្នុងរចនាបថភ្នំដាដែរ។ លក្ខណៈស្ថាបត្យកម្ម ក្នុងរចនាបថនេះប្រហែលគ្នាក្នុងរចនាបថសំបូរដែរ។

ផ្នែករូបដិមានៅក្នុងរចនាបថព្រៃក្មេងនេះ គេឃើញមានបច្ចេកទេសខ្ពង់ខ្ពស់ជាងសម័យមុន ដូចជារូបបដិមាហរិហរៈ(ព្រះឥសូរ)នៅប្រាសាទអណ្តែតគេទុកជាស្នាដៃឯកបំផុតព្រោះមានរាងរៅសមល្អក្រៃលែង។

លក្ខណៈស្ថាបត្យកម្ម ក្នុងរចនាបថនេះ គេឃើញប្លែកត្រង់ មានយឿនច្រើនជាន់ ឬមានរៀបប្រាង្គ ជាថ្នាក់ៗរាងដូចចេតិយមានដូចជា ប្រាសាទអកយំជាគំរូ ឯជើងទៀនខ្លះមានរាង៨ជ្រុងមានក្បាច់ស្លឹកឈើនៅលើជើងទៀនផង។

នៅក្នុងចំណោមរចនាបថទាំង១៣របស់ខ្មែរ គេបានសង្កេតឃើញថានៅក្នុងសម័យចេនឡា មានរចនាបថចំនួន៣បានលេចឡើងគឺ៖[2]

### ២.១-រចនាបថសំបូរព្រៃគុក

រចនាបថនេះត្រូវបានប្រវត្តិសិល្បៈវិទូ បានសិក្សាតាមរយៈព្រះមហាក្សត្រខ្មែរជាច្រើនអង្គ។ តាមសិលាចារឹកK.53 និងសិលាចារឹកដទៃទៀតមានដូចជាK.506 និងK.1150 ធ្វើឲ្យអ្នកសិក្សាបានស្គាល់ពីព្រះនាម ព្រះមហាក្សត្រសំខាន់ៗដូចជា៖

---

[2]http://www.khmercopy.epizy.com.សិល្បៈខ្មែរតាមរចនាបថ

-ព្រះបាទ ភវវរ្ម័នទី១ ប្រហែលជាចៅប្រុសរបស់ព្រះបាទរុទ្រវរ្ម័ន(ចុងស.វ.ទី៦ ឆ្នាំ៥៩៨)

-ព្រះបាទ មហេន្រ្ទវរ្ម័ន ចិត្រសេន ជាអនុជព្រះបាទ ភវវរ្ម័នទី១(រវាងឆ្នាំ ៦០៧ ដល់៦១៦)

-ព្រះបាទ ឥសានវរ្ម័ន ជាបុត្ររបស់ព្រះបាទ មហេន្រ្ទវរ្ម័ន(រវាងឆ្នាំ៦១៦ ដល់៦៣៧)

-ព្រះបាទ ភវវរ្ម័នទី២ ជាបុត្រារបស់ព្រះបាទ ឥសានវរ្ម័ន (រវាងឆ្នាំ៦៣៧ ដល់៦៥៧)

-ព្រះបាទ ជ័យវរ្ម័នទី១ ជាចៅទួតរបស់ព្រះបាទ ឥសានវរ្ម័ន(រវាងឆ្នាំ៦៥៧ ដល់៦៨១)

រចនាបថនេះ គិតចាប់ពីឆ្នាំ ៦១៥គ.ស ដល់ ៦៥០គ.ស ពាក់កណ្តាលទី១នៃស.វទី៧ស្ថិតនៅក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ មានរាជធានី ឥសានបុរៈ គឺសំបូរព្រៃគុកសព្វថ្ងៃ(ស្ថិតនៅចម្ងាយ ៣0Km ខាងជើងជាទីរួមខេត្តកំពង់ធំ)។ គេចែកប្រាសាទទាំងឡាយនៅតំបន់នេះ ជាបីក្រុម គឺ ក្រុមខាងជើង ខាងកណ្តាលនិងខាងត្បូង។ ក្រៅពីនេះ នៅមានប្រាសាទដទៃទៀត ដែលសាងសង់ដាច់ពីគេនៅក្រៅក្រុម។ ប្រាសាទ ដែលគេរាប់បញ្ចូល នៅក្នុងរចនាបថនេះ មានៈ

-ប្រាសាទសំបូរព្រៃគុក

-ប្រាសាទភ្នំធំ

-ប្រាសាទដំបងដែក

-ប្រាសាទគុកព្រះធាតុ

-ប្រាសាទភ្នំបាយ៉ង់ខេត្តតាកែវ

-ប្រាសាទត្នោតជុំ

ក្នុងរចនាបថសំបូរ ប្រាសាទច្រើនសង់មានរាងតូចៗដែលធ្វើពីឥដ្ឋបូកបាយអធ្វើពីកំបោរលាយស្ករដែលឥឡូវនេះរបេះធ្លាក់ស្ទើរអស់ទៅហើយ នៅសល់តែឥដ្ឋទទេ។ ផ្តែរនិងជើងទៀនឬសសរពេជ្រធ្វើអំពីថ្មភក់។ ប្រាសាទទាំងឡាយច្រើន ក៏ប៉ុន្តែ សង់គ្មានរបៀបរៀបរយនោះទេ ត្រង់នេះមួយ ត្រង់នោះមួយ។ ចំណែកឯផ្តែរវិញ នៅផ្នែកចំកណ្តាល មានក្បាច់រាងដងធ្នូជាបន្ទះសំប៉ែត។ លើដងធ្នូមានក្បាច់ផ្កាចន្ទន៍៣ ជារូបមនុស្ស នៅកណ្តាលមួយនិងនៅសងខាងពីរ។ នៅខាងចុងដងធ្នូទាំងសងខាងមានចម្លាក់សត្វមករហាមាត់ពាំដងធ្នូបែរមុខទល់គ្នា ខាងក្រោមដងធ្នូមានក្បាច់រំយោល ក្បាច់កំរងហើយនៅចន្លោះក្បាច់កំរងមានក្បាច់ស្លឹកលាតតូចៗទៀត។ ផ្តែរខ្លះមានរូបមនុស្សនៅខាងក្រោមដងធ្នូ។ ផ្តែរបែបនេះហៅថា ផ្តែររឿង។ ផ្តែរសម័យរចនាបថសំបូរសុទ្ធតែធ្វើជាបែបលំអជាងទងទាំងអស់។ សសរពេជ្រមានរាងមូលធ្វើអំពីថ្មភក់។ រីឯជញ្ជាំងប្រាសាទ គេតែងលំអដោយប្រាសាទតូចៗ ដាក់តំរៀបគ្នាជាជួរពីក្រោមទៅលើ។ នៅលើហោជាង ដែលមានរាងក្រចកសេះ គេពុំឃើញ មានក្បាច់រចនាអ្វីទេ ដោយហេតុតែបាយអដែលបូកលើប្រាសាទនោះ បានរបេះធ្លាក់អស់ទៅហើយ។



ប្រាសាទសំបូរព្រៃគុក



គំរូ និងសសរពេជ្រនៃរចនាបថសំបូរព្រៃគុក



ប្រាសាទភ្នំបាយ៉ង់កោខេត្តតាកែវ



ប្រាសាទគុកព្រះធាតុនៅខេត្តកំពង់ចាម



គំរូផ្តែររចនាបថសំបូរព្រៃគុក



ព្រះនាងទុគ៌ាមកពីប្រាសាទសំបូរព្រៃគុក



គំរូសម្លៀកបំពាក់សម្រាប់ទេវរូបភេទស្រី
នៃរចនាបថសំបូរព្រៃគុក



ព្រះហរិហរៈមកពីប្រាសាទសំបូរព្រៃគុក



ព្រះនាងលក្សីមកពីកោះក្រៀង
ខេត្តក្រចេះនៃសំបូរព្រៃគុក



ផ្តែរក្នុងរចនាបថសំបូរព្រៃគុក( ប្រាសាទភ្នំជើងព្រៃ )



ផ្តែររចនាបថសម្បូរព្រៃគុក ដើមស.វទី៧ វត្តស្លែង (ថត១៩៩៤)

## ២.២- រចនាបថព្រៃក្មេង

រចនាបថព្រៃក្មេង គឺរាប់ចាប់ពីឆ្នាំ៦៣៥គ.ស.ដល់ឆ្នាំ៧០០គ.ស.ពាក់កណ្តាលទី២នៃស.វ.ទី៧។រចនាបថព្រៃក្មេងស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ដែលមានរាជធានីនៅអង្គរបុរី។ ប្រាសាទដែលគេរាប់បញ្ចូលទៅក្នុងរចនាបថព្រៃក្មេងមាន៖

-ប្រាសាទព្រៃក្មេង (នៅស្រុកពួក ខេត្តសៀមរាប)

-ប្រាសាទស្វាយព្រាហ្មណ៍ (ផ្នែកបុរាណ)

-ប្រាសាទបាសិទ្ធ (ទ្វារខាងកើត)

-ប្រាសាទព្រៃប្រាសាទ (ប្រាសាទខាងត្បូងស្ថិតនៅក្បែរថ្មគោលទី៥នៃបារាយណ៍ខាងកើត)

-ប្រាសាទអណ្តែត (ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ)

-ប្រាសាទហាន់ជ័យ (ខេត្តកំពង់ចាម)

ស្ថាបត្យកម្មក្នុងរចនាបថនេះ គឺមានលក្ខណៈ ប្រហាក់ប្រហែល និង ស្ថាបត្យកម្ម នៅក្នុងរចនាបថសម្បូណ៍ដែរ។ ក្បាច់រចនានៅលើផ្តែរច្រើន តែក្បាច់ភ្ញីទេស ពោលគឺក្បាច់ផ្កាចន្ទន៍ ជារូបមនុស្សបានក្លាយទៅជាក្បាច់ផ្កាឈូកបន្ទំ រីឯសត្វមករនៅចុងដងធ្នូ ពុំឃើញមានទៀតទេ គេរចនាជំនួសដោយ ក្បាច់ខ្សងហៀនទៅវិញ។ សសរពេជ្រនៅតែមានរាងមូលជាទម្រង់ស៊ីឡាំងដដែល ហើយកាន់តែមានលំអថែមទៀត។ ជញ្ជាំងក៏នៅតែលំអ ដោយក្បាច់ជារូបប្រាសាទតូចដដែល។ ចំណែករូបដិមាដែលមានរាងកាច់ចង្កេះ បែបឥណ្ឌាពុំសូវមានទៀតទេ។ ក្បាច់លំអក្នុងផ្តែរមានការរីកចម្រើន នូវក្បាច់កម្រងផ្កា ជំនួសឱ្យនូវក្បាច់ផ្ការំយោល ហើយក៏កាន់តែសំបូរដោយក្បាច់ភ្ញីទេស។ ចំពោះសម្លៀកបំពាក់វិញ បដិមាភេទប្រុសមានពីរបែបទី១ គឺជាសំពត់រុំជុំវិញខ្លួនដែលមានជាយសំយាកខាង។ បែបទី២ គឺ

សំពត់ដែលមានផ្នត់វែង ធ្លាក់ចុះមកក្រោម។ ឯបដិមា ភេទស្រី ស្លៀកសំពត់ ខ្ពស់លើចង្កេះ ហើយសំពត់នោះ មានផ្នត់មួយ រាងផ្លែត្រប់ត្រង់ផ្ចិតចំពីមុខ ហើយវា រឹតតៅ ដោយធ្នូតរាងសំប៉ែត។ នៅ

ក្នុងរចនាបថនេះគេបាននាំគ្នា កោតសរសើរ រូបហារិហរៈ ដែលសិល្បករខ្មែរ ចេះផ្សំរូបឥសូរ និងព្រះវិស្ណុ ឱ្យទៅជារូបសំណាកតែមួយ ហើយមានលក្ខណៈសមសួនល្អឥតខ្ចោះទៀតផង។





ផ្តែរ និងសសរពេជ្ររចនាបថព្រៃក្មេង ប្រាសាទអណ្តែត



ប្រាសាទស្រីគ្រប់លក្ខណ៍(ភ្នំប្រសិទ្ធិខេត្តកណ្តាល)



ប្រាសាទវត្តភ្នំហាន់ជ័យនៅកំពង់ចាម





ទីតាំងប្រាសាទនៅខេត្តសៀមរាប តែបាក់បែកអស់ហើយ ព្រះនាងទុគ៌ានៃបដិមាសាស្ត្ររចនាបថព្រៃក្មេង



គំរូសម្លៀកបំពាក់នៃរចនាបថព្រៃក្មេង

## ២.៣- រចនាបថកំពង់ព្រះ

រចនាបថនេះ កសាងឡើងនៅឆ្នាំ៧០៧គ.ស.ដល់ឆ្នាំ៨០០គ.ស. ។ រចនាបថនេះស្ថិតនៅក្នុងសម័យដែលចេនឡាបែកបាក់គ្នាជាពីរ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថកំពង់ព្រះ មាន៖

-ប្រាសាទកំពង់ព្រះ (ខេត្តកំពង់ឆ្នាំង)

-ប្រាសាទអកយំ (ផ្នែកបុរាណ) នៅខេត្តសៀមរាប

-ប្រាសាទត្រពាំងផុង (ផ្នែកបុរាណ) នៅខេត្តសៀមរាប)

-ប្រាសាទភ្នំបាសិទ្ធ (ទ្វារខាងលិច) បាសែត (បាត់ដំបង)

-ប្រាសាទភូមិប្រាសាទ (កំពង់ធំ)។

ប្រាសាទនៅក្នុងរចនាបថកំពង់ព្រះនេះ គឺស្ទើរតែទាំងអស់ទៅហើយ ត្រូវបានគេធ្វើការសាងសង់ ដូចបណ្តាប្រាសាទក្នុងរចនាបថមុនៗដែរ គឺ គេសង់នៅលើខឿនច្រើនជាន់ មានរាងដូចចេតិយ។ សិល្បករខ្មែរយើងនៅសម័យនោះ បានយកក្បាច់ភ្ញីទេសមករចនានៅលើផ្តែរទាំងអស់។ សសរពេជ្រភាគច្រើនគឺនៅមានរាងមូលនៅឡើយ តែគេសង្កេតឃើញមានសសរពេជ្រ៨ជ្រុងខ្លះហើយ ហើយនៅលើសសរពេជ្រនីមួយៗ មានក្បាច់ស្លឹកលាតថែមទៀតផងដែរ។ រូបបដិមាក្នុងរចនាបថមានខ្លះល្អ ខ្លះអាក្រក់។ ប៉ុន្តែ សិល្បៈខ្មែរមានវិវត្តន៍ពិសេសរបស់ខ្លួន គឺត្រង់សិល្បករខ្មែរ បានសាកល្បងបំបាត់ចោលទម្រ និងទំនប់របស់បដិមាខ្លះ។ សម្លៀកបំពាក់ចំពោះរូបបដិមាភេទប្រុស មានសំពត់ពីរបែប។ បែបទី១ គឺមានលក្ខណៈដូចទៅនឹងរចនាបថព្រៃក្មេង ពិសេសរូបដិមា នៅប្រាសាទអណ្តែត។ ឯបែបទី២មានទម្រង់បែបថ្មីគ្មានផ្នត់រាងជាហោប៉ៅទេ គ្រាន់តែជារាងផ្នត់តែប៉ុណ្ណោះ ប៉ុន្តែវាមានផ្នត់រាងជាកន្ទុយត្រីធ្លាក់ចុះសំយ៉ាកនិងមានផ្នត់ទទឹងពោះ។ សម្លៀកបំពាក់បែបទី២ គឺត្រូវបានគេនិយមប្រើនៅសម័យក្រោយៗទៀត (សម័យអង្គរ)។

ឯរូបបដិមាភេទស្រី សំពត់មានលក្ខណៈដូចរចនាបថព្រៃក្មេងដែរ គឺដូចគ្នានឹងបដិមានៅប្រាសាទអណ្តែត។



ប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង



ប្រាសាទអកយំខេត្តសៀមរាប



ផ្តែរ នៃរចនាបថកំពង់ព្រះ



គំរូផ្តែរ នៃរចនាបថកំពង់ព្រះស.វ.ទី៨



ព្រះហរិហរៈនៃរចនាបងកំពង់ព្រះ



គំរូសម្លៀកបំពាក់នៃទេវរូបរចនាបថកំពង់ព្រះ



ប្រាសាទស្រីមើលពីចំហៀង



ប្រាសាទនិងជណ្តើរ



ប្រាសាទប្រុស



ប្រាសាទស្រីគ្រប់លក្ខណ៍ខេត្តកណ្តាល





ប្រាសាទពណ្ណរាយ

# សេចក្ដីសន្និដ្ឋាន

ឆ្លងកាត់តាមការវិភាគខាងលើ ហើយដោយឡែកខ្លឹមសារនៃការសិក្សាស្រាវជ្រាវស្ដីអំពីវប្បធម៌អរិយធម៌ជាពិសេស "រចនាបថសំណង់ស្ថាបត្យកម្ម និងប្រាសាទខ្មែរនាសម័យនគរភ្នំនិងចេនឡា" ដែលបានសិក្សាស្រាវជ្រាវក្នុងស្នាដៃនេះ យើងអាចបញ្ជាក់បន្ថែមទៀតថា អ្វីដែលបានអធិប្បាយពុំទាន់មានលក្ខណៈពេញលេញនៅឡើយទេដោយកង្វះពេលវេលា និងឯកសារ ដែលយើងពុំទាន់មានលទ្ធភាពនឹងប្រមែប្រមូលមកសិក្សាស្រាវជ្រាវ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏ទិន្នន័យដែលបានមកអាចជាមានអត្ថប្រយោជន៍រួមចំណែកជាវិភាគទាន នៅក្នុងការស្វែងយល់អំពីលក្ខណៈដើមនៃខឿនវប្បធម៌អរិយធម៌ខ្មែរ នាសម័យបុរេអង្គរជាពិសេសគឺសម័យនគរភ្នំ ឬហ្វូណនដែលជាប្រភពនៃវប្បធម៌-អរិយធម៌នៅសម័យអង្គរ និងក្រោយអង្គរដែរ។ ម៉្យាងវិញទៀតតាមរយៈការវិភាគរបស់យើង យើងក៏ឃើញនូវភាពចំណាស់របស់វប្បធម៌-អរិយធម៌ខ្មែរ ដែលកើតចេញពីខឿនវប្បធម៌មន-ខ្មែរដែលបានប្រសូត្រចេញពីសម័យបុរេប្រវត្តិសាស្ត្រ គួបផ្សំទៅនឹងវប្បធម៌ឥណ្ឌា ដែលបានហូរចូលចក្រភពនគរភ្នំ មុនការបង្កើតរដ្ឋមន ដែលមានឈ្មោះថាទ្វារវតីនៅក្នុងសតវត្សទី៧នៃគ.ស. រដ្ឋថៃនិងលាវ(ឡាវ)នាសតវត្សទី១៣-១៤នៃគ.ស. និងប្រទេសវៀតណាមខាងត្បូងពីដើមសតវត្សទី១៧ដល់សតវត្សទី២០នៃគ.ស នៅលើទឹកដីខ្មែរកម្ពុជាក្រោម។

លក្ខណៈសម្បត្តិមួយទៀតនៃការស្រាវជ្រាវរបស់យើង គឺការធ្វើឱ្យអត្តសញ្ញាណជាតិខ្មែរលេចធ្លោឡើងដោយបង្ហាញបញ្ជាក់យ៉ាងត្រឹមត្រូវថា គឺជនជាតិខ្មែរនេះឯង ដែលបានចូលរួមវិភាគទានយ៉ាងសកម្មក្នុងការស្ថាបនាខឿនវប្បធម៌-អរិយធម៌របស់ជនជាតិថៃ និងលាវ ដែលជាមនុស្សចំណូលថ្មី ក្នុងអតីតទឹកដីរបស់ជនជាតិខ្មែរ ដែលស្ថិតនៅក្នុងអម្បូរមន-ខ្មែរ រស់នៅមានលក្ខណៈជាកុលសម្ព័ន្ធនៅលើទឹកដីរបស់ខ្លួនហើយ ដែលនៅបានរក្សានៅឡើយនូវលក្ខណៈវប្បធម៌ដើមរបស់ខ្លួន ពោលគឺពុំបានទទួលនូវឥទ្ធិពលបរទេស ដែលជាកត្តាញ៉ាំងឱ្យមានការលេចធ្លោឡើងនូវរដ្ឋដំបូងនោះ គឺរដ្ឋនគរភ្នំ ឬក៏ហ្វូណននេះឯង។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ការសិក្សាស្រាវជ្រាវដ៏តូចមួយនេះ គឺពិតជានៅមានចំណុចខ្វះចន្លោះ លើសលោះ ដែលមិនអាចគេចផុតបាន។ យើងខ្ញុំសង្ឃឹមថា អ្នកសិក្សាស្រាវជ្រាវគ្រប់ជំនាន់ជួយកែកែសម្រួលស្ថាបនានិងបន្តការសិក្សាស្រាវជ្រាវបន្ថែម ឱ្យកាន់តែមានភាពសុក្រឹតនៅក្នុងពេលអនាគត ក្នុងន័យរួមចំណែកលើកស្ទួយខឿនវប្បធម៌អរិយធម៌នៃជនជាតិខ្មែរឱ្យគង់វង្ស និងមានភាពរុងរឿងជាអមតៈ។

# "ការវិវត្តនៃរចនាបថស្ថាបត្យកម្ម និងសំណង់ប្រាសាទខ្មែរសម័យអង្គរ"

ដោយឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង** អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ
និងលោក **សេខ សុវណ្ណដារ៉ា** និស្សិតបរិញ្ញាបត្រជាន់ខ្ពស់នៃស.ភ.ភ.ព.

## ១.សេចក្តីផ្តើម

អំឡុងសតវត្សរ៍ទី៩ នៅក្នុងពេលដែលអឺរ៉ុបកំពុងឆ្លងកាត់នូវយុគខ្មៅងងឹត ក្រោយការដួលរលំនៃចក្រភពរ៉ូម ហើយចក្រភពអារ៉ាប់កំពុងស្គាល់ភាពរុងរឿង វាតទីកាន់កាប់ទឹកដីនៅប៉ែកខាងត្បូង និងខាងកើត នៃតំបន់មេឌីទែរ៉ាណេ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ឯណោះវិញ អាណាចក្រមួយក៏កំពុងតែងើបឡើង និងស្គាល់ភាពរុងរឿងខ្លាំងដែរ នោះគឺ អាណាចក្រខ្មែរ។ ប្រវត្តិសាស្ត្របានបង្ហាញអោយឃើញថា សិល្បៈខាងសំណង់របស់ខ្មែរ គឺមានកំណើតឡើងតាំងពីសម័យហ្វូណនមកម្ល៉េះ។ ស្នាដៃសិល្បៈនៃសំណង់ទាំងនេះ ចេះតែវិវត្តជាបន្តបន្ទាប់រហូតដល់ចុងសម័យអង្គរ "សម័យបាយ័ន"។ ដើម្បីងាយស្រួលដល់ការសិក្សា អ្នកបុរាណវិទូ បានធ្វើការបែងចែកនូវស្នាដៃនៃសិល្បៈខ្មែរជា ១៤រចនាបថខុសៗគ្នាគឺៈ គេសង្កេតឃើញមានការសាងសង់ប្រាសាទភ្នំដើម្បីដំកល់សិវលិង្គ ដែលបង្ហាញអោយឃើញថា ប្រជារាស្ត្រខ្មែរគឺធ្វើការគោរពតាមនិកាយព្រះសិវៈជាធំ។ នៅស.វ.ទី១២ ក្នុងរាជ្យព្រះសូរ្យវរ្ម័នទី២ សាសនាព្រាហ្មណ៍មានការប្រែប្រួលបន្តិច ដោយគេឃើញមានការគោរពព្រះវិស្ណុជាធំវិញ។ ជាក់ស្តែងនៅតាមជញ្ជាំងជុំវិញប្រាសាទអង្គរវត្ត យើងឃើញមានរឿងរ៉ាវផ្សេងៗដែលមានការទាក់ទងដល់អវតារព្រះវិស្ណុ ដូចជារឿងរាមាយណៈ ជាមហាភារតៈជាដើម។ ទោះជាក្នុងពេលនោះសាសនាព្រាហ្មណ៍ ត្រូវបានព្រះមហាក្សត្រភាគច្រើនយកចិត្តទុកដាក់គោរពយ៉ាងខ្ជាប់ខ្ជួន ក៏ពុទ្ធសាសនានៅតែទទួលការអនុគ្រោះផងដែរ រហូតដល់មានព្រះមហាក្សត្រខ្លះគោរពពុទ្ធសាសនាទៀតផង ពិសេសនៅចុងស.វ.ទី១២។ មកដល់ដើមស.វ.ទី១៣ ពុទ្ធសាសនាមានការលូតលាស់ឡើងវិញ ឯសាសនាព្រាហ្មណ៍ត្រូវចុះឥទ្ធិពល ជាក់ស្តែងព្រះបាទជ័យវរ្ម័នទី៧ និងអគ្គមហេសី គឺជាពុទ្ធសាសនិកជន ដ៏ឆ្នើមបំផុតនាសម័យកាលនោះ។ ក្រោយព្រះបាទជ័យវរ្ម័នទី៧ ទ្រង់សោយទីវង្គតទៅ ស្តេចសោយទីវង្គតទៅ ស្តេចសោយរាជ្យបន្ត បានវិលមកគោរពព្រាហ្មណ៍សាសនាវិញ ដែលជាហេតុនាំអោយមានប្រតិកម្មសាសនាកើតឡើង។ ជាក់ស្តែងគឺនៅចុងស.វ.ទី១៣ ព្រះពុទ្ធសាសនាមហាយានត្រូវបានសាបរលាបស្ទើរសូន្យ។ ចំណែកឯសាសនាព្រាហ្មណ៍វិញ ក៏បាត់បង់ស្ទើរតែទាំងស្រុងផងដែរនៅស.វ.ទី១៤។ ពេលនោះ ពុទ្ធសាសនានិកាយថេរវាទ ក៏បានលេចមុខឡើងវិញ និងមានឥទ្ធិពលទន្ទឹមគ្នា។ ហើយរីកចំរើន និងថយចុះដោយផ្លាស់វេនគ្នា។ នេះមានន័យថា ទោះបីសាសនាណាមួយមានឥទ្ធិពលជាងក្តី ក៏សាសនាមួយ

ទៀតនៅតែរក្សាបាននូវអត្តិភាពរបស់ខ្លួនផងដែរ។ ម្យ៉ាងទៀត គួរកត់សំគាល់ផងដែរ រហូតដល់សព្វថ្ងៃនេះ ទោះបីព្រាហ្មណ៍សាសនា ត្រូវលោយសាបសូន្យទៅហើយក្តី ក៏នៅក្នុងសន្តានចិត្តខ្មែរទោះតិច ឬច្រើនក៏នៅតែទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍នៅឡើយដែរ ។

ក្នុងរយៈពេលប្រមាណជាជាង ៦០០ឆ្នាំ ចាប់តាំងពីដើមសតវត្សរ៍ទី៩ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១៥ អាណាចក្រខ្មែរបានស្គាល់នូវភាពរុងរឿង ក្នុងឋានៈជាមហាអំណាច នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងអំឡុងពេលនោះ អាណាចក្រខ្មែរបានគ្រប់គ្រងទឹកដីដ៏ធំ ដែលគ្របដណ្តប់លើទឹកដីកម្ពុជា ថៃ ឡាវ និងប៉ែកខាងត្បូងប្រទេសវៀតណាមបច្ចុប្បន្ន។ ព្រំដែននៃអាណាចក្រខ្មែរលាតសន្ធឹងរហូតទៅដល់ប្រទេសចិន នៅប៉ែកខាងជើង ភូមា នៅប៉ែកខាងលិច ម៉ាឡេស៊ី នៅប៉ែកខាងត្បូង និងនគរចម្ប៉ា នៅខាងកើត។

នៅក្នុងកំណត់ត្រារបស់ពួកអារ៉ាប់ នៅចន្លោះពីសតវត្សរ៍ទី៩ និងសតវត្សរ៍ទី១០ គេឃើញថា កាលណានិយាយពីតំបន់អឺរ៉ុប ពួកអារ៉ាប់តែងតែលើកឡើងពីការធ្លាក់ដុនដាបក្នុងយុគខ្មៅងងឹត ក៏ប៉ុន្តែពួកអារ៉ាប់បានចាត់ទុកតំបន់អាស៊ីអាគ្នេយ៍ថា ស្ថិតក្នុងតំបន់ដែលមានភាពរុងរឿងបំផុតនៅលើពិភពលោក នៅក្នុងអំឡុងពេលនោះ។

ក៏ប៉ុន្តែ ជម្លោះផ្ទៃក្នុង ជាពិសេស ជម្លោះដណ្តើមរាជ្យបល្ល័ង្ក បូករួមជាមួយនឹងការឈ្លានពានពីប្រទេសជិតខាងបានធ្វើឲ្យអាណាចក្រខ្មែរត្រូវធ្លាក់ចុះខ្សោយជាបន្តបន្ទាប់ ហើយទឹកដីកាន់តែរួញតូច។

ជាទូទៅ អ្នកប្រវត្តិសាស្ត្របានកំណត់ថា សម័យកាលរុងរឿងនៃអាណាចក្រខ្មែរបានចាប់ផ្តើមពីឆ្នាំ៨០២ ជាមួយនឹងការឡើងគ្រងរាជ្យនៃព្រះបាទជ័យវរ្ម័នទី២ និងបញ្ចប់នៅត្រឹមឆ្នាំ១៤៣១ នៅពេលដែលព្រះបាទស្រីសុរិយោពណ៌ (ឬចៅពញាយ៉ាត) សម្រេចចិត្តបោះបង់រាជធានីអង្គរចោល ហើយទៅតាំងរាជធានីនៅស្រីសន្ធរ និងបន្ទាប់មកនៅភ្នំពេញវិញ ដើម្បីគេចចេញពីការឈ្លានពានរបស់កងទ័ពសៀម។

សន្តតិវង្សព្រះរាជាខ្មែរសម័យអង្គរទាំង២៧អង្គ ពីឆ្នាំ៨០២ ដល់ឆ្នាំ១៣៣៩ ដោយចាប់គិតពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៣៤) រហូតដល់ព្រះបាទជ័យវរ្ម័នទី៩ (១៣២៧-១៣៣៩)។

នៅសម័យអង្គរ ខ្មែរមានឈ្មោះថាជាមហាអំណាចមួយនៅអាស៊ីអាគ្នេយ៍។ ដូច្នេះហើយអរិយធម៌ខ្មែរបានឡើងដល់កំរិតកំពូលនៅសតវត្សទី៩ដល់ទី១៣។ ភាពរុងរឿងនេះគេអាចសំគាល់ដោយផ្ទៃដីធំទូលាយ លាតសន្ធឹងសឹងតែអស់ផ្ទៃដីឥណ្ឌូចិនទាំងមូល ដោយប្រាសាទសិលាមានចំនួនច្រើនរាប់ពាន់ ប្រកបដោយក្បាច់រចនាគួរអោយកោតស្ញប់ស្ញែងដោយផ្ទាំងសិលាចារឹក ច្រើនសន្ធឹកសន្ធាប់មានទាំងភាសាសំស្ក្រឹត និងខ្មែរបុរាណ ឬជួនកាលមានភាសាទាំងពីរលាយចំរុះគ្នាដោយរូបបដិមាគ្រប់ប្រភេទ និងបុរាណវត្ថុផ្សេងៗទៀតនិងជាពិសេសដោយបរិក្ខារ សង្ខរណ ដែលមានសេសសល់រហូតមកដល់សព្វថ្ងៃដូចជា បារាយ ទំនប់ទឹក បណ្តាញជលគតិ ផ្លូវថ្នល់ ស្ពាន។ល។ ប៉ុន្តែចាប់ពីពាក់

កណ្តាលទី១នៃស.វ.ទី១៣ ទៅការចុះដុនដាបក៏ចាប់មានបន្តិចម្តងៗ រហូតដល់ត្រូវបោះបង់រាជធានីអង្គរចោលនៅសតវត្សទី១៥ដោយព្រះបាទចៅពញាយ៉ាត។

## ២.ការវិវត្តនៃរចនាបថស្ថាបត្យកម្ម និងសំណង់ប្រាសាទបុរាណខ្មែរនាសម័យអង្គរ

ស្ថាបត្យកម្ម និងសំណង់ប្រាសាទបុរាណខ្មែរសម័យអង្គរ មានប្រាសាទពីរបែបៈ

១.ប្រាសាទភ្នំជាប្រាសាទសង់លើឃឿនច្រើនជាន់សម្រាប់លទ្ធិទេវរាជ (បាគង បាខែង បក្សីចាំក្រុង ប្រាសាទធំ មេបុណ្យខាងកើតប្រែរូប តាកែវ បាពួន អង្គរវត្ត បាយ័ន)។

២.ប្រាសាទសង់ទាបនឹងដីជាប្រាសាទសម្រាប់លទ្ធិបុគ្គលនិយម (ព្រះគោ លលៃ បន្ទាយឆ្មារ ព្រះខាន់ តាព្រហ្ម។ល។)។ ម្យ៉ាងទៀត គេបានសង្កេតឃើញថាពីរាជ្យមួយទៅរាជ្យមួយទៀតប្រាសាទមានទំហំកាន់តែធំឡើង ហើយកាន់តែច្រើនឡើង។ ត្រង់នេះបង្ហាញអោយឃើញថា ព្រះរាជាអង្គរហាក់ដូចជាបានប្រណាំងប្រជែងក្នុងការលើកកិត្យានុភាពរបស់ព្រះអង្គ។ ចំពោះប្រាសាទដូចបាន រៀបរាប់រួចមកហើយនេះ ពុំមែនមានត្រឹមតែការកសាងហើយចប់នោះទេ គឺប្រជារាស្ត្រមានការផ្គត់ផ្គង់នូវគ្រឿងប្រដាប់ប្រើប្រាស់ និងជង្វាយផ្សេងៗនិងមានភារៈត្រូវទៅនៅបម្រើនិងថែរក្សាប្រាសាទទាំងនោះថែមទៀត។

ឧទាហរណ៍: ដូចជាប្រាសាទតាព្រហ្ម កសាងឡើងនៅឆ្នាំ១១៨៦ ដោយព្រះបាទជ័យវរ្ម័នទី៧ សម្រាប់ឧទ្ទិសចំពោះវិញ្ញាណក្ខន្ធនៃព្រះមាតា និងព្រះគ្រូនិងបដិមារូបឯទៀត ចំនួន២៦០ មានភូមិចំណុះ៣១៤០ភូមិ (សម្រាប់ផ្គត់ផ្គង់ប្រដាប់ប្រើប្រាស់ និងជង្វាយផ្សេងៗ) មានមនុស្សនៅចាំបម្រើថែរក្សា ៧៩៣៦៥នាក់ (ក្នុងចំណោមនេះមាន១២៦៤០នាក់ ស្ថិតនៅក្នុងបរិវេណប្រាសាទជានិច្ច)។ គ្រឿងប្រដាប់ប្រើប្រាស់ជាជង្វាយមានៈ ចានមាសទម្ងន់ជាង៥តោន ចានប្រាក់មួយទម្ងន់ដូចគ្នា ពេជ្រទាំងគ្រាប់ធំ ៣៥គ្រាប់ ត្បូងមុក្តា៤០៦២០គ្រាប់ ត្បូងយ៉ាងល្អ ៤៥៤០គ្រាប់ ផ្តិលមាសធំមួយ រនាំងស្រុកចិន៩៦៧ គ្រែធ្វើដោយសំពត់ល្អ ៥១២ ក្លស់៥២៣។ ចំពោះស្បៀងអាហារមានៈ អង្ករ ស្ករ ទឹកដោះគោ ប្រេង ទឹកឃ្មុំ ក្រមួន ខ្លឹមចន្ទន៍ កប៉ូរ គ្រឿងចីវរ។ នេះចំពោះប្រាសាទតែមួយផង ឃើញថាការប្រើប្រាស់កម្លាំងមនុស្ស និងទ្រព្យសម្បត្តិអស់យ៉ាងសន្ធឹកសន្ធាប់ទៅហើយ ចុះបើខ្មែរយើងមានប្រាសាទដល់ទៅរាប់ពាន់ តើតម្រូវការទាំងខាងកម្លាំងមនុស្សទាំងខាងទ្រព្យសម្បត្តិមានដល់ប៉ុន្មាន? ចំពោះបញ្ហានេះ ប្រវត្តិវិទូជាច្រើនបានចាត់ទុកថា ការកសាងប្រាសាទរួមនិងចម្បាំងដ៏វែងឆ្ងាយ (សូរ្យវរ្ម័នទី២វាយយួនផង ចាមផង មនផង) ជាកត្តាមួយនៃការធ្លាក់ចុះនៃអរិយធម៌អង្គរនេះឯង។

ការវិវត្តនៃរចនាបថស្ថាបត្យកម្មសំណង់ និងប្រាសាទបុរាណខ្មែរសម័យអង្គរ ត្រូវបានចែកចេញជា១០រចនាបថគឺៈ

**១-រចនាបថគូលែន** (**គ.ស.៨០២ ដល់ ៨៥០ ពាក់កណ្តាលទី១នៃស.វ.ទី៩**)

សិល្បៈក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ (គ.ស.៨០២-៨៥០) តាមអ្នកស្រាវជ្រាវប្រវត្តិសិល្បៈខ្មែរចាត់ទុកបដិមាសាស្ត្រ និងប្រាសាទក្នុងរាជ្យស្តេចអង្គនេះ ថាជាសិល្បៈ «រចនាបថគូលែន»។

ប្រាសាទគំរូសំខាន់ៗដែលទំនងជាសាងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ ឬក្នុងរចនាបថគូលែនមានដូចជា៖

-ក្រុមប្រាសាទនៅលើភ្នំគូលែន : ប្រាសាទនៅលើភ្នំគូលែនសរុបទាំងអស់មាន ៥៣ប្រាសាទ ដែលក្នុងនោះមានដូចជា ប្រាសាតដំរីក្រាប អូរផ្អុង ខ្ទីងស្លាប់ រូអារក្ស អ្នកតា អូរថ្មដាប់ អារាមរោងចិន ប្រាសាទក្រហម គគី ប៉មខាងជើងនៃប្រាសាទព្រៃប្រាសាទ។ល។

-ប្រាសាទតោ C1 នៅសម្បូណ៌ព្រៃគុក

+ប្លង់ប្រាសាទ: ប្រាសាទខ្លះមានរាងប៉មតូចតែឯង ឯប្រាសាទខ្លះទៀតសង់ជាជួរលើខឿនតែមួយ។



ប្រាសាទដំរីក្រាប

**២-រចនាបថព្រះគោ** (**គ.ស.៨៧៧-៨៨៩ ភាគ៤នៃចុងស.វ.ទី៩**)

រចនាបថព្រះគោនេះស្ថិតនៅក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១ (៨៧៧-៨៨៩) និងព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩០០) ដែលដំបូងបានគង់នៅក្នុងរាជធានីហរិហរាល័យដែរ គឺនៅរលួស ខេត្តសៀមរាប។

គេនៅតែកសាងប្រាសាទអំពីឥដ្ឋ បូកបាយអដដែល ប៉ុន្តែកសាងប្រាង្គជាច្រើននៅលើខឿនតែមួយ (ព្រះគោ និងលលៃ) ដើម្បីឧទ្ទិសចំពោះបុព្វជន មានព្រះមាតាបិតាជាដើម។ ម្យ៉ាងទៀត មានការ

សាកល្បងកសាងប្រាសាទតូចៗអំពីថ្មភក់ចំនួន១២នៅលើជាន់ទី៤ នៃប្រាសាទបាគង។ សិល្បៈក្នុងសម័យនេះមាន លក្ខណៈជាសិល្បៈខ្មែរសុទ្ធសាធ ដែលមានការវិវត្តក្នុងសម័យក្រោយៗទៀត។

ប្រាសាទសំខាន់ៗក្នុងរចនាបថព្រះគោមានៈ

-ប្រាសាទព្រះគោ (គ.ស.៨៧៩) កសាងក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១

-ប្រាសាទបាគង (គ.ស.៨៨១) កសាងក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១

-ប្រាសាទលលៃ (គ.ស.៨៩៣) កសាងក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១



ប្រាសាទព្រះគោ



ប្រាសាទលលៃ



ប្រាសាទបាគង

**៣-រចនាបថបាខែង** (**ចុងនៃ ស.វទី៩ និងដើម ស.វ ទី ១០**)

រចនាបថបាក់ខែងស្ថិតនៅក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ (គ.ស ៨៨៩-៩០០) ដែលមានរាជធានីនៅយសោធបុរៈ (ភ្នំបាក់ខែង)។

ប្រាសាទភ្នំបាខែងជាប្រាសាទមួយស្ថិតនៅលើភ្នំធម្មជាតិ ដែលគេចាត់ទុកជា ប្រាសាទភ្នំមានតួប៉មប្រាំខ្វែងគ្នា និងមានប្រាំថ្នាក់។ ប្រាសាទនេះស្ថិតនៅខាងឆ្វេងដៃផ្លូវពីអង្គរវត្តទៅអង្គរធំ ជាកន្លែងដែលអាចទាក់ទាញភ្ញៀវទេសចរបានយ៉ាងច្រើននៅពេលថ្ងៃលិច។ ប្រាសាទនេះកសាងឡើងនៅចុងសតវត្សរ៍ទី៩ និងដើមសតវត្សរ៍ទី១០ នៅរាជព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩១០) ដែលគោរពព្រហ្មញ្ញសាសនា។

ភ្នំបាខែងមានកំពស់៦៥ម។ ប្រាសាទភ្នំបាខែងមានកំពូល១០៩ និងមានកំពស់៤៥ម។ ប្រាសាទនេះតំណាងឱ្យភ្នំព្រះសុមេរុ។ ប្រាសាទនេះមាន៧ជាន់ គឺជាន់ក្រោម ថ្នាក់ទាំងប្រាំ និងជាន់លើ ដែលតំណាងឱ្យឋានសួគ៌៧ជាន់របស់ព្រះឥន្ទនៅក្នុងទេវកថារបស់ព្រហ្មញ្ញសាសនា។

ប្រាសាទនេះពិតជាមានលក្ខណៈពិសេស ដោយសារតែប្រាង្គទាំង១០៨មានលក្ខណៈតម្រៀបស្មើៗគ្នាគឺ១២ ប្រាង្គធំកណ្តាលមួយនៅជាន់ខាងលើ។ សព្វថ្ងៃនេះ ប្រាង្គមួយចំនួនធំត្រូវបានដួលរលំ។ ប្រាង្គទាំង១២ នៅតាមថ្នាក់នីមួយៗគឺតំណាងឱ្យសត្វទាំង១២នៃឆ្នាំ ហើយប្រាង្គទាំង១០៨នោះប្រហែលជានិមិត្តសញ្ញានៃចន្លោះពេលតាមច័ន្ទគតិទាំង៤ ដែលមានរយៈពេល២៧ថ្ងៃនៃចន្លោះពេល

នីមួយៗ។ នៅតាមទិសនីមួយៗ យើងអាចមើលតែ៣៣ប្រាង្គប៉ុណ្ណោះ នេះតំណាងឱ្យចំនួនទេវតាទាំង ៣៣ ក្នុងព្រហ្មញ្ញសាសនា។

ជណ្តើរឡើងប្រាសាទនេះមានលក្ខណៈចោទខ្លាំង។ នៅតាមជណ្តើរនៃថ្នាក់ទាំង៥ មានតោឈរយាមផ្លូវ។ ប្រាសាទនេះមានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ដែលមានគោបុរៈ។ ក្រៅពីនេះមានកូនប្រាសាទនៅខាងជើងដែលមានតំកល់លឹង្គពីរ និងមានបណ្ណាល័យពីរ។ នៅលើភ្នំនេះមានព្រះបាទជាន់ទុកដែលស្ថិតនៅចំកណ្តាលនៃផ្លូវចូលទៅកាន់ប្រាសាទ។

នៅប្រាង្គកណ្តាលដើមឡើយមានតំកល់លឹង្គព្រះឥសូរ។ ប្រាង្គនេះមានទ្វារចូលតាមទិសទាំងបួន។ ប្រាង្គទាំងបួននៅជាន់ខាងលើក៏មានតំកល់លឹង្គព្រះឥសូរផងដែរ តែមានទ្វាចូលតែពីរទិស។ ប្រាង្គកណ្តាលមានចំលាក់អប្សរា។សិលាចារិកមាននៅផ្នែកខាងលិចនៃទ្វារខាងជើងនៃប្រាង្គកណ្តាល។ តាមសិលាចារិក ប្រាសាទភ្នំបាខែងគឺស្ថិតនៅចំកណ្តាលទីក្រុងយសោធបុរ។ នេះត្រូវបានបញ្ជាក់ដោយការរកឃើញស្លាក់ស្នាមកំពែងចាស់របស់ទីក្រុង នៅចុងសតវត្សរ៍ទី៩។ ប្រាសាទនេះមានឈ្មោះដើមថា យសោធរគិរី។ ក្រោយមកគេហៅថា ភ្នំកណ្តាល។ ការហៅនេះប្រហែលជាគេគិតទៅលើការប្រៀបធៀបរវាងភ្នំបូក និងភ្នំក្រោម ហើយភ្នំនេះនៅកណ្តាលគេ។ បច្ចុប្បន្នគេហៅថាប្រាសាទភ្នំបាខែង។ យើងរកឃើញឈ្មោះនេះជាលើកដំបូងនៅក្នុងសិលាចារិករបស់ប្រាសាទនៅសតវត្សរ៍ទី១៦។

ប្រាសាទសំខាន់ៗក្នុងរចនាបថបាខែងមានដូចជា ប្រាសាទភ្នំក្រោម ប្រាសាទភ្នំបូក ប្រាសាទភ្នំបាខែង។



ប្រាសាទភ្នំបាខែង

### **៤-រចនាបថកោះកេរ** (**គ.ស.ទ ទី ១០**)

រចនាបថនេះស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៤ (គ.ស.៩២៨-៩៤១) ដែលទ្រង់បានតាំងរាជធានីនៅកោះកេរ ចម្ងាយប្រមាណ១០០គីឡូម៉ែត្រ នៅទិសឦសាន នៃភូមិភាគអង្គរ។

ប្រាសាទដែលគេរាប់បញ្ចូលនៅក្នុងរចនាបថនេះ គឺប្រាសាទនៅកោះកេរទាំងអស់ ហើយនៅក្នុងចំណោមប្រាសាទទាំងអស់នេះគេឃើញមានប្រាសាទមួយសង់លើខឿនប្រាំពីរជាន់ ដែលមានកំពស់ប្រមាណ៣៥មែត្រ។



ប្រាសាទកោះកេរ

ប្រាសាទកោះកេរបានកសាងឡើងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ ឧទ្ទិសថ្វាយព្រះឥសូរតាមបែបព្រហ្មញ្ញសាសនា។ ប្រាសាទនេះពីដើមឈ្មោះឆកគគីរ ឬផ្ទៃដីគោកគគីរ សព្វថ្ងៃហៅថា អតីតរាជធានីកោះកេរ មានទំហំផ្ទៃដី១៦x១៦គីឡូម៉ែត្រ រួមមានទាំងអស់៩៨ប្រាសាទ ដោយក្នុងនោះមានប្រាសាទមួយមាន៧ជាន់ មានកំពស់ ៣៥ម៉ែត្រ ដែលកសាងឡើងតាំងពីសម័យបុរាណ ទុកសំរាប់ជាការគោរពបូជាតាមលទ្ធិព្រហ្មញ្ញសាសនា។

ក្រុមប្រាសាទនៅកោះកេរមានដូចជា ប្រាសាទធំ ប្រាសាទពោងចិន ប្រាង្គប្រាសាទនាងខ្មៅ ប្រាសាទជើងអង និងប្រាសាទដំរី។ល។

### ៥-រចនាបថប្រែរូប (គ.ស.៩៤៤-៩៦៨)

រចនាបថនេះស្ថិតនៅក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ (គ.ស.៩៤៤-៩៦៨) ដោយប្រាសាទប្រែរូបនេះ ត្រូវបានកសាងឡើងនៅគ.ស.៩៦១។ ប្រែរូបមានភាពស្រដៀងគ្នាច្រើននឹងប្រាសាទមេបុណ្យដែលនៅខាងជើង ហើយស្ថិតនៅចំកណ្តាលថ្នល់បារាយណ៍ "យសោតដាក"។ តួប៉មកណ្តាលដែលនៅជាន់ខាងលើ គឺជាទីដែលគេតម្កល់លិង្គមួយហៅថា "រាជេន្ទ្រកទ្រេសូរ" ពោលគឺលិង្គស្នងព្រះឥសូរដែលមាននាមព្រះរាជាភ្ជាប់ជាមួយនោះផង។ ការកសាង និងឧទ្ទិសប្រាសាទប្រែរូបនេះមានចារជាអក្សរថ្ម ដែលជាសិលាចារឹកវែងជាងគេបង្អស់មួយក្នុងចំណោមសិលាចារឹកជាភាសាសំស្ក្រឹត ដែលគេស្គាល់ចំពោះកម្ពុជាសម័យបុរាណ។



ប្រាសាទប្រែរូប

ក្នុងសម័យនោះ សំណង់ស្ថាបត្យកម្មនៅរក្សាការអនុវត្តតាមរបៀបចាស់ទាំងសម្ភារៈសំណង់ ទាំងការតុបតែងលំអ គឺមានការវិលទៅរកសម័យអតីតកាល ដោយប្រាសាទសំខាន់ៗមាន មេបុណ្យខាងកើត និងប្រែរូប ប្រាសាទទាំងពីរនេះសុទ្ធសឹងជាប្រាសាទសង់លើខឿន ជាសាជីថ្នាក់ៗ នៅថ្នាក់ទាំងអស់មានវិហារ៥ខ្វែងគ្នា សង់អំពីឥដ្ឋ បាយអរ ប៉មវិហារកណ្តាលមានទំហំធំ ហើយសង់ខ្ពស់ជាងប៉ម៤ទៀត។ ក្រៅពីប្រាសាទពីរនេះ មានប្រាសាទតូចៗពីរទៀត គឺប្រាសាទលាក់នាង និងប្រាសាទបាជុំ។

ក្នុងរចនាបថប្រែរូបនេះ គេឃើញចាប់មានសំណង់បន្ទប់វែង នៅលើថ្នាក់នៃសាជី តែគ្រឿងដំបូលនៃបន្ទប់វែងទាំងនោះ ប្រហែលជាធ្វើឈើប្រក់ក្បឿង ឬស្លឹក។

## ៦-រចនាបថបន្ទាយស្រី (ពាក់កណ្តាលទី២ នៃ គ.ស.វ ទី ១០)

រចនាបថបន្ទាយស្រី ស្ថិតនៅក្នុងរជ្ជកាលព្រះបាទរាជិន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៨) ដែលទ្រង់បានតាំងរាជធានីនៅអង្គរវិញ ។

ប្រាសាទបន្ទាយស្រីមានឈ្មោះល្បី ព្រោះវាត្រូវបានសាងសង់ឡើងពី ថ្មផ្កាឈូកជាមួយនឹងក្បាច់ចម្លាក់យ៉ាងល្អិតផ្ចិតផ្ចង់រស់រវើកជាងគេ ដោយមានតួប្រាង្គបី ដែលមានសភាពល្អឆើតឆាយដូចនឹងស្រីគ្រប់លក្ខណ៍អ៊ីចឹងដែរ។

ប្រាសាទនេះសង់លើដីរាបស្មើមានរាងតូចច្រឡឹងដោយថ្មភក់ផ្កាឈូក និងឥដ្ឋរាង៤ជ្រុងទ្រវែង ហើយមានគូទឹកព័ទ្ធជុំវិញ ប្រាង្គទាំងបីនៃប្រាសាទសង់បែរមុខទៅទិសខាងកើត ហើយប្រាង្គកណ្តាលមានតម្កល់លិង្គព្រះឥសូរ ខាងត្បូងឧទ្ទិសថ្វាយដល់ព្រហ្មញ្ញសាសនា និងខាងជើងឧទ្ទិសថ្វាយដល់ព្រះវិស្ណុ។ ប្រាសាទបន្ទាយស្រីកាលដើមឡើយមានឈ្មោះថា "ឥសូរបុរៈ" ប្រែថា "បុរីនៃឥសូរ" ប៉ុន្តែសម័យក្រោយៗមកទៀតគេហៅថា ប្រាសាទបន្ទាយស្រី ទៅវិញដោយសារតែរាងតូចច្រឡឹង និងក្បូរ

ក្បាច់រចនាដ៏ស្រស់ស្អាត និងរស់រវើកនៅលើផ្ទាំងថ្មពណ៌ផ្កាឈូក។ មិនត្រឹមតែប៉ុណ្ណោះ ប្រាសាទនេះបានទទួលការកោតសរសើរពីភ្ញៀវទេសចរសឹងគ្រប់រូបថា ពិតជាស្រស់ស្អាត ទោះបីមានបរិវេណតូចចង្អៀត បន្តិចមែនតែទ្រង់ទ្រាយប្រាសាទលំអទៅដោយចម្លាក់ផ្កាភ្ញី នៃរឿងរ៉ាវដែលទាក់ទងទៅនឹងលទ្ធិទេវរាជ ហើយមិនត្រឹមតែប៉ុណ្ណោះចម្លាក់នីមួយៗ សុទ្ធតែមានលក្ខណៈរស់រវើកបើប្រៀបធៀបទៅ នឹងប្រាសាទដទៃ។

ប្រាសាទបន្ទាយស្រីស្ថិតនៅក្នុងភូមិបន្ទាយស្រី ឃុំបន្ទាយស្រី ស្រុកបន្ទាយស្រី ចំងាយ៣៩គីឡូម៉ែត្រភាគខាងជើងទីរួមខេត្តសៀមរាប ឃ្លាតពីស្រះស្រង់ ២៧គីឡូម៉ែត្រនិងមានចំងាយ៣២គីឡូម៉ែត្រពីប្រាសាទអង្គរវត្តតាមផ្លូវឆ្ពោះទៅភ្នំគូលែន។ តាមឯកសារប្រវត្តិសាស្ត្រអាណាចក្រខ្មែរបានកត់ត្រាថា ប្រាសាទបន្ទាយស្រីបានកសាងឡើងក្នុងគ្រិស្តសករាជ៩៦៧ ក្នុងរជកាលព្រះបាទរាជេន្ទ្រវរ្ម័ន្តគឺមុនការកសាងប្រាសាទអង្គរវត្ត និងអង្គរធំ ដោយព្រហ្មណ៍ម្នាក់ឈ្មោះ យជ្ញវរាហៈ ដែលជាព្រះគ្រូរបស់ព្រះបាទជ័យវរ្ម័ន្តទី៥ ដើម្បីឧទ្ទិសដល់ព្រហ្មញ្ញសាសនា។ ប្រាសាទបន្ទាយស្រីធ្វើពីថ្មភក់ពណ៌ស៊ីជម្ពូ និងរំលេចដោយទេពអប្សរចំនួន១៥០០ ដែលទេពអប្សរទាំងអស់សុទ្ធតែខុសគ្នា ហើយលើសពីនេះសិលាចារឹក ផ្កាភ្ញីនៅប្រាសាទបន្ទាយស្រីមានក្បាច់ល្អលើសពីក្បាច់ចម្លាក់នៅលើ ប្រាសាទអង្គរវត្តទៅទៀតគឺដូចជាក្បាច់ដែលបានឆ្លាក់លើប្រាក់លើស្ពាន់ដូច្នេះដែរ។ បើតាមមគ្គុទេសក៏វិញបញ្ជាក់ថា ព្រះបាទជ័យវ្ម័ន្តទី៥ ទ្រង់ជាអ្នក កសាងប្រាសាទនេះដែលតាមសិលាចារឹកថា "ឥសូរបុរៈ" ឈ្មោះត្រីភុវតមហេស្វរៈប្រែថា "ស្ថាននៃព្រះឥសូរជាធំត្រៃភព" ប្រែថា "បុរីព្រះឥសូរ" មិនមែនឈ្មោះបន្ទាយស្រីដូចយើងស្គាល់ទេ។ ប្រាសាទនេះមានកំពែងថ្មបាយក្រៀមព័ទ្ធ៣ជាន់មានទីលានក្រាលថ្មវែងទៅទិសខាងកើត មានគោបុរៈប្រកបដោយក្បាច់វិចិត្រ នៅចំកណ្តាលទីលានមានរោងទងខ្វាត់ខ្វែងក្រឡាចត្រង្គចេញទៅខាងជើងមួយ ចេញទៅខាងត្បូងបីសុទ្ធសឹងប្រកបដោយក្បាច់រចនាល្អវិចិត្រ។ សព្វថ្ងៃនេះបាក់ធ្លាក់អស់ហើយសល់តែសរសរច្រូងច្រាងគួរឱ្យស្តាយ។ ប្រាសាទបន្ទាយស្រីជាប្រាសាទមួយដែលមានក្បាច់រចនាយ៉ាងបញ្ចង់ធើតធាយ មានសន្លឹកភ្ញីវល្លិវិលវង់ល្អិតផ្ចិតស្រស់រស់រវើក ដែលមើលទៅគួរអោយនឹកគិតឥតមានក្តីសង្ស័យថា "ទេវតានិម្មិត"។ សន្លឹកក្បាច់មួយទងៗដែលវិលវង់មូលក្រឡង់អាចទាញភ្នែកគយគន់មើលម្តងហើយម្តងទៀតនិងអោយឈរទ្រឹងភាំងភ្លេចខ្លួនជញ្ជក់មាត់ដោយ សេចក្តីស្ងើចថ្ងៃដែសម្តែងអោយឃើញថា សម័យកសាងប្រាសាទបន្ទាយស្រីនេះជាសម័យនៃការចេះដឹងស្ទាត់ជំនាញ របស់បុព្វបុរសខ្មែរនាសម័យនោះ។ ប្រាសាទបន្ទាយស្រីកន្លងមកត្រូវវងនូវភាពមហន្តរាយដោយសារតែសង្គ្រាមបានធ្វើឱ្យប្រាសាទបុរាណមួយនេះខូចខាតខ្ទេចខ្ទីអស់យ៉ាងច្រើន។ របងកំពែងការពារខាងក្រៅត្រូវបានគេធ្វើការជីកគាស់កាយរុករកវត្ថុបុរាណ កាលពីអំឡុងប្រទេសស្ថិតនៅក្នុងសង្គ្រាម។ គំនរដុំថ្មប្រាសាទត្រូវទុករាយប៉ាយនៅមុខប្រាសាទ។ តួប្រាសាទខាងក្នុងមួយភាគត្រូវបាក់បែកស្រុតទ្រុឌដែលមើលទៅគួរឱ្យសង្វេគ។

ប្រាសាទសំខាន់ៗក្នុងរចនាបថបន្ទាយស្រីមានដូចជា ប្រាសាទបន្ទាយស្រី ប្រាសាទស្រឡៅ ប្រាសាទតូច (ក្រោយប្រាសាទឃ្លាំងខាងជើង) ប្រាសាទឥន្ទ្រកោសីយ៍ ប្រាសាទត្រពាំងខ្យង ប្រាសាទ Sek Ta Tuy។



ប្រាសាទបន្ទាយស្រី

**៧-រចនាបថឃ្លាំង (ចុងស.វ.ទី១០ និងពាក់កណ្តាលទី១ នៃស.វ.ទី ១១)**

រចនាបថនេះស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៦៨-១០០១) និងព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) ដែលមានរាជធានីនៅអង្គរ។



ប្រាសាទឃ្លាំងខាងជើង

អ្វីដែលគួរឱ្យកត់សម្គាល់ក្នុងរចនាបថនេះ គឺមាន "ថែវ" នៅព័ទ្ធជុំវិញតួប៉មខាងលើបង្អស់ ថែវនោះមានលក្ខណៈដូចជាបន្ទប់រាងទ្រវែង (ប្រាសាទតាកែវ)។ ឯនៅប្រាសាទភិមានអាកាសវិញ ចាប់ផ្តើមមានថែវព័ទ្ធជុំវិញដែលមានដំបូលរាងកោង។ ប្រាសាទសំខាន់ៗក្នុងរចនាបថនេះមាន ប្រាសាទ

តាកែវ ប្រាសាទឃ្លាំងខាងជើង (អង្គរធំ) ប្រាសាទឃ្លាំងខាងត្បូង (អង្គរធំ) ប្រាសាទភិមានអាកាស គោបុរៈនៃរាជវាំង (១១០០) វត្តឯកភ្នំ ភ្នំជីសូរ ព្រះវិហារ និងចៅស្រីវិជ័យយុគេ។



ប្រាសាទភិមានអាកាស

**៨-រចនាបថបាពួន** (**ពាក់កណ្ដាលទី ២ នៃស.វ.ទី ១១**)

រចនាបថនេះ ស្ថិតនៅក្នុងរជ្ជកាលព្រះបាទឧទយទិត្យវរ្ម័នទី២ (គ.ស.១០៥០-១០៦៦) ព្រះបាទហ៍សវរ្ម័នទី៣ (គ.ស.១០៦៦-១០៨០) ដែលមានរាជធានីនៅអង្គរ។ នៅក្នុងសម័យនោះ ការកសាងប្រាសាទភ្នំវិតតែមានការរីកចម្រើនឡើងថែមទៀត គឺប្រាសាទបាពួនមានថែវពីរជាន់ ប្រក់ថ្មភក់ព័ទ្ធជុំវិញ ព្រមទាំងមានប្រាង្គនៅគ្រប់ជ្រុងថែវ និងមានគោបុរៈនៅត្រង់ជណ្ដើរគ្រប់ទិសទាំងបួនទៀត។ នៅក្នុងប្រាសាទបាពួន គេសង្កេតឃើញមានរចនាក្បាច់រឿង នៅតាមជញ្ជាំងគោបុរៈនិងជញ្ជាំងប្រាង្គជ្រុងជាន់ទី២ក្បាច់រឿងទាំងនេះ ចែកជាផ្ទាំងតូចដាច់ៗពីគ្នាមានរាងចតុកោណកែងស្មើ។ ចតុកោណកែង ហើយច្រើនតែរឿងដែលទាក់ទងទៅ និងព្រះវិស្ណុ រីឯរូបបដិមាវិញ ពុំខុសពីរចនាបថឃ្លាំងឡើយ។

មានទីតាំងស្ថិតនៅផ្លូវចូលទៅកាន់ទ្វារជីផ្ទាំង ស្ថិតនៅបន្ទាប់ពីប្រាសាទបាយ័ន និងក្បែរព្រលានជល់ដំរី។ ប្រាសាទនេះកសាងឡើងនៅសតវត្សរ៍ទី១១ រវាងឆ្នាំ១០៦០ ដោយព្រះបាទឧទាយទិត្យវរ្ម័នទី២ (១០៥០-១០៦៦) ដើម្បីឧទ្ទិសថ្វាយដល់ព្រហ្មញ្ញសាសនា។ ប្រាសាទនេះមានចំលាក់ខុសពីប្រាសាទផ្សេងៗទៀត គឺឆ្លាក់នៅលើថ្មតូចៗស្រដៀងនឹងឥដ្ឋ។ ចម្លាក់នេះនៅសេសសល់តិចតួចប៉ុណ្ណោះ។ ប្រាសាទភ្នំនេះមានរាងដូចសាជីមានប្រាំថ្នាក់សំណង់ធ្វើ ពីថ្មភក់ថ្មបាយក្រៀម និងឈើមានគោបុរៈនៅទាំងបួនទិស ព្រមទាំងមានរូបចម្លាក់ក្បាច់រចនា ល្អឆើតទាក់ទងទៅនឹងរឿងរាមកេរ្តិ៍ខ្មែរ និងមានក្បាច់ចម្លាក់ផ្សេងៗទៀត ទាក់ទងទៅនឹងល្បែងកីឡា និងរូបព្រះពុទ្ធចូលព្រះនិព្វានដែលគេទើបកសាងនាសម័យលង្វែក។



ប្រាសាទបាពួន

ប្រាសាទនេះជាប្រភេទប្រាសាទភ្នំតំណាងអោយភ្នំព្រះសុមេរុ មានកំពែងប្រវែង ៤២៥ x ១២៤ ម៉ែត្រព័ទ្ធជុំវិញ។ លក្ខណៈពិសេសមួយទៀតនៃប្រាសាទនេះ គឺផ្លូវចូលប្រវែង ២០០ម៉ែត្រ នៅទិសខាងកើត មានលក្ខណៈជាស្ពានទ្រដោយសសរមូលបីជួរ។ នៅជាន់ទីមួយ ទីពីរ ទីបី នៃប្រាសាទមានថែវធ្វើពីថ្មភក់។

ប្រាសាទដែលស្ថិតនៅក្នុងរចនាបថនេះមាន ប្រាសាទបាពួង ប្រាសាទមេបុណ្យខាងលិច និងបារាយណ៍ទឹកថ្លា ប្រាសាទវត្តខ្នា ប្រាសាទខ្នា និងប្រាសាទឯកភ្នំ។

**៩-រចនាបថអង្គរវត្ត (ពាក់កណ្តាលទី ១ នៃស.វ.ទី ១២)**

រចនាបថអង្គរវត្ត គឺស្ថិតនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៤៥) ដែលមានរាជធានីនៅអង្គរ។ ប្រាសាទដែលចាក់បញ្ចូលក្នុងរចនាបថនេះ គឺប្រាសាទបេងមាលា ប្រាសាទព្រះបាលិលេយ្យ ប្រាសាទកំពូល ប្រាសាទបាគង។ល។ នៅក្នុងរចនាបថនេះ ស្ថាបត្យករខ្មែរ មានការរីកចម្រើនឡើងដល់កំពូល។

បើតាមលោកហ្សក-សឺដែស ប្រាសាទអង្គរវត្តគឺតំណាងឲ្យពិភពលោក។ ប្រាង្គកណ្តាលតំណាងឱ្យភ្នំព្រះសុមេរុ ដែលស្ថិតនៅកណ្តាលពិភពលោក។ ប្រាង្គទាំង៥ តំណាងឲ្យកំពូលភ្នំព្រះសុមេរុដែលជាជាយផែនដី និងគូទឹកព័ទ្ធជុំវិញប្រាសាទគឺ ជាសមុទ្រដែលព័ទ្ធជុំវិញ។ ប្រាសាទអង្គរវត្តមានឈ្មោះដើមថា ប្រាសាទបរមវិស្ណុលោក។ ប៉ុន្តែការវិវត្តនៃឈ្មោះអង្គរវត្តនេះ អាចត្រូវបានគេយកតាមប្រវត្តិសាស្រ្ត។ ស្លាកស្នាមដំបូងគឺមាននៅសតវត្សរ៍ទី១៦។ ជាការពិតណាស់ប្រាសាទនេះ បានក្លាយទៅជាកន្លែងពុទ្ធសាសនាដ៏ល្បីល្បាញមួយ។ តាមសិលាចារឹកនៅសតវត្សរ៍ទី១៦ ឈ្មោះនៃប្រាសាទអង្គរវត្តគឺ ព្រះមហានគរឥន្រ្ទប្រត្តព្រះពិស្ណុលោក ហើយមួយចំណែកទៀតនៅសតវត្សរ៍ទី ១៧

ហៅថាឥន្ទបត្តម្ពានគរ ស្រីសុធរពិស្ណុលោក។ ចំណែកឈ្មោះថាអង្គរវត្ត គឺជាឈ្មោះសាមញ្ញសម្រាប់កំណត់បូជនីយដ្ឋាននេះ។



ប្រាសាទអង្គរវត្ត

ចំពោះប្រជាជនខ្មែរ ពិសេសអ្នករស់នៅខេត្តសៀមរាប ច្រើនហៅឈ្មោះរួមមួយគឺ អង្គរតូច។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកនិពន្ធអឺរ៉ុបទាំងអស់បានកំណត់ហៅឈ្មោះរួមមួយគឺ អង្គរវត្តដែរ។ អង្គរវត្តសណ្ឋកទៅភាគខាងជើង ៥,៥ សហាតិមាត្រ (៣,៤ម៉ៃ.) នៃទីប្រជុំជនសម័យទំនើបសៀមរាប និងទិសខាងត្បូងចម្ងាយខ្លី និងខាងកើតបន្តិចនៃរាជធានីពីមុននេះដែលស្ថិតនៅបាពួន។ វាគឺជាតំបន់របស់កម្ពុជាមួយ ដែលមានក្រុមរចនាសម្ព័ន្ធសំណង់សំខាន់ៗ។ ស្ថិតនៅខាងត្បូងបំផុតនៃស្ថានីយសំខាន់ៗរបស់អង្គរ។

ប្រាសាទដែលស្ថិតនៅក្នុងរចនាបថអង្គរមាន ប្រាសាទធម្មនន្ទ ប្រាសាទព្រះពិធូរ ប្រាសាទភិម័យ ប្រាសាទចៅសាយទេវតា ប្រាសាទបន្ទាយសម្រែ ប្រាសាទបេងមាលា តួប៉មខាងលើប្រាសាទបាគង ប្រាសាទព្រះបាលិលេយ្យ ព្រះខ័នកំពង់ស្វាយ (ផ្នែកកណ្តាល)។

**១០-រចនាបថបាយ័ន (ពាក់កណ្តាលទី១ នៃស.វ.ទី១២ និងដើមស.វទី១៣)**

រចនាបថបាយ័ន ស្ថាបត្យកម្មខ្មែរបានចុះអន់ថយបន្តិចវិញ ព្រោះប្រាសាទទាំងឡាយច្រើនស្ថាបនាដោយប្រញាប់ប្រញាលពេក ឯថ្មវិញ ក៏ពុំសូវមានគុណភាពដូចសម័យមុនៗដែរ។ ប្រាសាទបាយ័នមានប្លង់ស្មុគស្មាញ ហើយរុះរើសាងឡើងវិញជាច្រើនគ្រា។ លើកលែងតែប្រាសាទបាយ័ន ដែលមានប្លង់បែបជាប្រាសាទភ្នំ ក្នុងរចនាបថនេះ ប្រាសាទទាំងឡាយ សុទ្ធតែសង់នៅលើដីរាបស្មើបែបជាវត្តអារាម ដើម្បីស្របទៅតាមទស្សនៈនៃព្រះពុទ្ធសាសនា។ លក្ខណៈពិសេសនៃរចនាបថនេះ គឺប្រាំងមុខបួនញញឹមប្រិមប្រិយ និងមាននាគអមសងខាងផ្លូវ ដែលឆ្លងចូលទៅក្នុងប្រាសាទ ក្បាលនាគបែរចេញមកខាងក្រៅ នាគម្ខាងមានពួកទេវតាជាអ្នកចាប់ទាញ ឯម្ខាងទៀតមានពួកអសុរៈចាប់ទាញជានិមិត្តរូបនៃការកូរសមុទ្រទឹកដោះ។

ប្រាសាទបាយ័ន ស្ថិតនៅចំកណ្តាលនៃក្រុងអង្គរធំ។ ប្រាសាទនេះកសាងនៅចុងគ្រិស្តសតវត្សរ៍ទី១២ និងដើមគ្រិស្តសតវត្សរ៍ទី១៣ ដោយព្រះបាទជ័យវរ្ម័នទី៧។ ប្រាសាទនេះមានតួប៉មនីមួយៗ

មានមុខបួន ដែលមានកំពូល៤៩ និងកំពូលក្លោងទ្វារចូល៥ទៀត សរុបទាំងអស់ ៥៤កំពូល ដែលតំណាងឲ្យខេត្តក្រុងខ្មែរទាំង៥៤ នៅសម័យកាលនោះ។ មានអ្នកប្រាជ្ញមួយចំនួន បានគិតថា មុខទាំង ៤ នោះតំណាងឱ្យព្រះពោធិសត្វលោកេស្វរៈ អ្នកខ្លះទៀត គិតថាជារូបតំណាងព្រះបាទជយវរ្ម័នទី ៧។ ប្រាសាទបាយ័នមានប្លង់បីជាន់។ ជាន់ទី១ និងទី២ មានថែវដែលមានចម្លាក់ដ៏ល្អ។ ប្រាង្គនៅកណ្ដាល១៦ និងស្ថិតនៅជាន់ទី៣ មានរាងកាកបាទ។ សំណង់ប្រាសាទបាយ័នមានលក្ខណៈស្មុគស្មាញ ទាំងថែវ ផ្លូវដើរ និងជណ្ដើរ។ ក្រៅពីទឹកមុខញញឹមនៃរូបបាយ័ន ប្រាសាទនេះមានចម្លាក់ដ៏ល្អប្រណីត ដែលរៀបរាប់ពីរឿងទេវកថានៅថែវខាងក្នុង និងខាងក្រៅ រៀបរាប់ពីជីវភាពរស់នៅរបស់ប្រជាជននៅសម័យអង្គរ មានទាំងផ្សារ ការនេសាទ ពិធីបុណ្យ ល្បែងប្រជាល់ ជល់មាន់។ល។ និងថែមទាំងមានការរៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ចម្បាំង និងព្យុហយាត្រា ជាដើម។ ចម្លាក់នោះឆ្លាក់បានជ្រៅជាងនៅប្រាសាទអង្គរវត្តតែមានលក្ខណៈ សាមញ្ញ។ ទិដ្ឋភាពនៃចម្លាក់បង្ហាញដោយផ្ទាំងតាមជួរ ពីរឬបីជួរ។

ប្រាសាទសំខាន់ៗនៃរចនាបថបាយ័នមាន ប្រាសាទបាយ័ន ប្រាសាទបន្ទាយក្ដី ប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័ន ប្រាសាទតាសោម ប្រាសាទតានៃ ប្រាសាទជ្រុងនៅលើកំពែងអង្គរធំ ប្រាសាទក្រោលគោ ប្រាសាទនាគព័ន្ធ ប្រាសាទព្រះខ័នកំពង់ស្វាយ ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព ប្រាសាទបាណន់ ប្រាសាទវត្តនគរ ប្រាសាទតាព្រហ្ម។...



ប្រាសាទបាយ័ន



ប្រាសាទបន្ទាយឆ្មារ

## ៣.សន្និដ្ឋាន

ជាទូទៅ ស្ថាបត្យកម្ម និងសំណង់សម័យអង្គរ គឺធ្វើឡើងសម្រាប់បម្រើវិស័យសាសនា ភាគច្រើនសាសនាព្រាហ្មណ៍។ ម្យ៉ាងវិញទៀត ស្ថាបត្យកម្មទាំងនោះច្រើនតែពាក់ព័ន្ធ ទៅនឹងការបូជាព្រះឥសូរ ឬព្រះសិវៈក្រោមរូបភាពសិវលិង្គជាងនិកាយ ឬសាសនាផ្សេងៗទៀត។ ហើយតាមរយៈសំណង់ ឬស្លាក់ស្នាមនៃសំណង់ស្ថាបត្យកម្មបុរាណទាំងនោះ យើងអាចឃើញនូវក្របខ័ណ្ឌប្រវត្តិសាស្ត្រវប្បធម៌សាសនារបស់ព្រះរាជាណាចក្រកម្ពុជានាអតីតកាល ដែលលាតសន្ធឹងពីឈូងសមុទ្រសៀមសព្វថ្ងៃនេះ រហូតដល់ទីក្រុងវៀងច័ន្ទ និងពីប្រទេសយៀកណាមខាងត្បូង ឬកម្ពុជាក្រោមរហូតដល់ទន្លេមេណាម។

ការរីកសាយនូវប្រាង្គប្រាសាទសម័យអង្គរដែលមានរយៈពេលប្រមាណជា ៦០០ឆ្នាំដែលជាភស្តុតាងនៃសេចក្តីរុងរឿង និងវិសាលភាពរបស់ប្រទេសខ្មែរបុរាណ បានទាក់ទាញឱ្យយើងស្រាវជ្រាវរកនូវមូលហេតុនៃការរីកចម្រើននេះ អ្វីដែលយើងខិតខំមកស្រាយដោយសម្អាងលើទិន្នន័យ ជាប្រវត្តិសាស្ត្រមួយចំនួន។ ដូចយើងបានជម្រាបមកហើយ ជាទូទៅសម័យមហានគរត្រូវបានចាប់បដិសន្ធិឡើងនៅឆ្នាំ៨០២ នៅពេលដែលព្រះបាទជ័យវរ្ម័នទី២ ប្រកាសលើភ្នំគូលែនថា ព្រះអង្គជាអធិរាជចក្រវាទិន ឬស្តេចចក្រវាឡ ដែលនៅទីនេះសញ្ញាណចក្រវាឡ គ្រាន់ទេសំដៅចក្រភពខ្មែរតែប៉ុណ្ណោះ ដែលមានទំហំដ៏ធំមហាសាល។

នៅអំឡុងស.វ.ទី៩ ដល់ស.វ.ទី១៣ ក៏ដូចជាសម័យបុរេអង្គរ វិសាលភាពរបស់ភូមិសាស្ត្រជាប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរក្សាដោយព្រះមហាក្សត្រខ្មែរសំខាន់ដែលជាស្តេចសឹក ហើយស្តេចស្ថាបនិកអមដោយអ្នកប្រាជ្ញធំៗខាងសាសនា ក៏ដូចជាខាងសាធារណការ។ ក្នុងករណីនេះហើយ បានជាយើងឃើញឈ្មោះនៃពួកព្រាហ្មណ៍ធំៗ ដែលជាវិស្វករចំណានៗសាងសង់គ្រប់គ្រងបូជនីយដ្ឋានរបស់ស្តេចក្នុងរាជបុរីនានា ដែលមានរាយការក្នុងអត្ថបទសិលាចារឹក។ ការដែលព្រះមហា

ក្សត្រចារឈ្មោះអ្នកប្រាជ្ញទាំងនោះ លើថ្ម គឺជាការលើកតម្កើងតម្លៃសីលធម៌ និងយុត្តិធម៌ខ្ពង់ខ្ពស់របស់ជនជាតិខ្មែរ ដែលរមែងតែងដឹងគុណចំពោះអ្នកដែលមានថ្វីដៃវីរបុរសជាតិ។

ដូច្នេះហើយបានជាសម័យអង្គរ ព្រះរាជាណាចក្រកម្ពុជារក្សាបនាទាំងស្រុងនូវទំហំដីធំធេងមហាសាល នាសម័យនគរភ្នំ ស្រុកខ្មែរមានព្រំដែនប្រទល់ខាងត្បូងលាតសន្ធឹងដល់ជ្រោយមឃូ ឬម៉ាឡាកា ភាគខាងត្បូងនៃប្រទេសថៃបច្ចុប្បន្ន។ ពីទិសខាងលិចទៅទិសខាងកើតដល់ប្រទេសភូមា ពោលគឺប៉ាហ្គានដល់ឈូងសមុទ្រចិន ពោលគឺកម្ពុជា ដែលក្លាយទៅជាប្រទេសយៀកណាមខាងត្បូងសព្វថ្ងៃ។ ក្នុងសម័យដ៏មហារុងរឿងនេះ គេពុំទាន់ឃើញមានវត្តមានរបស់ជនជាតិថៃ លាវ និងយួននៅឡើយទេ។ ក្រៅពីជនជាតិខ្មែរ ដែលជាម្ចាស់ទឹកដីនៃចក្រភពកម្ពុជទេសនេះ គេឃើញមានកុលសម្ព័ន្ធមន-ខ្មែរ ឬភ្នង (ខ្មែរលើ) ដែលរួមពូជសាសន៍ជាមួយខ្មែរយ៉ាងច្រើនកុះករ។ គឺពួកនេះហើយ ដែលបានក្លាយជាប្រភពពលកម្មយ៉ាងសកម្មមួយក្នុងការអភិវឌ្ឍទឹកដី និងសង្គមខ្មែរបានបែបសម័យទំនើប ពោលគឺតាមហេដ្ឋារចនាសម្ព័ន្ធបែបឥណ្ឌា។ នៅទីនេះ យើងចង់និយាយថា នយោបាយ និងសាសនាដ៏រឹងមាំនៃព្រះរាជាណាចក្រកម្ពុជាបុរាណ ពុំអាចអនុវត្តន៍ទៅបានដោយជោគជ័យជាស្ថាពរទេ ប្រសិនបើគ្មានអភិបាលកិច្ចល្អ ដែលក្នុងនោះមានពួកបម្រើជាតិខ្មែរ និងខ្មែរលើចូលរួមនោះទេ ដែលពុំមែនជាឈ្លើយសឹក ដូចជានៅប្រទេសអ៊ីតាលីបុរាណ។ នេះជាតម្រូវការរបស់យើង ចំពោះទស្សនៈខ្លះដែលបានពោលថា បូជនីយដ្ឋានដ៏ល្បីល្បាញរបស់ជនជាតិខ្មែរ ដូចជាប្រាសាទអង្គរវត្ត ប្រាសាទពិមាយ៕...

## គន្ថនិទ្ទេសៈ

### ក-ឯកសារជាភាសាខ្មែរ


១.កញ្ញាហ្សី តូ,ប្រែសម្រួលដោយអួង វន,ប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីក្នុង តំបន់ អង្គរ។

២.ពុទ្ធសាសនបណ្ឌិត្យ,ពុទ្ធសាសនា ២៥០០, ភ្នំពេញ, ១៩៥៧ ។

៣.ឃីង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ២០០៣ ។

៤.ជី វង្ឍា, ប្រវត្តិសាស្ត្រ-ប្រវត្តិសិល្បៈខ្មែរ, ២០១០។

៥.ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ, ភាគ១ ២, ១៩៧៣ ។

៦.ត្រឹង ងា, អរិយធម៌ខ្មែរ, អ្នកស្រី ភ្នំពេញ, ១៩៧៥ ។

៧.បណ្ឌិត ធ សោ, ព្រហ្មញ្ញសាសនា និងសង្គមខ្មែរ, សម្រាប់ជំនួយស្មារតីដល់ និស្សិតថ្នាក់ត្រៀមឧត្តមសិក្សា និស្សិតថ្នាក់បរិញ្ញាប័ត្រ អក្សរសាស្ត្រ, ១៩៩៤ ។

៨.ព្រះមហា ទូច ម៉ៃ សុសំវុតោ, សាសនាប្រៀបធៀបសម្រាប់ពុទ្ធិកវិទ្យាល័យថ្នាក់ទី ១០, ២០០៨ ។

៩.ពៅ សាវរស, សទ្ទានុក្រម សំស្រ្កឹត ខ្មែរ បារាំង, បណ្ណាគារអង្គរ, ២០១៣ ។

១០.ម. ត្រាណេ និងអួង វន, ប្រាសាទបាពួន, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ១៩៩០។

១១.ម. ត្រាណេ, វប្បធម៌ អរិយធម៌, មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ, ភាគ១, ២០១៣។

១២.ម. ត្រាណេ, វប្បធម៌ អរិយធម៌, មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ, ភាគ២, ២០១៤។
១៣.យិន គឹមវាណ, ប្រភពវប្បធម៌ អរិយធម៌ ចរិតខ្មែរ, ២០១០ ។
១៤.លាង ហាប់អាន, សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ, សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សទី១ ដល់ ១៨៥៩), ភ្នំពេញ, ១៩៦៧ ។
១៥.វង់ សុធារ៉ា និង ណុប សុខា, ប្រវត្តិសាស្ត្រខ្មែរ, សម្រាប់សិក្សាថ្នាក់មូលដ្ឋាន, ឆ្នាំសិក្សា២០១០ ២០១១ ។
១៦.សុង ស៊ីវ, ចលនាអារ្យធម៌, ភាគ១ ២, ១៩៧១ ។
១៧.សរ សារុន, វប្បធម៌ និងអរិយធម៌ខ្មែរ, សម្រាប់ថ្នាក់ទីបញ្ចប់ ថ្នាក់ត្រៀមនៃឧត្តមសិក្សា, បណ្ណាគារពន្លឺវិទ្យា, ១៩៧០ ។
១៨.ហួត រេចសួ, អត្ថាធិប្បាយ វប្បធម៌ អរិយធម៌ទូទៅ, ១៩៧៤ ។
១៩.ឡុង សៀម, វចនានុក្រមខ្មែរបុរាណ, (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦-៨)។
២០.អួង វន, រចនាបថប្រាសាទបុរាណខ្មែរពីរចនាបថភ្នំដាដល់រចនាបថបាយ័ន្ត, ២០០១។
២១.អួង វន, មគ្គុទេសក៏ប្រាសាទអង្គរ, ១៩៩៩។

**ខ-ឯកសារជាភាសាបរទេស**

1. Bruno Dagens, Angkor Heart of an Asian Empire, 1989.
2. Christopher Pym, The Anient Civilisation of Angkor, 1968.
3. Henri Marchal, Nouveau Guide D'Angkor, 1961.
4. Jean Boisselier, Tendances de L'Art Khmer, 1956.
5. Khmer Art in Stone, National Museum of Cambodia.
6. Maurice Glaize, Les Monuments du Groupe D'Angkor, Paris, 1963.
7. Solange Thierry, Les Khmers, 1964.
8. Philippe Stern. Le Bayon d'Angkor et l'évolution de l'art Khmer. (Annales du Musée Guimet.), Journal des savants / Année .1928
9. Robert Dalet, Recherches archéologiques au Cambodge. Note sur un linteau récemment découvert, Bulletin de l'École française d'Extrême-Orient / Année 1939 / 39.
10. Philippe Stern, Le style du Kulên (décor architectural et statuaire), Bulletin de l'École française d'Extrême-Orient / Année 1938 / 38 / pp. 111-150.
11. Éric Bourdonneau, Nouvelles recherches sur Koh Ker (Chok Gargyar). Jayavarman IV et la maîtrise des mondes, Monuments et mémoires de la Fondation Eugène Piot / Année 2011 / 90 / pp. 95-141.

12. Philippe Stern, Un nouveau style Khmèr au Phnom Kulèn, Comptes rendus des séances de l'Académie des Inscriptions et Belles-Lettres / Année 1937 / 81-4 / pp. 333-339.
13. Jeannine Auboyer, L'art khmer du IXe au XIIIe siècle, Cahiers de civilisation médiévale, 14e année (n°54), Avril-juin 1971. pp. 119-129.

## ឧបសម្ព័ន្ធ



ប្រាសាទដំរីក្រាប (រចនាបថគូលែន)



ប្រាសាទបាគង (រចនាបថព្រះគោ)



ប្រាសាទភ្នំបាខែង (រចនាបថបាខែង)



ប្រាសាទភ្នំបូក (រចនាបថបាខែង)



ប្រាសាទកោះកេរ (រចនាបថកោះកេរ)



ប្រាសាទប្រែរូប (រចនាបថប្រែរូប)



ប្រាសាទស្រឡៅ (រចនាបថបន្ទាយស្រី)



ប្រាសាទបន្ទាយស្រី (រចនាបថបន្ទាយស្រី)



ប្រាសាទភិមានអាកាស (រចនាបថឃ្លាំង)



ប្រាសាទធម្មនន្ទ (រចនាបថអង្គរ)



ប្រាសាទអង្គរវត្ត (រចនាបថអង្គរ)



ប្រាសាទបន្ទាយឆ្មារ (រចនាបថបាយ័ន)


ប្រាសាទបាយ័ន (រចនាបថបាយ័ន)

# "ការវិវត្តនៃរចនាបថស្ថាបត្យកម្ម និងសំណង់ប្រាសាទខ្មែរ សម័យលង្វែក-ឧដុង្គ"

ដោយបណ្ឌិតសភាចារ្យ **សោម សុមុនី** សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា
និងលោក **អ៊ុំ ចណ្ណាច័ន្ទបញ្ញា** និស្សិតបរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរនៃស.ភ.ភ.ព.

## ១-សេចក្ដីផ្ដើម

ក្រោយការចាកចោលក្រុងអង្គរនៅឆ្នាំ១៤៣១ ដោយព្រះបាទពញាយ៉ាត គេលែងឃើញមាននូវការសាងសង់សំណង់ផ្សេងៗដ៏គួរឱ្យចាប់អារម្មណ៍ដូចនៅសម័យអង្គរទៀតហើយ។ មានតែការកែប្រែទ្រង់ទ្រាយសំណង់សម័យអង្គរឱ្យទៅជាសំណង់មួយបែបក្នុងទម្រង់ជំនឿពុទ្ធសាសនា នាសម័យកណ្ដាល ដូចយ៉ាងការរុះរើថ្មប្រាសាទបាពួន លើកមកតម្រៀបធ្វើជាព្រះពុទ្ធរូបបរិនិព្វានជាដើម។ ម្យ៉ាងវិញទៀត វត្តមានព្រះពុទ្ធសាសនាថេរវាទបានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរជំនួសឱ្យព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនា។ សំណង់ស្ថាបត្យកម្មសំខាន់ៗក៏ត្រូវបានកសាងឡើងក្នុងឥទ្ធិពលនៃពុទ្ធសាសនាថេរវាទវិញដែរ។ ក្នុងចំណោមសំណង់សម័យកណ្ដាល គេសង្កេតឃើញមានសំណង់វត្តអារាមមានការដុះដាលយ៉ាងច្រើននៅស្រុកខ្មែរ ដែលបានដើរតួនាទីជាទីកន្លែងសក្ការៈបូជាជំនួសឱ្យប្រាសាទបុរាណនានា ដែលធ្លាប់តែជាទីកន្លែងសក្ការៈបូជាក្នុងលទ្ធិព្រហ្មញ្ញសាសនា ឬពុទ្ធសាសនាមហាយានអញ្ចឹងដែរ។

ការវិត្តនៃសំណង់ស្ថាបត្យកម្មសម័យលង្វែក-ឧដុង្គ ជាដំណើរវិវត្តន៍គួរឱ្យកត់សម្គាល់មួយដែលជាគំរូនៃរចនាបថសំណង់ បន្តមកសម័យក្រោយៗមកទៀត។

## ២-ការវិវត្តនៃរចនាបថស្ថាបត្យកម្ម និងសំណង់ខ្មែរសម័យលង្វែក-ឧដុង្គ

អារ្យធម៌សម័យកណ្ដាលចាប់ផ្ដើមកើតជារូបរាងតាំងពីមុនអង្គរធ្លាក់ចុះមកម្ល៉េះ។ ដូច្នេះពុំអាចពោលថាជាអារ្យធម៌ថ្មីមួយផ្សេងស្រឡះពីអារ្យធម៌អង្គរនោះទេ។ ត្រង់ចំណុចនេះ យើងអាចនិយាយបានថា អារ្យធម៌អង្គរ គឺជាមេនៃអារ្យធម៌សម័យកណ្ដាល ក៏ប៉ុន្តែយើងត្រូវចាត់ទុកសម័យមួយដោយឡែក ដ្បិតវប្បធម៌មានប្រភេទផ្សេងពីមុន យោងតាមទស្សនៈសាសនា ភាសា សិល្បៈជាដើម។ ម្យ៉ាងទៀតទម្រង់នៃស្ថាបត្យកម្មខ្មែរក៏មានការវិវត្តឈានមករកលក្ខណៈថ្មីមួយទៀតផងដែរ។ ដោយសារព្រះពុទ្ធសាសនាថេរវាទបានដើរតួនាទីយ៉ាងសំខាន់ ជំនួសឱ្យសាសនាបុរាណពីរបស់ខ្មែរ គឺព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយាន សឹងគ្រប់វិស័យទាំងអស់ មានការផ្លាស់ប្ដូរឱ្យស្របនឹងជំនឿពុទ្ធសាសនាថេរវាទនេះ។ តួយ៉ាងនៅក្នុងទិដ្ឋភាពសំណង់ស្ថាបត្យកម្មខ្មែរនាសម័យកណ្ដាលនិយាយជារួមជាពិសេសសម័យលង្វែកនេះតែម្ដង។

## ក. ការកែប្រែសំណង់ព្រហ្មញ្ញសាសនាឱ្យទៅជាទីសក្ការៈពុទ្ធសាសនា (ឬព្រះធាតុ)

នៅរវាងសតវត្សទី១៤ និងទី១៥ គេបានសង់ព្រះវិហារជាច្រើនកន្លែងនៅអង្គរធំតែម្តង។ ខ្លះនៅដាច់តែឯង ខ្លះទៀតតាំងនៅក្នុងប្រាសាទព្រហ្មញ្ញសាសនាដែលមានស្រាប់។ ដោយរៀបចំទៅជាកន្លែងសម្រាប់តម្កល់បល្ល័ង្កព្រះ ដោយទុកតម្កល់ព្រះពុទ្ធរូបផ្សេងទៀត។ ការកែប្រែប្រាសាទឱ្យទៅជាព្រះវិហារសម្រាប់ព្រះពុទ្ធសាសនា យើងឃើញមានជាឧទាហរណ៍នៅប្រាសាទតុប ប្រាសាទតាទូត (ប្រាសាទមួយក្នុងចំណោមក្រុមប្រាសាទព្រះពិធូរ)។ វត្តព្រះឥន្ទ្រកោសីយ៍ វត្តលលៃ ក្នុងបរិវេណអង្គរវត្តតែម្តង។

ប្រាសាទបាពួន ខ្មែរសម័យកណ្តាលកែប្រែជាន់ទី២ ប៉ែកខាងលិចនៃពីរ៉ាមីតទាំងមូលនេះ ឱ្យទៅជាព្រះពុទ្ធរូបចូលនិព្វានប្រវែង ៦០ម៉ែត្រ។



*ព្រះពុទ្ធរូបចូលនិព្វានប្រវែង៦០ម៉ែត្រនៅប្រាសាទបាពួន ខេត្តសៀមរាប*

ប្រាសាទបាខែង ក៏ត្រូវបានខ្មែរនាសម័យកណ្តាលកែប្រែឱ្យទៅជាទីសក្ការៈបូជានៃព្រះពុទ្ធសាសនាដែរ។ តួប៉មកណ្តាលទាំងមូលព្រមទាំងភាគផ្សេងៗនៃតួប៉មទាំងបួនដែលអមព័ទ្ធនៅជាន់លើបង្អស់នោះ ត្រូវគ្រប់ដណ្តប់ដោយព្រះពុទ្ធរូបទ្រង់ពែនក្អែនយ៉ាងធំសំបើមមួយអង្គ។ នៅទសវត្ស ១៩៦០ អ្នកស្រាវជ្រាវបារាំងបានរើថ្មមករៀបចំដូចដើមវិញ។



*ប្លង់ក្អែនព្រះពុទ្ធរូបនៅលើថ្នាក់ខ្ពស់បំផុតនៃប្រាសាទភ្នំបាខែង*

វត្តមាននៃព្រះពុទ្ធរូបបរិនិព្វាននៅប្រាសាទបាពួននេះ គឺជាការបញ្ជាក់អំពីវិវត្តដ៏ធំមួយនៅអង្គរ ឬអាច និយាយបានថានៅស្រុកខ្មែរទាំងមូល ក្នុងការកែប្រែប្រាសាទទៅជាព្រះធាតុនេះ។ ជាតឹកតាង គេបានប្រទះជួប នូវវត្តមានតាមបូជនីយដ្ឋាន ដែលកែប្រែព្រះធាតុមួយចំនួន មានតម្កល់ព្រះពុទ្ធរូបបរិនិព្វានដូចជានៅគុកខាងជើង ខេត្តកំពង់ធំ ព្រះធាតុ នៅភូមិរកា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ប្រាសាទភ្នំជើងព្រៃ ខេត្តកំពង់ចាម...។

ចំពោះប្រាសាទអង្គរវត្តវិញ ក៏ត្រូវបានខ្មែរនាសម័យកណ្តាល ដែលគោរពប្រណិបតន៍ពុទ្ធសាសនា បានកែប្រែឱ្យទៅជាទីសក្ការៈបូជាក្នុងពុទ្ធសាសនាវិញ ដោយមានសង់ព្រះពុទ្ធរូបយ៉ាងច្រើនយកមកថ្វាយនៅអង្គរវត្តក្នុងបរិវេណថែវមួយ ដែលក្រោយមកមានគេដាក់ឈ្មោះថា “ថែវព្រះពាន់”។ ឯនៅតួបាកាណរបស់ប្រាសាទអង្គរវត្ត គេយកថ្មទៅសន្ទប់ទ្វារទាំងបួនដោយឆ្លាក់ព្រះពុទ្ធរូបលើផ្ទាំងទ្វារនីមួយៗ។ នេះគឺជាការផ្លាស់ប្តូរទម្រង់នៃសំណង់ប្រាសាទអង្គរពីជំនឿក្នុងព្រហ្មញ្ញសាសនាមកព្រះពុទ្ធសាសនាវិញ។

នៅភាគទី២នៃសតវត្សទី១៦ ខ្មែរខំប្រឹងងើបពង្រឹងអំណាច និងវាតឥទ្ធិពលឡើងវិញដឹកនាំដោយក្សត្រមួយចំនួន ជាពិសេសព្រះបាទចន្ទរាជា។ ព្រះអង្គគង់នៅអង្គរមួយរយៈពេល ដោយមានធ្វើការជុសជុល កែទម្រង់ ព្រមទាំងរចនាបន្ថែមលើប្រាសាទនានាផងដែរ។

**ខ. វត្ត**

វត្ត គឺជាមណ្ឌលសង្គមកិច្ចដ៏ធំសម្រាប់សង្គមខ្មែរទាំងមូល។ មនុស្សចាស់ជរា អ្នកគ្មានទីពឹង និងជនកំសត់ទុរគតទាំងឡាយ យើងតែងតែឃើញថាវត្តអារាមនេះឯងដែលជាទីពឹងទីរលឹក មានមេត្តាករុណាធម៌អាចឱ្យអាស្រ័យទាំងចំណីអាហារ រហូតដល់រក្សាព្យាបាលជម្ងឺតម្កាត់ផ្លូវចិត្តផ្លូវផ្សេងៗផង។ ម្ល៉ោះហើយ ជាទំនៀមពីយូរយារមកហើយ ដែលវត្តអារាមទាំងឡាយកើតឡើងពីកម្លាំងញើសឈាមរបស់អ្នកស្រុកគ្រប់ ជាន់ថ្នាក់ដោយសេចក្តីជ្រះថ្លា ហើយដើម្បីអ្នកស្រុក។ សំណង់ទាំងពួងក្នុងវត្តនីមួយៗតែងកើតឡើងពីសទ្ធារួមគ្នាកសាង ដើម្បីជាប្រយោជន៍ក្នុងផ្លូវជំនឿ បុណ្យកុសលផង ក្នុងផ្លូវ

សង្គមកិច្ចទាំងឡាយផង។ ដោយសារវត្តជាទីសក្ការៈបូជា ទើបសំណង់នានាតែង ធ្វើឡើងដោយការយកចិត្តទុកដាក់ ផ្ចិតផ្ចង់ សម្រិតសម្រាំង ព្រមទាំងគោរពក្បួនខ្នាត ឬយ៉ាងហោចណាស់ក៏ឱ្យសមរម្យ ឬក៏លើសពីសំណង់លំនៅដ្ឋានរបស់អ្នកស្រុកធម្មតាដែរ។ ជាទូទៅ គេច្រើនសាងវត្តនៅលើផ្ទៃដីដែលគេរៀបចំឱ្យរាបស្មើល្អ ហើយវត្តខ្លះស្ថិតនៅកណ្ដាលភូមិ អ្នកស្រុក ឬនៅកន្លែងដែលជាទីទួលខ្ពស់មិនសូវលិចទឹក។ ជាធម្មតាបរិវេណវត្តតែងមានទំហំធំទូលាយ មានដើមឈើធំៗចោលម្លប់ត្រឈឹងត្រឈៃ សម្រាប់ជ្រកក្នុងឱកាសបុណ្យទានផ្សេងៗ និងមានសួនផ្កាភ្ញីល្អៗផង។ តាមទម្លាប់មកគេរៀបចំសំណង់ទាំងឡាយនៅក្នុងវត្តឱ្យមានសណ្ដាប់ធ្នាប់ មានជួរ មានរង ហើយព្រះវិហារដែលជាសំណង់សំខាន់ជាងគេ គឺតាំងនៅកណ្ដាលបរិវេណវត្តទាំងមូល និងទុកទីធ្លាធំទូលាយព័ទ្ធជុំវិញព្រះវិហារ សម្រាប់ធ្វើពិធី ឬសម្រាប់ក្បួនហែប្រទក្សិណក្នុងឱកាសបុណ្យផ្សេងៗ។



*ខឿនព្រះវិហារ (សម័យកណ្ដាលរវាងស.វ.ទី១៥-១៩)*
*ដែលគេយកថ្មប្រាសាទរលំបាក់បែកមករៀបចំនៅមុខប្រាសាទតាខ្ទួតក្នុងអង្គរធំ។*

### គ. សំណង់ព្រះវិហារ

នៅស្រុកខ្មែរ ចាប់ពីស.វទី៦រហូតមកដល់ស.វទី១៤ យើងឃើញមានសេសសល់សំណង់ជាប្រាសាទសព្វបែបយ៉ាងក្នុងក្របខ័ណ្ឌព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយាន។ លុះមកដល់ដើមស.វ.ទី១៤ ខ្មែរចាប់ផ្ដើតជ្រាបខ្លាំងអំពីពុទ្ធសាសនាថេរវាទ ដូចឃើញក្នុងរាជ្យព្រះបាទស្រិន្ទ្រវរ្ម័ន (សោយរាជ្យពីឆ្នាំ១២៩៥ ដល់១៣០៨) មានភស្តុតាងជាក់លាក់ក្នុងសិលាចារឹកភាសាបាលី នៅគោកស្វាយចេក (K.754) ចារនៅឆ្នាំ១៣០៨និយាយពីព្រះបាទស្រិន្ទ្រវរ្ម័ន ត្រាស់បង្គាប់ឲ្យគេកសាងព្រះវិហារ និងព្រះពុទ្ធបដិមា។

ព្រះវិហារនេះឯងហើយដែលជាសំណង់ចាំបាច់សម្រាប់ព្រហពុទ្ធសាសនាថេរវាទ។

បន្តបន្ទាប់ពីស.វទី១៤មកដល់សម័យក្រោយៗទៀត យើងឃើញមានសេសសល់ខឿនព្រះវិហារចាស់ៗជាច្រើន ដែលគេយកថ្មប្រាសាទបុរាណបាក់បែករលំទៅនោះមករៀបចំ។ នៅកន្លែងខ្លះទៀតគេ កសាងព្រះវិហារភ្ជាប់ទៅនឹងប្រាសាទបុរាណក៏មាន ឬមួយរៀបចំបរិវេណប្រាសាទទាំងមូល

ឱ្យទៅជាវត្តអារាមតែម្តង ដូចយ៉ាងអង្គវត្តជាដើម។ ប្រាសាទនិងទីសក្ការៈសម័យបុរាណនានាក្លាយមកជាវត្តអារាម ឬទីបូជាខាងពុទ្ធសាសនាចាប់ពីនោះតរៀងមក។

ព្រះវិហារជាសំណង់សំខាន់សម្រាប់តម្កល់ព្រះបដិមាធំហៅថា "ព្រះអង្គធំ" ដើម្បីព្រះសង្ឃធ្វើកិច្ច ពិធីផ្សេងៗ ដូចជាបួស ធ្វើឧបោសថ ធ្វើពិធីមាឃបូជា ពិសាខបូជា ចូលព្រះវស្សា ចេញព្រះវស្សា ទទួលកឋិនទាន និងសម្រាប់ពុទ្ធបរិស័ទចូលទៅធ្វើសក្ការៈបូជា បន់ស្រន់ជាដើម។ ភាគច្រើនគេសាងព្រះវិហារបែរមុខទៅទិសខាងកើត ដែលជាទិសថ្ងៃរះភ្លឺស្វាងឡើង រុងរឿងឡើង និងជាទិសព្រះអង្គបានត្រាស់ដឹង។

ព្រះវិហារទាំងឡាយ បើកាលណាមានជញ្ជាំងជុំវិញ ហើយមានទ្វារ មានបង្អួចគឺគេច្រើនតែបិទមិនចំហទ្វារបង្អួចនោះរាល់ពេលរាល់វេលាឡើង។ នេះមិនខុសពីប្រាសាទទេ គឺទាល់តែមានការ ទើបគេបើក ទ្វារ បើកបង្អួច ហើយធ្វើកិច្ចពិធីផ្សេងៗនៅចំពោះព្រះភក្ត្រព្រះបដិមា។ គួរជ្រាបដែរថា ជាធម្មតាគេតម្កល់ ព្រះពុទ្ធរូបក្នុងទីដែលស្ងប់ស្ងាត់ និងមិនចេញចូលស្រេចតែចិត្ត ដូចគេទៅទស្សនានោះឡើយ។ ពេលចូលទៅដល់មានកិច្ច អុជធូប អុជទៀន ថ្វាយបង្គំព្រះជាដើម។ ព្រះវិហារក៏មិនមែនជាកន្លែងត្រូវទទួលទានចំណីអាហារ ឬស្នាក់អាស្រ័យឡើយ។

បើយើងពិនិត្យមើលពីការរៀបចំផ្ទៃខាងក្នុងព្រះវិហារនានានៅស្រុកខ្មែរ និងប្រទេសមួយចំនួនក្បែរខាងគ្នានេះ ឃើញថាគេរៀបឱ្យមានល្វែងធំមួយនៅចំកណ្តាល បណ្តោយពីមុខបល្ល័ង្កព្រះ និងមានសសរ ពីរជួរអមសងខាងតាមបណ្តោយ ហើយមានល្វែងនៅអមសងខាងពីក្រៅទៀត។ ការរៀបចំរបៀបនេះគឺដូចគ្នាទៅនឹងប្រភពដើមនៃព្រះវិហារនៅប្រទេសឥណ្ឌាសម័យបុរាណ។

ព្រះវិហារខ្មែរដែលជាសំណង់ឈើ ឬឥដ្ឋបូកបាយអទាំងឡាយនោះ គឺមានទ្រង់ទ្រាយទូទៅតាមលំនាំសំណង់ពីថ្មដែលជាប្រាសាទមានមកតាំងពីសម័យបុរាណ។

នៅស្រុកខ្មែរមានគំរូព្រះវិហារផ្សេងៗច្រើនយ៉ាង តែបើសង្ខេបមកឃើញមាន៤បែបសំខាន់ៗដែលមានសេសសល់មកដល់យើងបច្ចុប្បន្ននេះ។ គេចែកប្រភេទព្រះវិហារទៅតាមរូបរាងនិងការតុបតែងដំបូល។

១. វិហារជហ្វា៤៖ ជាទូទៅព្រះវិហារជហ្វា៤គេច្រើនធ្វើសសរ៦ជួរ បណ្តោយ និងសសរ៩ជួរទទឹង (សរុប៧២សសរ) ឬសសរ១០ជួរទទឹង(សរុប៦០សសរ) ឬសសរ១២ជួរទទឹង (សរុប៧២សសរ) ឬមួយលើសពីនេះទៀតក៏មានដែរ។ ឯដំបូលជាកឹងមានពីរថ្នាក់ ឬ៣ថ្នាក់រាងជ្រាលចុះទៅសងខាង ហើយមានហោជាងមុខ និងហោជាងក្រោយ ព្រមទាំងមានជហ្វា២នៅចុងព្រំដំបូលខាងមុខ និងជហ្វា២ទៀតនៅចុងព្រំដំបូលខាងក្រោយ។ នៅគល់ហោជាងខាងមុខមានដំបូលហប់រាងជ្រាលចុះមកខាងមុខ១ថ្នាក់ ឬ ២ថ្នាក់ ឬមួយ៣ថ្នាក់ និងនៅគល់ហោជាងខាងក្រោយមានដំបូលហប់ជ្រាលចុះទៅក្រោយ១ថ្នាក់ ឬ២ថ្នាក់ ឬមួយ៣ថ្នាក់ ដែរ។ តាមដែលខ្ញុំធ្លាប់សង្កេតមកឃើញថា បើវិហារណាមានដំបូល២ថ្នាក់ គឺគេធ្វើ ដំបូលជ្រាល់ទៅមុខនិងក្រោយនោះតែ១ថ្នាក់ បើវិហារមានដំបូល៣ថ្នាក់

ខ្លះគេធ្វើដំបូលមុខក្រោយនោះ១ នោះ១ថ្នាក់ ឬធ្វើ២ថ្នាក់ក៏មានដែរ។ បើវិហារដំបូល៤ឬ៥ថ្នាក់គេធ្វើដំបូលទៅមុខ និងទៅក្រោយ៣ឬ៤ថ្នាក់ ទៅតាមនោះ។

ព្រះវិហារជហ្វា៤របៀបនេះ មានអ្នកខ្លះថា "វិហារបុរាណ" ត្បិតនៅរវាងមួយសតវត្សកន្លងទៅ និងមុនៗនោះទៀត គេនិយមសាងសង់ព្រះវិហារបែបនេះ។ វិហារជហ្វា៤មានទំហំតូចច្រឡឹង ទាបល្មមងាយសង់ ប្រើធនធានមិនសម្បើមខ្លាំងពេក ហើយងាយស្រួលក្នុងការថែទាំជួសជុល ព្រមទាំងសមតាមសេចក្តី ត្រូវការជាក់ស្តែងរបស់អ្នកស្រុកជាចំណុះជើងវត្តនៅតាមភូមិនានា។ ព្រះវិហារបែបនេះបង្ហាញពីភាពស្រគត់ស្រគំ មិនស្វែងអស្ចារ្យពេក។ រីឯទំហំ កម្ពស់ ទ្រង់ទ្រាយទូទៅគឺប្លែកៗគ្នាទៅតាមការច្នៃប្រឌិត។

២. វិហារជហ្វាង៦ ៖ ជាទូទៅមានសសរ៦ជួរបណ្តោយ និងសសរ៩ជួរទទឹង (សរុប៥៤សសរ) ឬសសរ១០ជួរទទឹង (សរុប៦០សសរ) ឬសសរដំបូលកិងមាន២ថ្នាក់ ៣ថ្នាក់ ៤ថ្នាក់ ឬ៥ថ្នាក់ រាងជ្រាលចុះទៅសងខាង ហើយមានជហ្វា៣នៅចុងព្រំដំបូលខាងមុខ និងជហ្វា៣ទៀតនៅចុងព្រំដំបូលខាងក្រោយ មានហោជាងមុខនិងហោជាងក្រោយ។ នៅគល់ហោជាងខាងមុខនិងខាងក្រោយមានដំបូលហប់តាងជ្រាលចុះ ទៅមុខនិងទៅក្រោយ១ថ្នាក់ ឬធ្វើមុខដាច់ឥតដំបូលហប់មុខនិងហប់ក្រោយ ខ្លះមានដំបូលមុខនិងក្រោយ ២ថ្នាក់ ៣ថ្នាក់ ឬ៤ថ្នាក់។ វិហារខ្លះធ្វើជញ្ជាំងជាប់នឹងសសរបាំងសាចតែម្តង ឯវិហារខ្លះទុកសសរបាំងសាច ដូចវិហារជហ្វា៤ដែរ។

៣. វិហារមណ្ឌប ៖ ជាព្រះវិហារមានខឿននិងជញ្ជាំងស្ទើរដូចនឹងវិហារជហ្វា៤ ឬវិហារ៦ដែរ គ្រាន់តែមានកំពូលបុស្បុកស្រួចនៅលើដំបូល។ វិហារមណ្ឌបមានជហ្វារវាង១០ទៅ១៦ តែភាគច្រើនមានជហ្វា១២ គឺ ផ្នែកខាងមុខ៤ ផ្នែកខាងក្រោយ៤ និងខាងស្តាំ២ ខាងឆ្វេង២។ ប៉ុន្តែមានវិហារមណ្ឌបខ្លះគេមិនដាក់ហោជាង និងជហ្វានៅផ្នែកចំហៀងសងខាងក៏មានដែរ គ្រាន់តែពុំសូវសមភ្នែក។

៤. វិហារត្រឡែងកែង៖ ជាព្រះវិហារមានមុខលយបែរទៅទិសធំៗទាំង៤ (អ្នកខ្លះហៅថាវិហារមុខ៤) ដែលខ្លះមានកំពូលបុស្បុកស្រួចនៅលើដំបូលចំកណ្តាល ហើយមានជហ្វា២ទៅ៤នៅចុងព្រំដំបូលមុខ នីមួយៗនៃទិសទាំង៤ ដែលសរុបមានជហ្វា៨ទៅ១៦។ នៅក្នុងវិហារបែបនេះគេច្រើនតម្កល់ព្រះបដិមា ដែលបែរព្រះភ័ក្ត្រទៅទិសទាំង៤ ដូចទៅនឹងប្រាសាទបុរាណមួយចំនួនដែរ។ តែព្រះវិហារត្រឡែងកែងខ្លះ ទៀតក៏មានគេតម្កល់ព្រះបដិមាបែរទៅទិសណាមួយ (ពិសេសបែរទៅទិសខាងកើត) ដូចក្នុងព្រះវិហារផ្សេងៗទៀតដែរ។ ព្រះវិហារត្រឡែងកែងមានមណ្ឌប គឺមានទ្រង់ទ្រាយដូចនឹងប្រាសាទបុរាណមួយចំនួន។

សំណង់វត្តអារាមកើតមានយ៉ាងព្រោងព្រាតនៅស្រុកខ្មែរ ក្នុងនោះវិវត្តន៍ដ៏សំខាន់ និងគួរឱ្យចាប់អារម្មណ៍គឺសំណង់ "វត្តត្រឡែងកែង"។



*វត្តត្រឡែងកែង*

ព្រះវិហារនេះមានទីតាំងស្ថិតនៅក្នុងបន្ទាយលង្វែក ដែលមានភូមិសាស្ត្រសព្វថ្ងៃស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង។ ព្រះវិហារនេះទម្រង់ស្ថាបត្យកម្មប្រាំងដែលមានប្លង់ជាការ៉េ៤ជ្រុងស្មើ មានមុខលយបែរទៅទិសធំៗទាំងបួន (អ្នកខ្លះហៅថា វិហារមុខ៤) ដែលមានកំពូលបុស្បុកស្រួចនៅដំបូលកណ្ដាល ហើយមានជហ្វា២ទៅ៤នៅចុងព្រំដំបូលមុខនីមួយៗនៃទិសទាំង៤ ដែលសរុបមានជហ្វា៨ទៅ១៦។



*ព្រះពុទ្ធរូបត្រឡែងកែង*

នៅក្នុងវិហារបែបនេះ គេច្រើនតម្កល់ព្រះបដិមាដែលបែរព្រះភ័ក្ត្រទៅទិសទាំង៤ ដូចទៅនឹងប្រាសាទបុរាណមួយចំនួនដែរ។ ព្រះវិហារត្រឡែងកែងនេះ មានមណ្ឌប គឺមានទ្រង់ទ្រាយដូចនឹងប្រាសាទបុរាណមួយចំនួនផងដែរ។

**ឃ. ចេតិយ**

ចេតិយជាសំណង់មានខឿន មានអង្គ (ខ្លួន) មានកំពូល ហើយមានសណ្ឋានផ្សេងៗ និងមានការតុបតែងរចនាទៅតាមប្រភេទច្រើនយ៉ាង។ ចេតិយប្រើសម្រាប់បញ្ចុះធាតុអ្នកស្លាប់ ឬឧទ្ទិសទៅអ្វីមួយ ឬមួយសម្រាប់តម្កល់វត្ថុសក្ការៈ។ ចេតិយមានតួនាទីនិងអត្ថន័យដូចប្រាសាទបុរាណមួយចំនួនដែរ គឺគេទុក ដូចជាភ្នំព្រះសុមេរុដែលជាស្ថានទេពនៅកណ្តាលចក្រវាលឬលោកធាតុ។ គេឧទ្ទិសឱ្យអ្នកស្លាប់ដែលគេបញ្ចុះធាតុទីនោះបានទៅដល់ "សុគតិភព" ដែលជាទេវស្ថាន ឬទេវលោក។

អ្នកស្រាវជ្រាវទាំងឡាយយល់ឃើញថា ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានចេតិយនេះ គឺប្រភពដើមនៅប្រទេសឥណ្ឌាបុរាណហើយបន្តទៅប្រទេសស្រីលង្កា និងជះឥទ្ធិពលមកប្រទេសនានា។ ឯខ្មែរក៏មានចេតិយប្រហែលពីស.វទី១៥រហូតមក និងមានរាងប្លែកៗច្រើនយ៉ាងតាមកាលវេលា។ តាមយោបល់ខ្លះគេយល់ថា ចេតិយមានមុខងារផ្សេងៗគ្នា៤យ៉ាង៖

១. ធាតុចេតិយ៖ ជាចេតិយសម្រាប់បញ្ចុះធាតុ។

២. ធម្មចេតិយ៖ ជាចេតិយសម្រាប់តម្កល់គម្ពីរ ក្បួន ច្បាប់ វិន័យ ធម៌អាថ៌ សាស្ត្រាផ្សេងៗ។

៣. បរិភោគចេតិយ៖ ជាចេតិយបញ្ចុះគ្រឿងបរិក្ខាររបស់ព្រះ ឬព្រះសង្ឃដែលខ្ពង់ខ្ពស់ ឬក៏ស្បង់ចីពរ ចាស់ៗរបស់ព្រះសង្ឃ។

៤. ឧទ្ទេសិកចេតិយ៖ ជាចេតិយសម្រាប់គេគោរពបូជា ដូចព្រះ ឬសម្រាប់ឧទ្ទិសទៅអ្វីផ្សេងៗជាទីសក្ការៈ។

រូបរាងទូទៅនៃចេតិយនៅស្រុកខ្មែរមានវិវឌ្ឍហូរហែតាំងតែពីសម័យកណ្តាលមក គឺរវាងស.វ.ទី១៥-១៦មកដល់សព្វថ្ងៃ។

គេចែករូបរាង ឬការតុបតែងចេតិយជា៣ប្រភេទ៖

១. ចេតិយលាត៖ ជាចេតិយពុំមានក្បាច់តុបតែងលម្អិតនៅផ្នែកផ្សេងៗឡើយ គឺមានខឿនមានតួខ្លួន និងមានកំពូល ហើយគេរចនាជាល្បាក់គន្លាក់ៗ នៅតាមជាន់ថ្នាក់នានា ឬមានសារពើសូត្រនៅតាមកែងនៃខឿនចេតិយនោះ។ ចេតិយបែបនេះសម្រាប់បញ្ចុះធាតុមនុស្សម្នាទាំងពួង។ មានចេតិយលាតខ្លះ ក៏មានច្នៃរចនាថែមសង្វារខ្វែងនៅលើអង្គហើយមានត្របកឈូកផ្កាប់នៅលើស្មា ឬមានល្បាក់រាងគន្លាក់ៗច្រើននៅតាមជាន់ថ្នាក់នានា ហើយមានជើងកោស១ឬ២ជាន់ខ្លះដែរ។

២. ចេតិយក្បាច់៖ ជាចេតិយមានក្បូរក្បាច់រចនាលម្អិតនៅតាមផ្នែកនានា។ អ្នកខ្លះយល់ថា ចេតិយក្បាច់បែបនេះសម្រាប់បញ្ចុះធាតុព្រះសង្ឃ ព្រះរាជវង្សានុវង្ស ឬអ្នកមានបណ្តាសក្តិជាដើម។ ប៉ុន្តែក៏មានអ្នកសម្បូណ៌ទ្រព្យធនខ្លះ ក៏អាចសាងចេតិយក្បាច់សម្រាប់បញ្ចុះធាតុក្រុមគ្រួសារបានដែរ។

ចេតិយក្បាច់ដែលមានការតុបតែងលម្អច្រើន និងមានទំហំធំខ្ពស់ មើលទៅសម្បើមគួរស្ញែងបង្ហាញពីឥស្សរភាពឧត្តុង្គឧត្តម គឺច្រើនសម្រាប់តម្កល់ព្រះមហាក្សត្រ។



*ក្បាច់លម្អ នៅលើចេតិយព្រះអង្គដួង*

៣. ចេតិយទ្រង់គ្រឿង៖ ជាចេតិយមានក្បាច់រចនា មានសង្វារខ្វែងនៅលើអង្គ(ខ្លួន) ហើយមានព្រះភ័ក្ត្រ ព្រះព្រហ្ម និងមានកំពូលស្រួច ឬមានឆ័ត្ររួត(៣រួត ឬ៥រួត) នៅខាងលើ។ ចេតិយទ្រង់គ្រឿងដែលមានការតុបតែងលម្អច្រើន និងមានទំហំធំ ខ្ពស់ ហើយលើកំពូលមានរាងស្រួច ឬមានឆ័ត្ររួច៧ថ្នាក់ គឺច្រើន ប្រើសម្រាប់តម្កល់ព្រះអដ្ឋិព្រះមហាក្សត្រ។ ចំពោះព្រះរាជវង្សានុវង្ស និងព្រះសង្ឃជាដើមច្រើនដាក់ឆ័ត្ររួតតែ៥ថ្នាក់។ រីឯអ្នកស្រុកទូទៅគេច្រើនដាក់ឆ័ត្ររួតតែ៣ថ្នាក់ ឬអាចដាក់៥ថ្នាក់បានដែរ។ គួរជ្រាបដែរថា ចេតិយលាត និងចេតិយក្បាច់ខ្លះក៏មានដាក់ព្រះភ័ក្ត្រព្រះព្រហ្មដែរ។



*ចេតិយព្រះបាទស៊ីសុវត្ថិ*

និយាយពីឧដុង្គជាអតីតរាជធានីនាសតវត្សទី១៧ (ពីឆ្នាំ១៦១៨ ដល់ឆ្នាំ១៨៦៦) ហើយត្រូវបានបោះបង់ចោលដោយព្រះបាទនរោត្តម នៅឆ្នាំ១៨៦៦។ ដោយផ្លាស់រាជធានីទៅកាន់រាជធានីភ្នំពេញរហូតដល់សព្វថ្ងៃ។ ក្រុងឧដុង្គចាប់កសាងឡើងក្នុងសតវត្សរ៍ទី១៧ ក្នុងរជ្ជកាល ព្រះបាទ សម្តេចព្រះជ័យជេដ្ឋាទី២ ក្នុងពុទ្ធសករាជ២១៦៤ នៃគ្រិស្តសករាជ១៦២០។ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាស្តេចគង់នៅ ព្រះរាជវាំង ល្វាឯម ទ្រង់បាននាំសេនាបតី និងនាម៉ឺនសព្វមុខមន្ត្រីចុះ ព្រះរាជទីនាំងនាវាស្តេចយាងទៅប្រពាតនៅ តំបន់អូរក្រុងលាយក្នុងខេត្ត។ ទ្រង់ប្រថាប់នៅ ព្រះពន្លាជាយូរថ្ងៃ រួចស្តេចយាង ទៅក្រសាលនៅតាដុងយាយជ័យ ទ្រង់ក៏ទតឃើញទីទួលមួយនៅ តំបន់ស្រះកែវ ជាទីមានទេសភាពល្អក៏ទ្រង់ចាប់ព្រះទ័យ។ ហើយទ្រង់មានព្រះតម្រាស់ជាមួយមន្ត្រី មានហោរាធិបតីជាដើមថា យើងចង់សាងព្រះរាជវាំងគង់នៅទីនេះ តើអស់អ្នកទាំងពួងយល់ថាម្តេច? ឧកញ្ញាហោរាធិបតីមុំ គន់គូរពិនិត្យមើលទីដីនោះដោយក្បួនហោរាសាស្ត្រហើយក្រាបបង្គំទូលថា "ទីនេះជាទីជយភូមិល្អណាស់ត្រូវតាមក្បួនទាយថា នឹងមានឫទ្ធិតេជះ ឈ្នះអស់សត្រូវទាំង៨ទិស"។ ព្រះរាជាទ្រង់ជ្រាបដូច្នោះ ក៏ចាត់ឧកញ៉ាក្រឡា-ហោមកែវ ឱ្យជានាយកចាត់ការកសាងព្រះរាជវាំងនៅតំបន់ស្រះកែវនេះ នៅថ្ងៃ៥កើតខែផល្គុណ ឆ្នាំវក ទោស័កពុទ្ធ-សករាជ២១៦៤ គ្រិស្តសករាជ១៦២០។ ស្តេចបានតាំងព្រះនាមព្រះនគរ (ទីក្រុង) ថ្មីនោះថា ព្រះបរមរាជវាំងមហានគរឧដុង្គមានជ័យបុរីរម្យឧត្តមរាជនិវេសនដ្ឋាន ដែលហៅខ្លីថា ក្រុងឧដុង្គមានជ័យ។

ចំពោះនៅជុំវិញតំបន់និងនៅលើភ្នំឧដុង្គ (គិតពីទិសខាងជើងមកទិសខាងត្បូង) ទាំងមូលមានចេតិយមួយចំនួនដូចជា៖

- ចេតិយព្រះចន្ទរាជា
- ចេតិយព្រះសត្ថា
- ចេតិយព្រះអង្គអេង
- ព្រះសក្យមុនីចេតិយ
- ចេតិយព្រះស្រីសុរិយោពណ៌
- ចេតិយព្រះអង្គចន្ទ
- ចេតិយព្រះអង្គដួង
- ចេតិយព្រះស៊ីសុវត្ថិ
- ចេតិយរាជវង្ស




*ប្លង់នៃចេតិយនៅលើភ្នំឧដុង្គ*

ចេតិយដែលមានក្បូរក្បាច់ហាក់ស្អាតបាត នៅឡើយចេតិយធំៗទាំង៣ ស្ថិតលើកំពូលភ្នំឧត្តុង្គជ្រុងខាងជើង ត្រូវបានគេហៅថា "ចេតិយត្រៃត្រិង្ស"។ ចេតិយត្រៃត្រិង្សស្ថិតនៅខាងឆ្វេងដៃក្បែរព្រះសក្យមុនីចេតិយទើបធ្វើថ្មីនោះ គឺឃើញមានចេតិយធំៗពីរនៅក្បែរគ្នា។



ចេតិយត្រៃត្រិង្ស



ចេតិយសាមពាន់

ចំពោះចេតិយខាងជើងមានឆ្លាក់រូបដំរី លេចក្បាលផ្លោឡើងប៉ុនដំរីមែនទែន គេហៅថា "ចេតិយសាមពាន់" ត្រូវបានកសាងឡើងតាំងពីគ្រិស្តសករាជ១៦២៣ ដោយព្រះបាទជ័យជេដ្ឋា ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃ ព្រះបាទស្រីសុរិយោពណ៌ ជាព្រះរាជបិតា។



ចេតិយព្រះចន្ទរាជា



ចេតិយព្រះអង្គអេង



*ចេតិយព្រះសត្ថាទី១*



*ចេតិយព្រះអង្គចន្ទ*



*ចេតិយនៅក្រោយចេតិយទន្ទឹម*



*ចេតិយនៅមុខព្រះគោព្រះកែវ*

ចេតិយខាងត្បូងកសាងឡើងក្នុងគ្រិស្តសករាជ១៨៩១ ដោយព្រះបាទសម្តេចព្រះនរោត្តម ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទសម្តេចព្រះអង្គដួង ជាព្រះវររាជបិតា។





*ចេតិយព្រះបាទអង្គដួង* *ព្រះចេតិយហ្លួងខត្តិយកោដ្ឋព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស*

ចុះតាមជណ្តើរថ្មទៅត្បូងបន្តិច គេនឹងឃើញចេតិយដ៏ធំមួយទៀតដែលជាចេតិយរបស់ព្រះករុណាព្រះខត្តិយកោដ្ឋព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស។

## ខ. ប្រាង្គ

ប្រាង្គ ជាសំណង់ដែលមានខឿនច្រើនជាន់ មានជណ្តើរឡើងខ្ពស់ មានតួខ្លួន(អង្គ) មានកំពូល និងមានទំហំធំ ហើយមានការតុបតែងរចនាច្រើនផង។ ប្រាង្គប្រើសម្រាប់តម្កល់ធាតុអ្នកស្លាប់ ឬឧទ្ទិសទៅអ្វីមួយ ឬមួយសម្រាប់តម្កល់វត្ថុសក្ការៈ។ ប្រាង្គមានតួនាទី និងអត្ថន័យដូចប្រាសាទបុរាណមួយចំនួនដែរ គឺទុកដូចជាភ្នំព្រះសុមេរុ ដែលជាស្ថានទេពនៅកណ្តាលចក្រវាលឬលោកធាតុ ព្រោះគេឧទ្ទិសឱ្យអ្នកស្លាប់ ដែលតម្កល់ធាតុនៅទីនោះបានទៅដល់ "សុគតិភព" គឺទេវស្ថាន។

អ្នកខ្លះគេបែងចែករូបរាងប្រាង្គជា៣បែប គឺប្រាង្គប្រាសាទ ប្រាង្គចេតិយ ប្រាង្គស្តូប។ ប្រាង្គទាំងនេះសុទ្ធតែមានខឿននិងជណ្តើរឡើង ហើយខ្ពស់ទៅលើ។ ការតុបតែងប្រាង្គ គឺទៅតាមប្រភេទនីមួយៗប្លែកគ្នា។

១. ប្រាង្គប្រាសាទៈ ជាប្រាង្គមានរាងដូចប្រាសាទបុរាណ និងមានការតុបតែងក្បាច់រចនាច្រើនស្មុកស្មាញ (ពិសេសក្បាច់អង្គរ)។ ប្រាង្គរបៀបនេះគេច្រើនដកស្រង់រូបរាងមកពីប្រាង្គកណ្តាលនៃប្រាសាទសម័យអង្គរដូចជាប្រាសាទបាគង ប្រាសាទបន្ទាយស្រី ប្រាសាទអង្គរវត្តជាដើម។ ប្រាង្គប្រាសាទច្រើនប្រើសម្រាប់តម្កល់ ព្រះអដ្ឋិព្រះមហាក្សត្រ ឬព្រះអដ្ឋិសម្តេចព្រះសង្ឃរាជ ឬមួយឥស្សរជនជាដើម។

២. ប្រាង្គចេតិយ ៖ ជាប្រាង្គមានខឿន មានជណ្ដើរឡើងខ្ពស់ មានរូបរាងខាងលើជាចេតិយ។ ប្រាង្គរបៀបនេះ គេច្រើនប្រើសម្រាប់តម្កល់ព្រះអដ្ឋិព្រះចៅអធិការវត្ត ឬព្រះសង្ឃដែលមានកិត្តិនាមខ្ពង់ខ្ពស់។ រីឯជាតុអ្នកមានបណ្ដាសក្ដិខ្ពស់ខ្លះ ក៏មានប្រើប្រាង្គចេតិយសម្រាប់បញ្ចុះដែរ។

ការរចនាតុបតែងនៅប្រាង្គចេតិយ គឺច្រើនតែដូចទៅនឹងចេតិយដែរ គ្រាន់តែប្រាង្គនោះមានខឿនច្រើនជាន់ឬខ្ពស់ឡើងទៅលើ។

៣. ប្រាង្គស្ដូបៈ ជាប្រាង្គមានខឿនខ្ពស់ មានជណ្ដើរឡើង ហើយខាងលើមានសណ្ឋានប្លែកៗយ៉ាងច្រើន ទៅតាមការច្រើនទៅតាមការច្នៃប្រឌិតផ្សេងៗ ខ្លះរាងគោល ខ្លះរាងមណ្ឌល ។ល។ ប្រាង្គរបៀបនេះ គេច្រើនប្រើសម្រាប់តម្កល់ព្រះអដ្ឋិព្រះចៅអធិការវត្ត ឬព្រះសង្ឃចាស់ទុំ។ ប្រាង្គស្ដូបនេះក៏មានប្រើប្រាស់សម្រាប់ឧទ្ទិសទៅអ្វីផ្សេងៗក៏មានដែរ។

នៅលើផ្នែកផ្សេងៗនៃប្រាង្គដែលមានរូបរាងជាប្រាសាទ តែងមានពាក្យហៅទៅតាមទម្លាប់របស់ជាង និងអ្នកស្រុកនានាដែរ។ ពាក្យហៅចំណុចទាំងឡាយលើប្រាង្គនោះអាចដូចគ្នាឬខុសគ្នាខ្លះៗពីតំបន់មួយទៅតំបន់មួយ។ នៅខាងក្រោមនេះជាឧទាហរណ៍មួយដែលលោក Carbonnel Jean-Piere បានសិក្សាចុងក្រោយ និងបោះពុម្ពផ្សាយកាលពីឆ្នាំ១៩៧៣ អំពីពាក្យហៅផ្នែកផ្សេងៗនៅលើប្រាង្គ ហើយខ្ញុំយកមកដាក់ឲ្យទៅជាអក្សរខ្មែរវិញ។

នៅលើផ្នែកផ្សេងៗនៃប្រាង្គដែលមានរូបរាងជាប្រាសាទ តែងមានពាក្យហៅទៅតាមទម្លាប់របស់ជាង និងអ្នកស្រុកនានាដែរ។ ពាក្យហៅចំណុចទាំងឡាយលើប្រាង្គនោះ អាចដូចគ្នា ឬខុសគ្នាខ្លះៗពីតំបន់មួយទៅតំបន់មួយ។



*ចេតិយនៅក្នុងបរិវេណអង្គរវត្ត ប្រហែលសាងនៅឆ្នាំ១៧០២ ដោយជ័យនន្ទ*

## ៣. ស្ថាបត្យកម្ម និងសំណង់សម័យក្រោយលង្វែក-ឧដុង្គ

### ក. សម័យបារាំង

ចាប់តាំងពីបារាំងបានដាក់អាណានិគមមកលើកម្ពុជា អស់រយៈពេលជិតមួយទសវត្ស (១៨៦៣ដល់១៩៥៣) ហើយនៅក្នុងដំណាក់កាលដំបូងនៃការដាក់មូលដ្ឋានគ្រប់គ្រងលើប្រទេសកម្ពុជា បារាំងបានប្រឈមជាមួយនឹងចលនាបះបោរជាច្រើន ដែលប្រឆាំងនឹងវត្តមានរបស់ បារាំងដែលត្រួតត្រាដាក់អាណានិគមលើប្រទេសកម្ពុជា។ ក្តីសង្ឃឹមរបស់អ្នកដឹកនាំខ្មែរព្រមទាំងប្រជារាស្ត្រ ដែលតែងតែសង្ឃឹមថាវត្តមានបារាំងនឹងជួយកម្ពុជាឲ្យរំដោះបានខេត្តខ្មែរមួយចំនួនដែលបានបាត់បង់ទៅខាងសៀម ក៏ដូចជាការជួយរៀបចំកម្ពុជាឲ្យមានសន្តិភាព និងការអភិវឌ្ឍឡើងវិញ ហាក់ដូចជាស្ថិតនៅក្នុងការរង់ចាំមួយដ៏អន្ទះសារ។ នៅឆ្នាំ១៨៨៤ ក៏ជាសម័យនៃការផ្លាស់ប្តូរមួយនៅកម្ពុជាផងដែរ។ អស់រយៈពេលប្រហែល២០ឆ្នាំ បារាំងបានព្យាយាមបញ្ចុះបញ្ចូលស្តេច នរោត្តម ដើម្បីធ្វើការផ្លាស់ប្តូរដែលបារាំងចង់បាន។ នោះគឺជាការលុបបំបាត់របបទាសភាព ធ្វើកម្មសិទ្ធិ ដីធ្លីឯកជន ធ្វើម្ឋការហិរញ្ញវត្ថុ និងរៀបចំពន្ធដារឡើងវិញ។ ប៉ុន្តែស្តេចនរោត្តមបានតវ៉ា ដោយនិយាយថា ការផ្លាស់ប្តូរបែបនេះ គឺជាការប្រឆាំងទៅនឹងប្រពៃណី និងបណ្តាលឱ្យមានចលាចល។ ដោយពុំសូវទទួលបានការគាំទ្រពីព្រះបាទនរោត្តម បារាំងក៏សម្រេចចិត្តធ្វើការសន្សឹមៗរហូតដល់ព្រះអង្គសោយទីវង្គត។ ពួកបារាំងយល់ថា ព្រះអនុជរបស់ព្រះបាទ នរោត្តម ដែលមានព្រះនាមថា ស៊ីសុវត្ថិ គឺជាអ្នកគាំទ្របារាំង នឹងថាប្រសិនបើព្រះអង្គម្ចាស់ស៊ីសុវត្ថិឡើងសោយរាជ្យបន្ទាប់ ក្រោយពីការសោយទីវង្គតរបស់ព្រះបាទ នរោត្តម ព្រះអង្គប្រាកដជាយល់ព្រមចំពោះការកែទម្រង់ទាំងអស់របស់បារាំង។

ចំពោះការស្ថាបនាព្រះបរមរាជវាំងចុងក្រោយ បានរៀបចំឡើងនៅភ្នំពេញ ចំនួន២លើក គឺលើកទី១ ក្នុងឆ្នាំ១៨៣៤ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត និងលើកទី២ ក្នុងឆ្នាំ១៨៦៦ ក្នុងរាជ្យព្រះបាទនរោត្តម និងត្រូវរុះរើសាងសង់ជាថ្មី នៅឆ្នាំ ១៩១៣ ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិ រហូតមកដល់សព្វថ្ងៃ ដែលមានឈ្មោះថា ព្រះបរមរាជវាំងចតុមុខមង្គល ដោយស្ថិតនៅត្រង់ចំណុចប្រសព្វនៃទន្លេទាំងបួន គឺមានទន្លេមេគង្គលើទន្លេមេគង្គក្រោម ទន្លេបាសាក់ និងទន្លេសាប។ ព្រះបរមរាជវាំង សាងសង់បែរមុខទៅទិសខាងកើត គឺបែរទៅរកទន្លេចតុមុខ។





*ទិដ្ឋភាពព្រះបរមរាជវាំងនៃព្រះរាជាណាចក្រកម្ពុជា*

សារមន្ទីរជាតិកម្ពុជា បានចាប់បដិសន្ធិក្រោមការផ្តួចផ្តើមគំនិតដោយប្រវត្តិវិទូ George Groslier នៅឆ្នាំ១៩១៧ ដែលកាលនោះមានឈ្មោះថាសាលាសិល្បៈកម្ពុជា បន្ទាប់មកសាលានេះក៏ប្រែក្លាយជាសារមន្ទីរជាតិកម្ពុជានៅឆ្នាំ១៩១៩។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩២០ ពិធីសម្ពោធសារមន្ទីរជាតិកម្ពុជា ក៏បានប្រព្រឹត្តិ ឡើងក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ព្រះបាទស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជា ហើយក៏បានប្តូរឈ្មោះពីសារមន្ទីរជាតិកម្ពុជាមកជា សារមន្ទីរ អាល់បឺតសារូត (Albert Sarraut) ដែលលោកជាអគ្គទេសាភិបាលឥណ្ឌូចិននាសម័យអាណានិគមបារាំង។ អគារសារមន្ទីរទាំងមូល ត្រូវបានរចនាតាមស្ថាបត្យកម្មប្រាសាទបុរាណខ្មែរ ដែលបានដាក់តាំងវត្ថុបុរាណជាង ១៤,០០០ ប្រភេទ ជាស្នាដៃសិល្បៈខ្មែរ ដ៏អស្ចារ្យបំផុតលើពិភពលោករួមមាន៖ រូបចម្លាក់ សេរ៉ាមិក សំរិទ្ធ និងវត្ថុបុរាណដែលមានតាំងពីមុនសម័យបុរេប្រវត្តិ រហូតដល់មុនកំឡុងពេលនិងក្រោយពេលអាណាចក្រខ្មែរ។




*រូបភាពពិធីសម្ភោធសារមន្ទីរ* ***Albert Sarraut*** *ឆ្នាំ១៩២០*



*រូបភាពសារមន្ទីរជាតិនាបច្ចុប្បន្ន*

ផ្សារធំថ្មីត្រូវបានសាងសង់ក្នុងខែសីហា ឆ្នាំ១៩៣៥ ហើយត្រូវបានបញ្ចប់រួចរាល់នៅខែ មិថុនា ឆ្នាំ១៩៣៧ ក្រោមជំនួយរបស់សាធារណរដ្ឋបារាំង ក្នុងរជ្ជកាលគ្រប់គ្រងរាជសម្បត្តិដោយព្រះករុណាព្រះបាទស៊ីសុវត្ថិ មុនីវង្ស។

អ្នកគូរប្លង់ផ្សារធំថ្មី គឺជាជនជាតិបារាំងឈ្មោះ JEAN DUBOIR ហើយសាងសង់ដោយក្រុមហ៊ុន(ឥណ្ឌូចិនសាយហ្គន)។



*ផ្សារធំថ្មី*

ដំបូងឡើយ ប្រព័ន្ធផ្លូវដែករបស់ប្រទេសកម្ពុជា ត្រូវបានកសាងឡើងដោយរដ្ឋអំណាចអាណានិគមបារាំងនៅទសវត្សឆ្នាំ១៩៣០។ ផ្លូវដែកទី១ "ភាគខាងជើង" មានប្រវែង៣៨៦គីឡូម៉ែត្រ ភ្ជាប់ទីក្រុងភ្នំពេញទៅនឹងទីប្រជុំជនប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ ជាប់ព្រំដែនប្រទេសថៃ កាត់តាមខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ នៅឆ្នាំ១៩៤២ ផ្នែកចុងក្រោយនៃផ្លូវដែកនេះ ត្រូវបានតភ្ជាប់ជាមួយនឹងបណ្ដាញផ្លូវដែករបស់ប្រទេសថៃ។



*ស្ថានីយអយស្ម័យានភ្នំពេញ*

## ខ. សម័យសង្គមរាស្ត្រនិយម

ក្រោយពេលការទាមទារឯករាជ្យបានទាំងស្រុង ពីអាណានិគមន៍បារាំងនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ត្រូវបានបានកសាងឡើង និងសម្ពោធដាក់ឲ្យប្រើប្រាស់ នៅឆ្នាំ១៩៥៨ ក្នុងរាជ្យព្រះបាទ នរោត្តម សុរាម្រិត (១៩៥៥-១៩៦០) ព្រះរាជបិតា សម្តេចព្រះ នរោត្តម សីហនុ។

វិមានឯករាជ្យសាងសង់ឡើង ដើម្បីជានិមិត្តរូបបញ្ជាក់ថា ប្រទេសកម្ពុជា បានទទួលឯករាជ្យពី ប្រទេសបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ និងសម្រាប់ជាស្តូបគោរពវិញ្ញាណក្ខ័ន្ធ អ្នកស្លាប់ ដើម្បី បុព្វហេតុជាតិ និងដើម្បីប្រារព្ធនូវសេរីភាព និងឯករាជ្យរួចពីការគ្រប់គ្រងរបស់បរទេស។

វិមានឯករាជ្យ រចនាប្លង់ (គូរប្លង់) ដោយស្ថាបត្យករខ្មែរដ៏ល្បីល្បាញ គឺលោក វណ្ណ មូលីវណ្ណ មានកម្ពស់២០ ម៉ែត្រ មាន ៥ជាន់ ដោយយកលំនាំតាមរាងផ្កាឈូកក្រពុំ តាមគំរូរចនាបថរបស់អង្គរ លំអដោយក្បាលពស់នាគរាជចំនួន១០០ (១ជាន់២០, ១ជ្រុង៥) ដែលរំលេចចេញយ៉ាងច្បាស់នូវម៉ូដ (រចនាបថ) របស់ប្រាង្គប្រាសាទអង្គរវត្ត។ ចំណែកអ្នកកសាងវិមានឯករាជ្យ តាមប្លង់របស់លោក វណ្ណ មូលីវណ្ណ គឺលោក តឹង វឿត ជាស្ថាបត្យករដ៏ល្បីល្បាញ។



*សម្តេចព្រះបាទ នរោត្តម សីហនុ ក្នុងពិធីបុណ្យឯករាជ្យ*



*វិមានឯករាជ្យ*

គ្រឹះស្ថានសិក្សាមួយគឺសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលទទួលបាននូវភាពល្បីល្បាញស្ទើរតែគ្រប់ជំនាន់សម្រាប់ប្រជាពលរដ្ឋខ្មែរ ពិសេសសិស្សនិស្សិតបានចាត់ទុកទីនេះថាជាគ្រឹះស្ថានបណ្តុះបណ្តាលសំខាន់មួយក្នុងការស្វែងរកអនាគតដ៏ជាក់លាក់ ប្រកបដោយក្តីសង្ឃឹមក្នុងជីវិត។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាសមិទ្ធផលនៃសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) ដែលបានស្ថាបនាឡើងដោយថវិកាជាតិ អស់២១០លានរៀល និងបានប្រារព្ធពិធីសម្ពោធឱ្យប្រើប្រាស់ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង នរោត្តម សីហនុ។ កាលពីក្នុងរបបសង្គមរាស្ត្រនិយម គេឱ្យឈ្មោះថាសាកលវិទ្យាល័យភូមិន្ទខ្មែរ ដែលបានសម្ពោធឡើងនៅថ្ងៃទី១៣ខែមករាឆ្នាំ១៩៦០។



*សាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ១៩៦០*

ពហុកីឡដ្ឋានជាតិអូឡាំពិកដែលជាហុកីឡដ្ឋានដ៏ធំជាងគេនៅកម្ពុជាមានអាយុកាលប្រមាណជាជាង៥០ឆ្នាំហើយ និងធ្លាប់បានបំពេញតួនាទីជាច្រើនក្នុងការធ្វើជាម្ចាស់ផ្ទះនៃព្រឹត្តិការណ៍ប្រកួតកីឡាទាំងកម្រិតជាតិ និងអន្តរជាតិ។ ស្នាដៃដ៏មានតម្លៃជាប្រវត្តិសាស្ត្រនេះ ត្រូវបានគូរប្លង់និងដឹកនាំកសាងដោយលោក វណ្ណ មូលីវណ្ណ ក្នុងឆ្នាំ១៩៦១ ក្រោមការផ្តួចផ្តើមរបស់ព្រះបាទសម្តេចព្រះនរោត្តមសីហនុ ហើយត្រូវបានចាប់ផ្តើមចាក់ដីបំពេញទីលាន និងទំនប់នៃពហុកីឡដ្ឋានពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៦២ រហូតដល់ចុងខែមីនា ឆ្នាំ១៩៦៣ និងបានបញ្ចប់នៅក្នុងខែមេសា ឆ្នាំ១៩៦៤ ។ ហើយនឹងបានសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦៤។



*ពហុកីឡដ្ឋានជាតិអូឡាំពិក*

សាលមហោស្រពជាតិដែលមានគុណតម្លៃដ៏មហិមា ជាស្នាដៃស្ថាបត្យកម្មខ្មែរសម័យទំនើបបានបង្ហាញពីគុណតម្លៃនៃការស្ថាបនាជាតិ ដោយកូនខ្មែរពិតៗក្រោយកម្ពុជាឯករាជ្យ និងជាសច្ចធម៌ប្រវត្តិសាស្ត្រមួយគ្មាននរណាអាចបំភ្លែបានឡើយ។ ហើយបានសម្ពោធនាថ្ងៃអង្គារ ទី១២ ខែវិច្ឆិកា ឆ្នាំ១៩៦៨ នៃ មហោស្រពជាតិ "ព្រះសុរាម្រិត"។ ជាអកុសលសាលមហោស្របមួយនេះត្រូវបានភ្លើងឆេះអស់រលីងក្នុងឆ្នាំ១៩៩៤។



*សាលមហោស្រពជាតិ "ព្រះសុរាម្រិត"*

សាលសន្និសិទចតុមុខ "ចតុម្មុខ" គឺត្រូវបានយកឈ្មោះប្រសិទ្ធនាមតាមទីតាំងដែលតាំងនៅត្រង់ទន្លេចតុមុខ។ សាលសន្និសិទនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ ១៩៦២ ដោយស្ថាបត្យករខ្មែរដ៏ល្បីគឺលោក វណ្ណ មូលីវណ្ណ ដើម្បីត្រៀមធ្វើជាម្ចាស់ផ្ទះទទួល ***សន្និសីទពុទ្ធសាសនា*** នៅភ្នំពេញ។



*រូបភាពសាលសន្និសីទចតុមុខ*

ទន្ទឹមនឹងនោះ នៅសម័យសង្គមរាស្ត្រនិយមលើហេដ្ឋារចនាសម្ពន្ធនៃគេហដ្ឋានយើងសង្កេតឃើញថា ការសាងសង់មានលក្ខណៈទំនើបនិងស៊ីវិល័យ។




*មហាវិថីព្រះមុនីវង្ស និងសំណង់អគារ*

ជាអកុសលចាប់តាំងពីឆ្នាំ១៩៧០ នៃការទម្លាក់ព្រះបាទ នរោត្តម សីហនុ រហូតដល់ឆ្នាំ១៩៧៥ ការវិវត្តនៃស្ថាបត្យកម្មនិងសំណង់ គឺមិនមានការរីកដុះដាលអ្វីឡើយ ដោយសារតែកម្ពុជាបានធ្លាក់ចូលក្នុងភ្នក់ភ្លើងនៃសង្គ្រាមដ៏រ៉ាំរៃរវាងខ្មែរនឹងខ្មែរ ផ្ទុយទៅវិញសង្គ្រាម បានបំផ្លិតបំផ្លាញអ្វីៗដែលជាសមិទ្ធផលដែលមានពីមុនមក។





*រូបភាពនៃធនាគារជាតិនៃកម្ពុជា*





*រូបភាពស្ពានជ្រោយចង្វារចាស់បាក់ដោយការបំផ្ទុះគ្រាប់បែកកាលទសវត្សទី៧០*

យ៉ាងណាមិញ ចាប់តាំងពីឆ្នាំ២០០០មក ក្រោមគោលនយោបាយ ឈ្នះ ឈ្នះ ដែលមាន សម្តេចអគ្គសេនាបតិតេជោ ហ៊ុន សែន ជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានធ្វើឱ្យប្រទេសជាតិ មានសុខសន្តិភាព និងមានការអភិវឌ្ឍគ្រប់វិស័យ។ នៅក្នុងរាជធានីភ្នំពេញបច្ចុប្បន្នមានសំណង់អគារខ្ពស់ៗ ទំនើបៗ ធំស្កឹមស្កៃបានរីកដុះដាលគួរឱ្យមានភាពស្ញប់ស្ញែង ដូចជាមានសំណង់អគារមជ្ឈមណ្ឌលពាណិជ្ជកម្ម ការិយាល័យ ធនាគារ ផ្សារទំនើប សណ្ឋាគារ អគារស្នាក់នៅរួមនិងបុរីលំនៅដ្ឋានបានសាងសង់ឡើងជាបន្តបន្ទាប់។



*អគារមជ្ឈមណ្ឌលពាណិជ្ជកម្ម និងសំណង់ខុនដូនៅរាជធានីភ្នំពេញ*



*អគារអូឡាំពិចស៊ីធី ដែលស្ថិតនៅជុំវិញស្តាតអូឡាំពិក*

ទន្ទឹមនឹងនោះដែរ អ្វីដែលជាសមិទ្ធផលថ្មីៗនៃសំណង់ដែលបានកសាងឡើង ក៏នៅមានការបញ្ចូលនូវ សិល្បៈខ្មែរសម័យបុរាណ រួមទាំងវប្បធម៌ និងអត្តន័យទៅតាមមុខងារនៃសំណង់អគារនីមួយៗផងដែរ។



*វិមានសន្តិភាព*



*ទីស្តីការគណៈរដ្ឋមន្ត្រី*





*ប្លង់ និងប្លង់លម្អិតអគារខេមរវិទូនៃរាជបណ្ឌិត្យសភាកម្ពុជា*

# សន្និដ្ឋាន

ការសិក្សាស្រាវជ្រាវអំពី "ការវិវត្តនៃរចនាបថស្ថាបត្យកម្ម និងសំណង់ប្រាសាទខ្មែរសម័យលង្វែក និងឧដុង្គ" នេះ គឺជាការសាកល្បងប្រមូលចងក្រងឡើងវិញនូវមត៌កនៃអរិយធម៌សម័យកណ្ដាល ដើម្បីឈ្វេងយល់ឱ្យឃើញអំពីវិសេសភាពនៃសិល្បៈស្ថាបត្យកម្មនាសម័យកាលក្រោយអង្គរដ៏រុងរឿងនោះមក។ ទោះបីជាសម័យក្រោយៗមកទៀត ដូចយ៉ាងសម័យលង្វែក យើងលែងឃើញមានការកសាងសំណង់ប្រាសាទផ្សេងៗដ៏ស្កឹមស្កៃដូចសម័យអង្គរក្ដី តែសំណង់ស្ថាបត្យកម្មនាសម័យលង្វែក និងឧដុង្គ គឺជារបត់ថ្មីមួយដ៏គួរឱ្យចាប់អារម្មណ៍មិនចាញ់សម័យកាលមុននោះដែរ។ អវត្តមានប្រាង្គប្រាសាទ ឬសំណង់បែបព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយាន ដោយជំនួសមកវិញនូវសំណង់បែបវត្តអារាមជាដើម គឺជាដំណាក់កាលថ្មីមួយទៀតនៃប្រវត្តិសិល្បៈខ្មែរលើផ្នែកស្ថាបត្យកម្មនាសម័យក្រោយអង្គរ ដែលមានអត្ថិភាព និងបន្តជាពុម្ពគំរូមកទល់នឹងសព្វថ្ងៃ ហើយដែលជាអត្តសញ្ញាណជាតិដ៏សំខាន់មួយផងដែរ។

ជារួម ការសិក្សាស្រាវជ្រាវអំពី «ការវិវត្តនៃរចនាបថស្ថាបត្យកម្ម និងសំណង់ប្រាសាទខ្មែរនៅសម័យលង្វែក និងឧដុង្គ" គឺជាការបន្តការសិក្សាស្រាវជ្រាវអំពីការវិវត្តនៃរចនាប័ទ្មស្ថាបត្យកម្ម និងសំណង់ប្រាសាទខ្មែរសម័យមុនអង្គរ និងអង្គរ ដែលខ្មែរយើងបានទទួលឥទ្ធិពលចំណែកណានោះពីឥទ្ធិពលនៃវប្បធម៌-អរិយធម៌ឥណ្ឌា គួបផ្សំនឹងលក្ខណៈពិសេសនៃទេពកោសល្យរបស់មនុស្សខ្មែរ បានបង្កើតឱ្យមានវិសេសភាពនៃរចនាបថស្ថាបត្យកម្ម និងសំណង់ក្នុងអត្តសញ្ញាណជាសិល្បៈស្ថាបត្យកម្មខ្មែរ។

# គន្ថនិទ្ទេស

**ឯកសារជាភាសាជាតិ**

១. ជី វង្ឍា *ប្រវត្តិសាស្ត្រ-ប្រវត្តិសិល្បៈខ្មែរ* ២០១០។

២. ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ ភាគ១* ២១៩៧៣។

៣. ត្រឹង ងា *អរិយធម៌ខ្មែរ* អ្នកស្រី ភ្នំពេញ ១៩៧៥។

៤. *ទស្សនាវដ្ដីចេតនា និងសំណង់* សាកលវិទ្យាល័យន័រតុន (គ្មានកាលបរិច្ឆេទ)។

៥. បណ្ឌិត ធ សោ *ព្រហ្មញ្ញសាសនា និងសង្គមខ្មែរ* សម្រាប់ជំនួយស្មារតីដល់និស្សិតថ្នាក់ត្រៀម ឧត្តមសិក្សា និស្សិតថ្នាក់បរិញ្ញាប័ត្រអក្សរសាស្ត្រ ១៩៩៤។

៦. ព្រាប ចាន់ម៉ារ៉ា *សំណង់នៅតាមវត្ត* ភ្នំពេញ ២០១៧។

៧. លាង ហាប់អាន *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សទី១ ដល់ ១៨៥៩)* ភ្នំពេញ ១៩៦៧។

**គេហទំព័រ**

៨. https://tamabmmo.wordpress.com/research/research-oudong/

៩. http://rac.apppeppers.com/posts/52

១០. http://api.tnaot.com/article/gallery_detail/622909

# "លក្ខណៈពិសេសនៃក្បាច់ចម្លាក់ប្រាសាទបន្ទាយស្រី"

ដោយសាស្ត្រាចារ្យ **ផល ពុទ្ធិ**
សាស្ត្រាចារ្យមហាវិទ្យាល័យសូន្យរូបនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ







សេចក្តីផ្តើម
• បើសង្កេតមើលទៅលើទំរង់និងឈ្មោះដែលគេដាក់អោយក្បាច់ខ្មែរនិមួយៗឃើញថាច្រើនតែមានទំនាក់ទំនងទៅនឹងធម្មជាតិដូចជា សត្វ រុក្ខជាតិដែលមានដើម ស្លឹក ផ្លែ ផ្កាជាដើម។
ឯកសារយោងពីម៉ីយ៉ា


បញ្ហា
• បើយើងពិចារណាទៅលើពាក្យ ក្បាច់ ឃើញថាអាចមកពីពាក្យ កាច់ ឯក្បាច់គឺគេសំដៅទៅលើគ្រឿងលម្អវិចិត្រផ្សេងៗដែលមានរាងពត់ពេនកាច់ចុះឡើងដោយដកស្រង់រូបរាងពីធម្មជាតិផ្សេងៗយកមកច្នៃប្រឌិតទៅតាមទេពកោសល្យរបស់សិល្បៈករ។

## វត្ថុបំណង

- ជាទូទៅមានទម្លាប់ហៅឈ្មោះក្បាច់ដោយសំដៅទៅលើផ្នែកណាមួយនៃសំណង់(ដែលមានប្រើក្បាច់ បច្ចេកទេស ឬវត្ថុធាតុ ឧទាហរណ៍ ក្បាច់អង្គរដែលគេយកមកទៅប្រើលើក្បាលសសរណាមួយ នោះគឺគេច្រើនហៅថា(ក្បាច់ក្បាលសសរ តែម្តង)។ បើមើលទៅ ក្បាលសសរគឺជាផ្នែកមួយនៃសំណង់ រីឯក្បាច់មានឈ្មោះថា ក្បាច់អង្គរ ។
- រូបរាងក្បាច់ខ្លះមានលក្ខណះជា ក្បាច់ ហើយបំបែកទម្រង់មានការកែច្នៃទៅតាមវិធីផ្សេងៗគ្នានឹងប្រើប្រាស់ទៅតាមវត្ថុឬទីកន្លែងដែលមានទំនាក់ទំនងទាំងនោះមកកែច្នៃរចនាខាងក្នុងឬខាងក្រៅក្លាយជាក្បាច់អ្វីមួយទៅតាមវិធី ចែក នឹង ផែកជាដើម។

## វិធីសាស្រ្ត

- ទម្រង់ក្បាច់មូលដ្ឋាន
- បើសង្កេតមើលទៅលើទម្រង់ និងឈ្មោះដែលគេដាក់អោយក្បាច់បន្ទាយស្រីគឺស្រិគ្រប់លក្ខណ៍នៅក្នុងសង្គមខ្មែរនាសម័យមហានគរ ហើយការប្រើប្រាស់ក្បាច់នីមួយៗឃើញថាច្រើនតែមានទំនាក់ទំនងទៅនឹងធម្មជាតិឬរចនាទៅតាមគោលការណ៍ដែលគេចង់បាន ។ ការតុបតែងទម្រង់លម្អ នឹងបំពាក់គ្រឿងអលង្ការរួមទាំងវត្ថុមានតំលៃ ឬទម្រង់ផ្សេងៗទៀតដូចរូបសត្វហង្សជាដើម។



ឯកសារយោងពីមីយ៉ំ

សារិតា

- ក្បាច់អង្គរ
- បើតាមការសង្កេតនិងសាកសួរលោកគ្រូចាស់ៗឃើញថាក្បាច់អង្គរគេប្រើក្នុងទម្រង់សំខាន់ៗ៣ដែលដកស្រង់ពីធម្មជាតិ គឺគ្របកឈូកចំពីមុខ គ្របកឈូកចំហៀង(ដែលអាចក្លាយជាកន្ទុយហង្ស និងវង្សហៀនដែលគេអាចបំបែកជាក្រពុំ ឬចង្វាយ ។មិនតែប៉ុណ្ណោះ សិល្បៈករដកយករូបសត្វ ឬរូបទេពផ្សេងៗមកប្រើជំនួសដែរ ដែលធ្វើអោយរូបរាងក្បាច់នេះរឹតតែសម្បូរថែមទៀត។ (ឯកសារពីមីយ៉ំ)







ឯកសារយោងពីមីយ៉ំ

សន្និដ្ឋាន

- រាល់ការបង្កើតគំនិតសុទ្ធសឹងតែប្លុកបញ្ចូលនូវក្បូនខ្នាតបាតុត្រាដែលមានការវិវឌ្ឍន៍នៃរចនាបទនិងសំណង់គំរូពីប្រាសាទនានា ដែលមានការរចនាល្អស្អាត។
- ការតុបតែងលំអរក្រោមប្រធានបទស្រីគ្រប់លក្ខណ៍ជាមាតាទី១ដោយមានការលើកកំពស់និងសិទ្ធិសេរីភាពពេញបរិបូរណ៍រឹមាតាប្រជាធិបតេយ្យ។



បទបង្ហាញដោយលោកសាស្ត្រាចារ្យ ធល ឫទ្ធិ

## ឯកសារយោង



ក្បាច់ខ្មែរ

KBACH

A Study of Khmer Ornament



# "សិល្បៈចម្លាក់នៅប្រាសាទបាកាណ (ព្រះខ័នកំពង់ស្វាយ)"

រៀបរៀងដោយ
លោក **ហឿន សាខហុន** ប្រធានផ្នែកវប្បធម៌វិទ្យា
វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១-សេចក្តីផ្តើម

រមណីដ្ឋានបុរាណវិទ្យាបាកាណ ព្រះខ័ន)-កំពង់ស្វាយ( ជារាជធានីមួយ ស្ថិតនៅចម្ងាយជាង ១០០គីឡូម៉ែត្រភាគខាងកើតតាមបណ្តោយផ្លូវបុរាណពីតំបន់អង្គរ។ រាជធានីនេះបានកសាងនៅសតវត្សទី១១ដែលជារាជាធានីដំបូងរបស់ព្រះបាទសូរ្យវរ្ម័នទី១ (គ.ស. ១០០២-១០៥០)។ ព្រះបាទសូរ្យវរ្ម័នទី១បានសាងប្រាសាទបាកាណជាប្រាសាទកណ្តាលតាំងពីមុនគ.ស.១០០៦ ដែលជាគំរូនៃការបង្កើតថ្មីខាងវិស័យសិល្បៈស្ថាបត្យកម្ម ក្នុងការចាប់ផ្តើមរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នទី១[3]។ ក្រោយមកព្រះបាទសូរ្យ-វរ្ម័នទី២ (គ.ស.១១១៣-១១៥០) បានបន្តរៀបចំកសាងរចនាសម្ព័ន្ធរាជធានីនិងស្ថាបនាប្រាសាទបុរាណជាច្រើននៅក្នុងរាជធានីបាកាណនេះ។ អំឡុងសតវត្សទី១២ ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨)បានគង់នៅរាជធានីបាកាណនេះអស់រយៈពេលយ៉ាងយូរមុនទ្រង់បានឡើងគ្រងរាជ្យជាព្រះមហាក្សត្រ។

ភាពសម្បូរបែបនៃសម្បត្តិវប្បធម៌មានដូចជា ប្រាសាទបុរាណតូចធំ ផ្លូវនិងស្ពានបុរាណ សំណង់កំពែងដីប្រវែង៤៥០០ម៉ែត្របួនជ្រុង បារាយណ៍ទឹក បឹង ត្រពាំង ស្ទឹង ចម្លាក់សិល្បៈ សិលាចារឹក ព្រមទាំងធនធានធម្មជាតិ បានបង្ហាញពីសក្តានុពល និងភាពអស្ចារ្យនៃរចនាសម្ព័ន្ធនគរូបនីយកម្មទីក្រុងបុរាណដ៏ស្កឹមស្កៃ និងឆ្លុះបញ្ចាំងពីការវិវត្តនៃរចនាបថសិល្បៈស្ថាបត្យកម្មរបស់រាជធានីបាណ និងជារាជធានីខ្មែរដ៏សំខាន់មួយក្នុងសម័យអង្គរ។ រាជធានីបាកាណគឺជាមូលដ្ឋានទីតាំងយុទ្ធសាស្ត្រដ៏រឹងមាំក្នុងការរៀបចំកម្លាំងតស៊ូរំដោះជាតិរបស់ព្រះបាទជ័យវរ្ម័នទី៧ ពីការឈ្លានពានពីសំណាក់ពួកទ័ពចាមនៅក្រុងយសោធរ។

សម្បត្តិវប្បធម៌ដ៏ច្រើនទាំងនេះហើយ ដែលបានទាក់ទាញអ្នកស្រាវជ្រាវអន្តរជាតិ បានផ្តើមសិក្សាស្រាវជ្រាវអំពីក្រុមប្រាសាទបុរាណនៅទីនេះជាបន្តបន្ទាប់តាំងពីដើមស.វទី១៩មក។ ពិសេសពួកណានិគមបារាំង មានដូចជាក្រុមបេសកកម្មនៃគណៈកម្មការរុករកទន្លេមេគង្គ (១៨៦៦) លោក ល្វីស៍ ឌឺឡាព័រ៍ (១៨៧៣) លោក អេដេន អៃមូនីញ៉េរ៍ (១៩០០) លោក លុយណេ ដឺឡា ហ្សង់គីយ៉ែរ៍ (១៩០២) លោក វិចទ័រ ហ្គូលូបើស៍ (១៩៣៧) លោក ហ្សក សឺដេស លោក ភីលីពស្ទែន លោក ប៉ែណា ភីលីព ហ្រ្គូសលីយ៉េរ៍ លោក ហង់រី មូហ្សេរ៍ (១៩៣៩) លោក ជីនអឺន៍ អូប៊ូយ៉េរ៍ (១៩៦៨)។ល។ ការស្រាវជ្រាវកាល នោះច្រើនផ្តោតលើការធ្វើផែនទីភូមិសាស្ត្រតំបន់ សិល្បៈ ស្ថាបត្យកម្ម សិលាចារឹក គម្រោងអភិរក្សប្រាសាទជាដើម។ គម្រោងទាំងឡាយរបស់បារាំងត្រូវបានបញ្ចប់នៅពេលកម្ពុជាធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលពីទសវត្សរ៍ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៩។ ក្រោយសង្គ្រាម ការសិក្សាស្រាវជ្រាវអំពីក្រុម

---

[3] Briggs, Lowrence Palmer, *The Ancient Khmer Empire*, Philadelphia, February 1951, p. 154

ប្រាសាទបាកាណបានចាប់ ដំណើរការឡើងវិញក្នុងទសវត្សរ៍ឆ្នាំ២០០៥ ដោយស្ថាប័នជាតិ អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ហើយបន្តរហូតបច្ចុប្បន្ន។

អត្ថបទស្រាវជ្រាវនេះ នឹងសិក្សាស្វែងយល់អំពីតួនាទី និងនិម្មិតរូបនៃចម្លាក់បីប្រភេទសំខាន់ៗ ដូចជា ចម្លាក់សត្វនិងចម្លាក់រឿងជាតក ដោយផ្អែកលើភស្តុតាងចម្លាក់ដែលមាននៅលើប្រាសាទបាកាណ។ អត្ថបទនេះក៏លើកមកបង្ហាញគ្រួសៗដែរ អំពីក្រុមប្រាសាទមួយចំនួននៅក្នុងរមណីយដ្ឋានបុរាណវិទ្យាបាកាណ គ្រាន់បានជាការយល់ដឹងបន្ថែម។




*ផែនទីទីតាំងរមណីយដ្ឋានបុរាណវិទ្យាបាកាណ (ព្រះខ័ន-កំពង់ស្វាយ)*

## ២-ប្រាសាទបុរាណក្នុងរមណីយដ្ឋានបុរាណវិទ្យាបាកាណ

នៅក្នុងរមណីយដ្ឋានបុរាណវិទ្យាបាកាណឃើញមានប្រាសាទចំនួន១៣ ដែលនៅរក្សាទ្រង់ទ្រាយលក្ខណៈសំណង់ដើម និងប្រាសាទចំនួន៣២ទៀតបានបាក់ស្រុតបាត់រូបរាងដើមនៅសល់គ្រឹះ និងខឿន។ កត្តាអាយុកាល កត្តាធម្មជាតិ ការគាស់បំផ្លាញ ការលួចជាប់ចម្លាក់និងថ្មប្រាសាទដោយពួកជនទុច្ចរិត គឺជាកត្តាបំផ្លិចបំផ្លាញដ៏ធំជេងបំផុត ដែលធ្វើឱ្យប្រាសាទបុរាណជាច្រើនបាក់បែកខូចខាតស្ទើគ្មានសល់។ ក្រុមប្រាសាទបាកាណអាចចែកចេញជាពីរប្រភេទគឺ ប្រាសាទបាកាណ (ប្រាសាទធំ) និងប្រាសាទជាបរិវារ។ ក្រៅអំពីប្រាសាទទាំងពីរប្រភេទនេះ នៅមានសំណង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗជាច្រើនដែលទៀត ដូចជា បារាយណ៍តជាក ស្ពានថ្ម និងផ្លូវបុរាណ ជាដើម។




## ២.១. ប្រាសាទបាកាណ

ប្រាសាទបាកាណ ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងថ្មភក់៤ជាន់ ហ៊ុំព័ទ្ធពីក្រៅដោយកសិណទឹកបណ្ដោយ១០០០ម៉ែត្រគុណ៨០០ម៉ែត្រទទឹង។ កំពែងមណ្ឌលនីមួយៗមានក្លោងទ្វារនៅគ្រប់ទាំងបួនទិស។ ក្លោងទ្វារធំនៃកំពែងទាំងបួនជាន់គឺស្ថិតទិសខាងកើត ដែលជាច្រកចូលទៅកាន់ប្រាង្គប្រាសាទកណ្ដាល។ កសិណទឹកនិងកំពែងមណ្ឌលទាំងបួនជាន់នៃប្រាសាទបាកាណ ហ៊ុំព័ទ្ធជុំវិញដោយកំពែងដីបីជាន់មានប្រវែង៤៥០០ម៉ែត្របួនជ្រុង។ នេះជាទំហំកំពែងដីដ៏ធំបំផុតនៅកម្ពុជាសម័យបុរាណ។ កំពែងអង្គរធំមានទំហំតែជា៣គីឡូម៉ែត្របួនជ្រុង ឯកំពែងប្រាសាទបន្ទាយឆ្មារគឺមានទំហំ៤គីឡូម៉ែត្រ។

**កំពែងទី១៖** ជាកំពែងសាងសង់ដោយលើកដីធ្វើជាជញ្ជាំងមានបីជាន់ប្រវែង៤៥០០ម៉ែត្របួនជ្រុង។ កំពែងដីនេះប្រៀបបាននឹងកំពែងការពាររាជធានីបាកាណទាំងមូល។ ជ្រុងខាងកើតនៃកំពែងដីត្រូវបានសង់ទល់ចំពាក់កណ្ដាលទំនប់បារាយណ៍តដាកផ្នែកខាងត្បូង និងខាងជើង។

**កំពែងទី២៖** កំពែងនេះសង់ពីថ្មបាយក្រៀមនិងថ្មភក់មានកម្ពស់ជាង៣ម៉ែត្ររាងចតុកោណកែង មានបណ្ដោយប្រវែង១០០០ម៉ែត្រនិងទទឹង៨០០ម៉ែត្រ ព័ទ្ធជុំវិញដោយកសិណទឹកមានទទឹង៥០ម៉ែត្រ។ នៅគ្រប់ទិសទាំងបួនមានច្រកទ្វារចេញចូលចំនួន៤ មានលក្ខណៈជាប្រាសាទឬគោបុរៈ។ នៅលើហោជាងនិងតួគោបុរៈកំពែងទី២នេះមានលម្អដោយក្បាច់រចនា មានចម្លាក់ទេពអប្សរ ព្រះវិស្ណុជិះលើគ្រុឌរំលេចក្នុងផ្កាវល្លិ៍ ចម្លាក់រឿងជាតក នរសិង្ហ សត្វហង្ស ជាដើម។ គោរបុរៈទី២ មានលក្ខណៈ

ស្រដៀងនឹងគោរបុរៈចូលក្រុងអង្គរធំ។ សំណង់ និងប្រាសាទនៅបរិមណ្ឌលកំពែងទី២ភាគច្រើនត្រូវបានសាងសង់ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២[4]។

នៅក្នុងបរិមណ្ឌលចន្លោះកំពែងទី២ និងកំពែងទី៣ មានប្រាសាទពីរនៅរក្សាទម្រង់ដើមល្អនោះគឺ ប្រាសាទកាត់ក្ដី (ឬប្រាសាទសិលចារឹក) ស្ថិតនៅខាងត្បូងផ្លូវ និងប្រាសាទធម្មសាលា ស្ថិតនៅខាងជើងផ្លូវ។ ប្រាសាទកាត់ក្ដីសង់ពីថ្មភក់ និងព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម។ ប្រាសាទនេះប្រហែលសង់នៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២។ មានសិលាចារឹកមួយផ្ទាំងចារនៅលើជញ្ជាំងប្រាសាទនេះ។ ចំពោះប្រាសាទធម្មសាលាសង់នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។ ធម្មសាលាជាប្រាសាទមួយក្នុងចំណោមធម្មសាលា ឬសាលាសំណាក់ទាំង១២១កន្លែងសង់នៅតាមផ្លូវបុរាណនាសម័យអង្គរ។

**កំពែងទី៣៖** មានស្ពានហាលមួយសម្រាប់ដើរឡើងទៅកាន់គោរបុរៈទី៣។ ស្ពានហាលនេះសង់ផុតពីដីទ្រដោយសសរថ្មមូលៗ មានលក្ខណៈស្រដៀងទៅនឹងស្ពានហាលចូលទៅកាន់ប្រាសាទបាពួន។ ស្ពាននេះបានបាក់រលំធ្លាក់ដល់ដីអស់។ កំពែងទី៣សង់ពីថ្មភក់មានកម្ពស់ខ្ពស់ មានប្រវែង១៥០ម៉ែត្របួនជ្រុង។ កំពែងនេះសង់ឡើងជារោងទងព័ទ្ធជុំវិញ។ រោងទងកំពែងទី៣បានរលំបាក់ស្រុតនិងបែកបាក់ខ្ទេចខ្ទីពិបាកនឹងសិក្សា។ នៅក្នុងបរិមណ្ឌលនៃកំពែងទី៣មានប្រាសាទថ្មមួយចំនួន តែត្រូវបាក់រលំសល់តែគ្រឹះ។ នៅជាប់របងកំពែងផ្នែកខាងជើងជ្រុងខាងកើតមានប្រាសាទសង់ពីឥដ្ឋ៤អ្នកស្រុកហៅ ប្រាសាទចេតិយ។

**កំពែងទី៤៖** ជាកំពែងជាលក្ខណៈរោងទងនិងគោរបុរៈបើកចំហទៅគ្រប់ទិសទាំងបួន។ នៅតាមជ្រុងនីមួយៗមានប្រាង្គ ឬតួប៉មប្រាសាទ ប្រៀបដូចជាទីតាំងបន្ទាយដ៏រឹងមាំ។ លក្ខណៈនៃកំពែងទី៤គឺការរចនា រំលេចនូវទ្វារបញ្ឆោតនៅតាមជញ្ជាំងរោងទង និងចម្លាក់ពុទ្ធបដិមា៥អង្គនៅទ្វារបញ្ឆោតឬផ្ដែរទ្វារ។

**កំពែងទី៥៖** មានចម្ងាយ៥០ម៉ែត្រចេញពីកំពែងទី៣ ដែលមានទំហំ៥០ម៉ែត្របួនជ្រុង សង់ពីថ្មភក់។ ប្រាសាទកណ្ដាលឬបរិមណ្ឌលកណ្ដាលនេះជាផ្នែកសំខាន់នៃប្រាសាទបាកាណ។ តាមលក្ខណៈសិល្បៈស្ថាបត្យកម្មប្រាសាទនៅក្នុងបរិមណ្ឌលកណ្ដាលនៃកំពែងទី៥ កសាងនៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី[5]។ បរិមណ្ឌលកណ្ដាលព័ទ្ធជុំវិញដោយកំពែងរោងទងមានប្រវែង៥០ម៉ែត្របួនជ្រុង និងមានសំណង់សំខាន់ៗ ដូចជា ប្រាសាទកណ្ដាល (ប្រាសាទបាកាណ) ហោត្រ័យជើង និងខាងត្បូង ប្រាសាទព្រះពាន់ ប្រាសាទនាងពៅ និង ប្រាសាទដង្កៅបៅដោះ។ ប្រាសាទទាំងនេះជាឈ្មោះដែលអ្នកស្រុកក្នុងតំបន់ហៅតៗគ្នាមក។ កំពែងរោងទងមានគោបុរៈនៅគ្រប់ទិសទាំងបួន។ ប្រាង្គបាកាណ ហោរត្រ័យ រោងទង និងគោបុរៈនៅក្នុងកំពែងនៃគោបុរៈទី៥ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រាង្គប្រាសាទមួយចំនួននៅក្នុងរចនាបថអង្គរវត្ត នៃរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១។ នៅលើប្រាង្គបាកាណ និងនៅលើហោត្រ័យខាងជើងដែលមិនទាន់បាក់រលំ ឃើញមានលម្អដោយក្បាច់ចម្លាក់បែបព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាផង។ បច្ចុប្បន្ន ប្រាសាទនៅទីនេះត្រូវជនទុច្ចរិតទាញផ្ដួលរំលំកំពូលប្រាសាទ រោងទង ក្លោងទ្វារ ត្រូវបាក់ស្រុតខ្ទេចខ្ទីស្ទើរមើលមិនយល់។

---

4 Briggs. Ibid. 1951, p. 192

5 Briggs L. Palmer, ibid.

## ២.២. ប្រាសាទជាប់រិវារសំខាន់ៗ

នៅខាងក្រៅកំពែងទាំង៤ជាន់នៃប្រាសាទបាកាណ គឺមានប្រាសាទសំខាន់ៗមួយចំនួនដែលនៅគង់វង្សនៅឡើយ ដូចជា ប្រាសាទព្រះស្ទឹង ប្រាសាទព្រះថ្កោល ប្រាសាទចតុមុខ ប្រាសាទបឹងស្រែ ប្រាសាទអូរឈើទាលធំ អូរឈើទាលតូច អូរឈើទាលឯលិច អូរឈើទាលឯត្បូង ប្រាសាទព្រះដំរី ។ល។

### ប្រាសាទព្រះស្ទឹង

ស្ថិតនៅខាងកើតជ្រុងឯខាងជើងកំពែងទី២នៃប្រាសាទបាកាណ ជាប់នឹងទំនប់ខាងលិចនៃបារាយណ៍តជាក (អ្នកស្រុកហៅព្រះដាក់)។ ប្រាសាទសង់ពីថ្មភក់ មានកំពែងខ្ពស់ព័ទ្ធជុំវិញទំហំ៥០ម៉ែត្របួនជ្រុង។ តួប៉មកណ្តាលជាព្រហ្មមុខបួនដែលជាលក្ខណៈពិសេសនៅក្នុងរចនាបថបាយ័ន នៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។ នៅមុខប្រាសាទមានផ្លូវថ្មមួយភ្ជាប់ទៅកាន់ស្ពានថ្មកំពង់ទឹកបារាយណ៍តជាក។ ស្ពានកំពង់ទឹកនេះមានក្បាច់រចនាវិចិត្រ ពិសេសចម្លាក់សត្វហង្សក្បាលបីធំៗមួយជំហមនុស្សឈរទ្រស្ពានកំពង់ទឹក។ នេះជាលក្ខណៈពិសេសដោយឡែកនៃរចនាបថសិល្បៈនៅបាកាណកំពង់ស្វាយ។

### ប្រាសាទព្រះថ្កោល

ប្រាសាទព្រះថ្កោល ឬប្រាសាទមេបុណ្យ សង់នៅលើដីទួលចំកណ្តាលបារាយណ៍តជាក ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងថ្មភក់ទំហំ៥០ម៉ែត្របួនជ្រុង មានច្រកទ្វារចេញចូលនៅគ្រប់ទិសទាំងបួន។ តួប្រាង្គប្រាសាទកណ្តាលសង់ពីថ្មភក់មានកម្ពស់ប្រហែល១៥ម៉ែត្របែរមុខទៅទិសខាងកើត។ ប្រាសាទនេះសង់ឡើងរត់ចំខ្សែអ័ក្សនៃប្រាសាទបាកាណ។ ផ្អែកលើលក្ខណៈសិល្បៈស្ថាបត្យកម្មប្រាសាទព្រះស្ទឹងស្ថាបនាឡើងទៅតាមគោលទស្សនៈរបស់ព្រះបាទជ័យវរ្ម័នទី៧ តាមរយៈការរំលេចចេញក្បាច់ចម្លាក់នៅតាមជ្រុងនីមួយៗនូវបដិមាដំរីសាមពាន់ ឬដំរីក្បាលបី ចម្លាក់សត្វគ្រុឌ នរសិង្ហ និងកំពូលប្រាង្គប្រាសាទជាព្រហ្មមុខបួន ឬព្រះលោកេស្វរៈ ព្រមទាំងរួមបញ្ចូលនូវចម្លាក់ព្រះសិវៈ ព្រះនារាយណ៍ និងព្រះឥន្ទ្រាផង។

### ក្រុមប្រាសាទអូរឈើទាល

ក្រុមប្រាសាទអូរឈើទាលមានបីប្រាសាទ គឺប្រាសាទអូរឈើទាលធំ ប្រាសាទអូរឈើទាលឯលិច និងប្រាសាទអូរឈើទាលឯត្បូង។ បើពិនិត្យតាមទីតាំងភូមិសាស្ត្រប្រាសាទទាំងបីសង់នៅក្បែរអូរឈើទាលដែលស្ថិតនៅខាងលិចប្រាសាទបាកាណ។ ហើយឈ្មោះប្រាសាទត្រូវបានអ្នកស្រុកហៅទៅតាមទីកន្លែងនៃទិសដែលប្រាសាទនីមួយៗសង់ដោយធៀបទៅនឹងទិសនៃភូមសាស្ត្រអូរឈើទាល។ តាមអ្នកស្រុកបានហៅប្រាសាទអូរឈើទាលថា ប្រាសាទចាំ[6]។ ក្រុមប្រាសាទអូរឈើទាលមានលក្ខណៈរចនាបថដូចទៅនឹងប្រាសាទព្រះស្ទឹង។ ប្រាសាទអូរឈើទាលធំសង់នៅលើទីតាំងរត់ចំអ័ក្សនៃប្រាសាទបាកាណដូចប្រាសាទព្រះថ្កោលដែរ។

---

[6] រស់ ចន្ត្រាបុត្រ *ប្រាសាទព្រះខ័នកំពង់ស្វាយ,* រាជបណ្ឌិត្យសភាកម្ពុជា, ខែធ្នូ គ.ស.២០០៥

## ប្រាសាទត្រពាំងចំបក់

ប្រាសាទត្រពាំងចំបក់ ជាឈ្មោះហៅតាមត្រពាំងមួយស្ថិតនៅចម្ងាយជាងកន្លះគីឡូម៉ែត្រខាងលិចទីតាំងប្រាសាទ។ បច្ចុប្បន្នប្រាសាទនេះស្ថិតនៅចម្ងាយប្រហែល៥គីឡូម៉ែត្រខាងលិចប្រាសាទបាកាណ តាមផ្លូវបុរាណទៅកាន់ភូមិខ្វាវ ស្រុកជីក្រែង នៃខេត្តសៀមរាប។

ប្រាសាទត្រពាំងចំបក់សង់ពីថ្មភក់ បែរមុខទៅទិសខាងកើត ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម មានទំហំ៥០ម៉ែត្របួនជ្រុង។ តាមការពិនិត្យ ក្រៅពីក្លោងទ្វារធំស្ថិតនៅទិសខាងកើត គឺនៅមានក្លោងទ្វារនៅកំពែងខាងត្បូងជិតមកជ្រុងកំពែងខាងលិចជ្រុងខាងត្បូង ដែលមានលក្ខណៈជារោងទងនិងមានបង្អួចអមសងខាងនិងទ្វារកំពែងតូចមួយនៅកំពែងខាងលិចឬខាងក្រោយ។ ភ្ជាប់ពីក្លោងទ្វារធំខាងកើតមានស្ពានហាលមួយសង់ផ្ទាល់ដីក្រាលថ្មបាយក្រៀមមានបណ្ដោយប្រហែល១០០ម៉ែត្រ និងទទឹងប្រវែង៥ម៉ែត្រឆ្ពោះទៅអូរមួយ។ ស្ពាននេះលម្អដោយបង្គោលថ្មសីមាដូចបង្គោលសីមានៅស្ពានហាលប្រាសាទព្រះខ័ន-អង្គរ។ សព្វថ្ងៃបង្គោលថ្មនេះបានដួលរលំបន្សល់ទុកលើដីនិងកប់ទៅក្នុងដី។ ប្រាសាទកណ្ដាលធំមួយអមហោត្រ័យបែរមុខទៅខាងលិច។ នៅលើជញ្ជាំងនៃប្រាសាទកណ្ដាលមានចម្លាក់បែបព្រះពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង ។

## ប្រាសាទចតុមុខ

អ្នកស្រុកនិយមហៅប្រាសាទនេះថា ព្រះអង្គធំ ឬព្រះចតុមុខ ឬតាព្រហ្ម។ តាមសិលាចារិកប្រាសាទនេះមានឈ្មោះពិតប្រាកដថា "ចតុមុខ"។ ប្រាសាទចតុមុខគឺខុសពីប្រាសាទបុរាណដទៃៗទៀតដែលគេបានស្គាល់ ដោយប្រាសាទនេះសង់ឡើងក្នុងទម្រង់ព្រះពុទ្ធបដិមា៤អង្គក្នុងជំហទល់ខ្នងនិងបែរព្រះភ័ក្រទៅទិសទាំងបួនបង្កើតបានជាតួប៉មនៃប្រាសាទមួយ។ នេះជាពុទ្ធបដិមាប្រាសាទដ៏ធំនៅកម្ពុជាសម័យបុរាណ។

ប្រាសាទចតុមុខស្ថិតនៅជិតជ្រុងទំនប់ខាងលិចជ្រុងខាងត្បូងនៃបារាយណ៍តដាក។ បដិមាព្រះពុទ្ធមុខបួនបានបាក់បែកអស់ពាក់កណ្ដាលផ្នែកខាងលើនៅសល់តែសំពត់ខាងក្រោម។ ក្នុងឆ្នាំ២០១៨នេះ ក្រុមអភិរក្សរបស់នាយកដ្ឋានគាំពារនិងអភិរក្សសំណង់បុរាណ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានជួសជុលផ្គុំព្រះពុទ្ធបដិមាចតុមុខឱ្យមានរូបរាងច្បាស់លាស់ឡើងវិញ[7]។

## ប្រាសាទបឹងស្រែ

ប្រាសាទបឹងស្រែ[8] ស្ថិតនៅខាងកើតបឹងស្រែលិចចម្ងាយជាង៥០ម៉ែត្រ និងស្ថិតនៅខាងកើតជ្រុងខាងជើងប្រាសាទបាកាណ។ ប្រាសាទនេះសង់លើខឿនខ្ពស់ មានតួប៉មតែមួយសង់ពីថ្មបាយ

---

[7] ទី សារឿន «ប្រាសាទចតុមុខពីភាពប៉ាត់ប៉ាយ មកក្លាយជារូបសំណាកព្រះពុទ្ធរូបដ៏ធំមួយយ៉អង្គ» ថ្ងៃសៅរ៍ទី២១ ខែកក្កដា ឆ្នាំ២០១៨,នៅក្នុង៖ *http://spktliv.com/archives/3222*

[8] លោក Lunet De Lajonquiere, បានចុះបញ្ជីប្រាសាទនេះលេខ L.L. 177, និងលោក ហង់រី ម៉ាកសាល់ M. H. n$^0$ 206 នៅក្នុង៖ Henri Mauger. Preah Khan de Kompong Svay, *BEFEO* Tome XXXIX 1939, p.214

ក្រៀម និងថ្មភក់ជាគ្រឿងតុបតែងលម្អក្លោងទ្វារ និងសសរពេជ្រ។ នៅលើផ្តែរទ្វារមិនមានឃើញមានក្បាច់ចម្លាក់គួរកត់សម្គាល់ទេ។ តាមការពិនិត្យលើប្លង់ប្រាសាទនេះមានរាងទ្រវែងបែរមុខទៅទិសខាងកើតនិងមានប្រាសាទតូចមួយ ដែលអាចជាហោត្រ័យនៅខាងមុខជ្រុងខាងត្បូងព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានក្លោងទ្វារធំមួយនៅជ្រុងខាងកើតចំពីមុខប្រាសាទ។ សព្វថ្ងៃទាំងតួរោងទងដែលតភ្ជាប់ពីតួប្រាសាទធំ និងប្រាសាទតូចនៅពីមុខនោះ ព្រមទាំងកំពែងបានរលំបាក់បាត់រូបរាងដោយបន្សល់ទុកតែតួប៉មប្រាសាទធំ។

### ប្រាសាទព្រះដំរី

នៅខាងកើតឈាងខាងត្បូងទំនប់បារាយណ៍តដាកមានប្រាសាទមួយហៅថា ប្រាសាទព្រះដំរី។ ជាប្រាសាទមានរាងជាសាជីពីរ៉ាមីតទំហំ៥០ម៉ែត្របួនជ្រុង កំពស់១៥ម៉ែត្រ មានកាំចំនួន១២ថ្នាក់ ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម។ ទាំងផ្នែកខាងក្រោមនិងខាងលើមានចម្លាក់រូបដំរីធ្វើពីថ្មភក់ឈរនៅតាមជ្រុងនីមួយៗ។ ប៉ុន្តែបច្ចុប្បន្នគេឃើញមានតែដំរីថ្មតែពីរទេនៅលើទីតាំងដើមនេះ។ ចំណែកដំរី ថ្មពីរទៀតត្រូវបានយកទៅរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ និងសារមន្ទីរហ្គីមេប្រទេសបារាំង។ នៅ តាមជ្រុងផ្នែកខាងក្រោមមានបដិមាសត្វតោ និងតាមជញ្ជាំងក្លោងទ្វារមានចម្លាក់ទ្វារបាលប្រុស ស្រី។ លោក Mouger សន្និដ្ឋានថា បដិមាដំរីថ្មនិងប្រាសាទព្រះដំរី បានស្ថាបនាឡើងតាំងពីចុងសតវត្សទី១០មកម្ល៉េះ[9]។ ប្រាសាទព្រះដំរី គឺជាទីសក្ការៈបូជាដ៏ស័ក្តសិទ្ធិមួយដែលពលរដ្ឋក្នុងមូលដ្ឋានតែងធ្វើពិធីឡើងអ្នកតានៅលើប្រាសាទនេះរៀងរាល់ឆ្នាំ។

ប្រាសាទព្រះដំរីមានរចនាបថសិល្បៈពិសេស ដូចជា បដិមាដំរីនៅតាមជ្រុងកំពែងគ្រប់ទិសទាំងបួនមានគោបុរៈបួន (គោបុរៈបីជាទ្វារបញ្ឆោត) ជញ្ជាំងគោបុរៈនីមួយៗលម្អដោយបដិមាទេពអប្សរឈរអមក្លោងទ្វារ ចម្លាក់ក្បាច់ត្របកឈូក ក្បាច់ចក ក្បាច់ផ្កាច័ន្ទ ក្បាច់ភ្ញី ព្រមទាំងចម្លាក់រូបទេពតូចៗនៅក្នុងក្បាច់សន្លឹកផងដែរ។ ផ្តែរទ្វារបញ្ឆោតខាងលិចលម្អដោយចម្លាក់ពុទ្ធបដិមាចំនួន៥អង្គ ស្ពានហាលសង់ពីថ្មភក់លម្អដោយបង្កាន់ដៃសនាគមានក្បាល៥មានមុខសងខាង ទ្រពីក្រោមដោយនរសិង្ហជើងជណ្តើរពីមុខក្បាលនាគ មានបណ្តោយប្រហែលជាង១៥ម៉ែត្រ និងទទឹងប្រហែល៣ម៉ែត្រ។ ចំណែកនៅផ្នែកខាងក្រោមបដិមាដំរីបន្តិច គឺមានបដិមាសត្វតោនៅតាមជ្រុងនីមួយៗ និងនៅអមសងខាងជណ្តើរគ្រប់ទិសផងដែរ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានជួសជុលបន្តិចបន្តួចនិងលើកបដិមាដំរីទៅដាក់នៅលើខឿនប្រាសាទឡើងវិញ។

## ៣. សិល្បៈចម្លាក់នៅប្រាសាទបាកាណ

ចម្លាក់នៅលើប្រាសាទបុរាណ និងនៅតាមសំណង់បុរាណនានា នៃរមណីយដ្ឋានបុរាណវិទ្យាបាកាណ គឺជាមរតកដ៏មានគុណតម្លៃបន្ថែមទៀតទៅលើរចនាបថ សិល្បៈស្ថាបត្យកម្មប្រាសាទ និងហេដ្ឋារចនាសម្ព័ន្ធនានា។ នៅក្នុងរចនាបថស្ថាបត្យកម្ម ក្បាច់ចម្លាក់ ការតុបតែងលម្អលើប្រាសាទ បានដើរតួសំខាន់ក្នុងការបញ្ជាក់អំពីតួនាទី និមិត្តរូប និងទស្សនៈរបស់អ្នកកសាងប្រាសាទឬសំណង់នោះ។ ដូច្នេះហើយបានជានៅតាមប្រាសាទបុរាណនានា វិចិត្រករតែងឆ្លាក់នូវចម្លាក់បដិមាទាក់ទងនឹងរឿងរ៉ាវ

---
[9] Brigg. *Ibid*. 1951

ផ្សេងៗនៅលើជញ្ជាំងប្រាសាទ ផ្តែរទ្វារ សសរពេជ្រ ហោជាង។ល។ គេឆ្លាក់ចម្លាក់ និងក្បាច់លម្អទាំងនោះទៅតាមនិន្នាការទស្សនៈសាសនានិងគោលបំណងនៃប្រាសាទនីមួយៗ។ ចម្លាក់ដែលឆ្លាក់នៅលើប្រាសាទ ឬសំណង់បុរាណ មិនមែនសម្រាប់ការលម្អធម្មតានោះទេ ប៉ុន្តែចម្លាក់មានពាក់ព័ន្ធនឹងនិមិត្តរូបនៃជីវិតរបស់ប្រាសាទ និងអទិទេពនៅលើផែនដី។ ហើយចម្លាក់ទាំងនោះក៏មិនមែនសម្រាប់បម្រើការទស្សនានោះដែរ[10]។ ចម្លាក់បដិមារបស់ក្រុមប្រាសាទបាកាណបានបង្ហាញនូវកំរិតកំពូលនៅក្នុងប្រវត្តិនៃសិល្បៈខ្មែរ។

ប្រាសាទភាគច្រើនសាងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ធ្វើឱ្យយើងយល់បានថា ទាំងប្រាសាទ និងចម្លាក់ហាក់មានទំនោរទៅរកទស្សនៈបែបព្រះពុទ្ធសាសនា ដែលស្ថិតក្នុងរចនាបថបាយ័ន។ នៅក្នុងសម័យកាលនេះ ប្រាសាទនិងចម្លាក់សុទ្ធតែបង្ហាញនូវភាពអស្ចារ្យនិងមានទំហំធំៗ ក្នុងន័យបង្ហាញនូវអំណាចរបស់ព្រះមហាក្សត្រនាពេលនោះ។ លក្ខណៈពិសេសនៃសិល្បៈស្ថាបត្យកម្មនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ គឺប្រាង្គសាទជាព្រះភ័ក្រលោកេស្វរៈ (ព្រហ្មមុខបួន) ចម្លាក់បដិមាសត្វគ្រុឌធំៗ ចម្លាក់ ដំរីក្បាលបី ចម្លាក់សត្វហង្សធំៗ ចម្លាក់នរសិង្ហ និងចម្លាក់ពុទ្ធបដិមា ជាដើម។ ក្នុងអត្ថបទជាបន្តនេះខ្ញុំនឹងលើកមកបង្ហាញអំពីចម្លាក់ពីរប្រភេទគឺចម្លាក់សត្វហង្ស និងចម្លាក់រឿងជាតក ដែលបានឆ្លាក់នៅក្រុមប្រាសាទបាកាណផង និងឃើញមាននៅប្រាសាទធំៗនៅតំបន់អង្គរផង។

### ៣.១. ចម្លាក់សត្វហង្ស

នៅក្នុងទេវកថា សត្វហង្ស ជាបក្សីទេពមួយនៅក្នុងព្រហ្មញ្ញសាសនា ដែលមានតួនាទីជាជំនិះរបស់ព្រះព្រហ្ម។ នៅក្នុងព្រះពុទ្ធសាសនាវិញ សត្វហង្ស គឺតំណាងឱ្យការផ្សព្វផ្សាយនូវលទ្ធិពុទ្ធសាសនា [11] ។ ដោយសាររោមនិងស្លាបមានពណ៌ស ទើបសត្វហង្សបានក្លាយនិមិត្តរូបនៃភាពបរិសុទ្ធនិងឫទ្ធិអំណាចដ៏អស្ចារ្យ។ សត្វហង្សមានសំបុកជាជម្រកនៅលើកំពូលភ្នំហិមាឡៃ ដែលគេជឿថាទីនោះគឺជាដែនដីរបស់ពួកអាទិទេពទាំងឡាយគង់នៅ។ ហង្សក៏ជានិមិត្តរូបក្នុងការបែងចែករវាងសភាវៈល្អនិងសភាវៈអាក្រក់ និងការកំចាត់បង់នូវពពួកមនុស្សដែលមានភាពរើសអើងផងដែរ[12]។

ចម្លាក់សត្វហង្ស ឃើញមាននៅច្រើនកន្លែងលើសំណង់នានាក្នុងក្រុមប្រាសាទបាកាណ។ ចម្លាក់សត្វហង្សទាំងនោះអាចចែកជាពីរប្រភេទគឺ ចម្លាក់សត្វហង្សក្បាលបីដែលមានមាឌធំៗ និងចម្លាក់សត្វហង្សឆ្លាក់លម្អនៅលើផ្តែរទ្វារប្រាសាទដែលមានទំហំតូចៗ។

### ចម្លាក់សត្វហង្សក្បាលបី

ហង្សក្បាលបី ជាចម្លាក់ក្រឡោតទាប ត្រូវបានគេឆ្លាក់នៅតាមជញ្ជាំងស្ពានឆ្លងកសិណទឹកច្រកចូលក្លោងទ្វារខាងកើតនៃប្រាសាទបាកាណ និងនៅជញ្ជាំងស្ពានកំពង់ទឹកខាងមុខប្រាសាទព្រះស្ទឹង នៅលើមាត់ទឹកបារាយណ៍តជាក។ លក្ខណៈសិល្បៈនៃហង្សក្បាលបីនៅទីតាំងទាំងពីរគឺដូចគ្នា

---

[10] Vittorio Roveda. *Khmer mythology*, Printed and bounded in Thailand, 1997, p.22

[11] Vittorio Roveda. Ibid, p. 173; Michael Freeman and Claude Jacques. *Book guide: Ancient Angkor*, Thailand, 1999, p. 234.

[12] Lochtefeld, James G., *The illustrated encyclopedia of Hinduism*, New York, 2002, p. 270-71

ទាំងការរចនាតុបតែងលម្អលើតួខ្លួនសត្វហង្ស។ ហង្សនីមួយៗមានក្បាលបី ឈរហាក់បីដូចកំពង់លើកទ្រស្ពានថ្មដ៏ធ្ងន់កុំឱ្យរលំបាក់ឬដួល។ ទាំងដងខ្លួន និងក្បាលហង្សមានតុបតែងដោយគ្រឿងអលង្ការ និងផ្ការំយោល យ៉ាងស្រស់ស្អាត។ ចម្លាក់ហង្សក្បាលបីទាំងនេះមានទំហំធំៗ និងមានកម្ពស់ពេញមួយជំហរមនុស្ស។ ចម្លាក់ហង្សក្បាលបីធំៗបែបនេះកម្រឃើញមាននៅកន្លែងដ៏ទៃទៀតៗនៅកម្ពុជា។ នេះជាលក្ខណៈពិសេស មួយនៅក្នុងប្រវត្តិសាស្ត្រនិងរចនាបថសិល្បៈបាយ័ននៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។



*រូបខាងលើ៖ ចម្លាក់សត្វហង្សទ្រស្ពានកំពង់ទឹក នៅប្រាសាទព្រះស្ទឹង*



*រូបខាងលើ៖ ស្ពានឆ្លងកសិណទឹកទៅកាន់គោបុរៈខាងកើតនៃប្រាសាទបាណ*





*ចម្លាក់សត្វហង្សក្បាលបីឈរទ្រស្ពានឆ្លងកសិណទឹកប្រាសាទបាកាណ គោបុរៈខាងកើត*

### ចម្លាក់សត្វហង្សតូចៗ

សត្វហង្ស ហាក់មានតួនាទីសំខាន់ក្នុងរចនាបថសិល្បៈនៃក្រុមប្រាសាទបាកាណ។ ក្រៅពីចម្លាក់ សត្វហង្សក្បាលបីធំៗដូចបានបង្ហាញរួចមកហើយនោះ សត្វហង្សតូចៗក្បាលមួយក៏ត្រូវបានឆ្លាក់នៅលើផ្តែរទ្វារនៃប្រាង្គប្រាសាទបាកាណសំខាន់ៗផង។ ជាទូទៅផ្តែរទ្វារប្រាសាទ ជាទីតាំងសំខាន់របស់ប្រាសាទបុរាណដែលជាកន្លែងគេតែងឆ្លាក់បង្ហាញនូវចម្លាក់ទេវកថា និងក្បាច់លម្អផ្សេងៗទៅតាមរចនាបថសិល្បៈនៃសម័យកាលនីមួយៗក្នុងប្រវត្តិសិល្បៈខ្មែរ។ ចម្លាក់សត្វហង្សតូចៗទាំងនោះត្រូវបានឆ្លាក់ក្នុងទម្រង់ផ្សេងៗគ្នា ដូចជា សត្វហង្សស្ថិតនៅក្នុងរង្វង់ក្បាច់សន្លឹក និងមានទេព (ព្រះព្រហ្ម) ជិះពីលើខ្នង ឬជិះតោងកហង្ស និងចម្លាក់ហង្សខ្លះទៀតហ៊ុំព័ទ្ធរំលេចជារង្វង់ផ្កាភ្ញីយ៉ាងស្រស់ស្អាត។




*ចម្លាក់ហង្សដែលឆ្លាក់ម្អនៅលើផ្តែរទ្វារ និងស៊ុំទ្វារ នៃប៉មសំខាន់នៃប្រាសាទបាកាណ*




### ៣.២. ចម្លាក់រឿងជាតក

ជាតក ជារឿងរ៉ាវពីអតីតជាតិរបស់ព្រះពុទ្ធដែលបានយោនយកកំណើតជាមនុស្ស ជាសត្វ ឬជាទេពផ្សេងៗច្រើនជាតិមុននឹងព្រះអង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ជាតកជារឿងដែលព្រះពុទ្ធបានលើកមកសម្តែងអំពីជាតិកំណើតរបស់ទ្រង់កាលនៅជាតិជាព្រះពោធិសត្វ ដើម្បីធ្វើជាឧទាហរណ៍អប់រំដល់ព្រះសាវ័កនិងពុទ្ធបរិស័ទដើម្បីកសាងបុណ្យបារមីបានត្រាស់ដឹងធម៌ [13] ។ រឿងជាតក មានតួ

[13] ទៀវ វិចិត្រ៖ *ចម្លាក់រឿងជាតកលើប្រាសាទបុរាណខ្មែរ,* គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត, ខែមេសា គ.ស.២០១១,

នាទីជាគោលសំខាន់សម្រាប់ប្រើប្រាស់ជាឧទាហរណ៍ក្នុងការអប់រំពុទ្ធបរិស័ទ និងសង្ឃសាវ័កឱ្យដើរតាមឱវាទដ៏ត្រឹមត្រូវសុច្ចរិតរបស់ព្រះពុទ្ធ។ នៅក្នុងជំនឿព្រះពុទ្ធសាសនា រឿងជាតកមានភាពល្បីល្បាញណាស់ ដូចនេះហើយ ទើបសម័យបុរាណ ពិសេសក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ រឿងជាតកជាច្រើនត្រូវបានឆ្លាក់នៅលើ ប្រាសាទរបស់ទ្រង់។ ក្នុងចំណោមចម្លាក់រឿងជាតកដ៏ច្រើន ខ្ញុំនឹងលើកយកចម្លាក់រឿង "**ភូរិទត្តជាតក**" មកបង្ហាញ ដោយចម្លាក់រឿងភូរិទត្តនេះឃើញមានឆ្លាក់នៅលើក្លោងទ្វារធំខាងកើតនៃប្រាសាទបាកាណ។ ហើយចម្លាក់រឿងទូរិទត្តជាតកនេះក៏ឃើញមានឆ្លាក់នៅលើប្រាសាទធំៗនៅតំបន់អង្គរផងដែរ ដូចជា ចម្លាក់ភូរិទត្តជាតកនៅលើហោជាងនៃប្រាសាទតាព្រហ្ម (អង្គរ) ចម្លាក់ភូរិទត្តនៅលើផ្តែរមួយនៃប្រាសាទបន្ទាយក្តី និងចម្លាក់ភូរិទត្តជាតកនៅលើហោជាងប្រាសាទព្រះខ័ន (អង្គរ)។



នេះជាផ្ទាំងចម្លាក់រឿង "ភូរិទត្តជាតក" នៅលើហោជាងមុខខាងត្បូងនៃក្លោងទ្វារខាងកើត កំពែងខាងក្រៅ (ផ្នែកខាងក្នុង)។ ចម្លាក់នេះចែកជាពីរផ្នែក គឺនៅជួរខាងលើឃើញគ្រុឌមួយកំពង់ហោះ។ នៅជួរខាងក្រោមគឺមានពួកនាងនាគីចំនួនបីនាក់អង្គុយបត់ជើងលើកដៃប្រណម្យ។

ខាងក្រោមនេះជាចម្លាក់រឿង "ភូរិទត្តជាតក" ដែលឆ្លាក់នៅលើផ្តែរ និងហោជាងនៃប្រាសាទធំៗ កសាងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដូចជា ប្រាសាទបន្ទាយក្តី ប្រាសាទព្រះខ័ន និងប្រាសាទតាព្រហ្ម[14] ។

---

ទំព័រ ១៦-17

[14] ប្រភពរូបចម្លាក់រឿង "ភូរិទត្តជាតក" ស្រង់ពី ទៀវ វិចិត្រ៖ ដ-ឯ-ម. ទំព័រ៥៨ - ៦៣











ចម្លាក់លើហោជាងខាងលិច

ប្រាង្គឦសាន នៃប្រាសាទតាព្រហ្ម



ចម្លាក់នៅលើផ្តែរក្លោងទ្វារខាងលិច

ប្រាង្គកណ្តាលនៃប្រាសាទបន្ទាយក្តី

## សង្ខេបរឿងភូរិទត្តជាតក[15]

ក្នុងអតីតជាតិមួយ មានព្រះពោធិសត្វមួយអង្គ ព្រះនាមថា ភូរិទត្ត(ជាកំណើតនាគឈ្មោល) ដែលជាអង្គប្រកបដោយទឹកចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនាណាស់។ ដោយហេតុនេះទ្រង់ក៏បានសូមព្រះវររាជបិតា និងមាតា ដែលសោយរាជ្យសម្បត្តិនៅនគរភុជង្គនាគ ដើម្បីយាងទៅកាន់សីល។ ប៉ុន្តែជារៀងរាល់ថ្ងៃព្រះអង្គត្រូវរំខានដោយពពួកនាគី(ជាតួអង្គនាគញី) តែងមកថ្វាយកម្រងផ្កាមិនឈប់ឈរ

[15] ទៀវ វិចិត្រ៖ ដ-ឯ-ម, ទំព័រ ៥៤-៥៥

សោះ ប្រហែលជាក្នុងន័យប្រាថ្នាចង់ប្រលោមស្នេហ៍ជាមួយ។ ម្ល៉ោះហើយព្រះបុត្រានាគក៏សម្រេចព្រះទ័យយាងទៅស្ថានមនុស្សម្តងដើម្បីកាន់សីលបន្តនៅតាមដងព្រៃភ្នំ។ ទោះបីជាយ៉ាងនេះក្តី នៅឯឋានមនុស្សក៏មិនប្រាកដថាស្ងប់ស្ងាត់នោះដែរ ព្រោះថាពពួកនាគក៏ឧស្សាហ៍ឡើងមកកំសាន្ត រីឯមនុស្សម្នាក៏តែងធ្វើដំណើររុកព្រៃបរបាញ់សត្វជាអាហារ។

ថ្ងៃមួយនោះក្នុងខណៈដែលព្រះអង្គកំពុងភាវនាធម៌ស្រាប់ តែមានមាណពម្នាក់បានមកដល់ទីនោះ។ ឃើញដូច្នេះ ព្រះពោធិសត្វក៏នាំមាណពនោះ ទៅកាន់ស្ថាននាគកំសាន្តលេងមួយរយៈពេលដ៏ខ្លីសិន។ នៅគ្រាមួយមានស្តេចគ្រុឌដែលជាសត្រូវតពូជជាមួយនាគក៏បានដេញចាប់ពួកនាគ ជាហេតុធ្វើឱ្យអាស្រមឥសីម្នាក់ខូចខាត។ ដើម្បីលុបលាងនូវបាបកម្មដែលបណ្តាលមកពីអំពើមិនគប្បី គ្រុឌនោះបានថ្វាយគាថាចាប់ពស់ដ៏សក្តិសិទ្ធទៅតាបសឫសីនោះជាសំណង។ ក្រោយមកឥសីនោះមានសិស្សម្នាក់ សិស្សនោះក៏បានរៀនក្បួនយុទ្ធសីលចាប់ពស់នោះតាបស។ បានរៀនចប់សព្វគ្រប់ ក៏មានបំណងទៅចាប់ព្រះពោធិសត្វភូរិទត្តយកទៅសម្តែងតាមតំបន់ផ្សេងៗឱ្យអ្នកស្រុកមើលដើម្បីបានប្រាក់។

ដំណឹងនេះបានឮដល់ព្រះវររាជបិតានិងមាតា ស្តេចទាំងពីរអង្គក៏បានត្រាស់បង្គាប់ឱ្យព្រះរាជបុត្រានាគទាំងឡាយឱ្យទៅជួយសង្គ្រោះព្រះភូរិទត្តពីគ្រោះភ័យ។ នៅទីបញ្ចប់បុរសចេះមន្តអាគមអាលម្ពាយ ត្រូវបានផ្ចាញ់ហើយព្រះពោធិសត្វក៏ត្រូវរំដោះបាន។ ពេលយាងត្រឡប់មកដល់ភពកុជង្គនាគវិញ ព្រះភូរិទត្តទ្រង់ក៏បានប្រទានការសម្តែងធម៌ទេសនា ដើម្បីឱ្យព្រះរាជវង្សានុវង្សផុតពីទុក្ខ។

## ៤.សេចក្តីសន្និដ្ឋាន

រមណីយដ្ឋានបុរាណវិទ្យាបាកាណ ព្រះខ័ន)-កំពង់ស្វាយគឺជាអតីតរាជធានីមួយនៃសម័យ (ទី១៣។ រចនាបថសិល្បៈស្ថាបត្យ.វ.ទី១១ដល់ស.វ.អង្គរ ដែលបានស្ថាបនាឡើងប្រហែលនៅវាំងពីសកម្ម និងចម្លាក់អាចបញ្ជាក់ឱ្យយើងយល់ថា ប្រាសាទសំខាន់ៗ និងហេដ្ឋារចនាសម្ព័ន្ធបុរាណភាគច្រើនត្រូវបានសាងសង់ក្រោមការគ្រប់គ្រង និងឥទ្ធិពលបែបព្រះពុទ្ធសាសនាដែលជាទស្សនៈដឹកនាំរបស់បាទជ័យវរ្ម័នទី៧។ ទស្សនៈនេះត្រូវបានបង្ហាញតាមរយៈស្នាដៃខាងវិស័យសិល្បៈស្ថាបត្យកម្មសំណង់និងប្រាសាទទាំងឡាយដែលមានទំហំធំៗ ជានិមិត្តរូបនៃភាពអស្ចារ្យនិងភាពរឹងមាំនៃប្រទេសកម្ពុជាសម័យនោះ។ តំបន់ប្រាសាទបាកាណគឺជាមូលដ្ឋានយុទ្ធសាស្ត្រដ៏រឹងមាំនៃព្រះបាទជ័យវរ្ម័នទី៧ មុនពេលព្រះអង្គលើកទ័ពទៅកំចាត់ទ័ពចាមឈ្លានពាននៅយសោធរ។ ស្លាកស្នាមទាំងនោះ បានគ្របដណ្តប់ស្ទើរតែទាំងស្រុងនៅក្នុងតំបន់ប្រាសាទកាណ។ ប្រាសាទបុរាណ និងចម្លាក់បដិមាបុរាណជាច្រើនដែលត្រូវបានរកឃើញនៅស្ថានីយបុរាណវិទ្យាមួយនេះ បានបង្ហាញនូវកំរិតរីកចម្រើនដល់កំពូលក្នុងសម័យកាលមួយនៃសិល្បៈខ្មែរ។

សម្បត្តិវប្បធម៌ដ៏ច្រើននៅក្នុងអតីរាជធានីបាកាណ ដូចបានពោលមកហើយនេះ គឺជាប្រភពនៃធនធានសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិប្រកបដោយគុណតម្លៃ និងសក្តានុពលសម្រាប់បម្រើដល់វិស័យវប្បធម៌ ទេសចរណ៍ និងសេដ្ឋកិច្ចជាតិ។ ដូច្នេះហើយសម្បត្តិដែលមាននៅក្នុងរមណីយដ្ឋានបុរាណវិទ្យាបាកាណបច្ចុប្បន្ន គឺត្រូវតែទទួលបានការការពារ ការអភិរក្ស និងគ្រប់គ្រងឱ្យមានសុវត្ថិភាពល្អ ប្រកបដោយចីរភាពដូចគ្នានឹងសម្បត្តិបេតិកភណ្ឌវប្បធម៌នៅរមណីយដ្ឋានបុរាណវិទ្យានានានៅកម្ពុជាដែរ៕

## ឯកសារយោង

រស់ ចន្ទ្រាបុត្រ៖ *ប្រាសាទព្រះខ័នកំពង់ស្វាយ,* រាជបណ្ឌិត្យសភាកម្ពុជា, ខែធ្នូ គ.ស.២០០៥

ទៀ វិចិត្រ៖ *ចម្លាក់រឿងជាតកនៅប្រាសាទបុរាណខ្មែរ* , គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត,

ខែមេសា គ.ស.២០១១

ហៀង លាងហុង សូត្រ សំណាង ឈឹម សុខាន់ដារ៉ា យិន យ៉ង់ និង ជួន សោរិទ្ធី ៖ របាយករណ៍ស្រាវជ្រាវស្ដីពី «បច្ចុប្បន្នភាពនៃតំបន់ប្រាសាទព្រញខ័នកំពង់ស្វាយ » ខែកញ្ញា ឆ្នាំ២០១៣

ទី សារឿន៖ «ប្រាសាទចតុមុខពីភាពរប៉ាត់រប៉ាយ មកក្លាយជារូបសំណាកព្រះពុទ្ធរូបដ៏ធំមួយយ៉អង្គ» ថ្ងៃសៅរ៍ ទី២១ ខែកក្កដា ឆ្នាំ២០១៨,នៅក្នុង៖ *http://spktliv.com/archives/3222*

Henri Mauger. Preah Khan de Kompong Svay, *BEFEO* Tome XXXIX 1939

Briggs L. Palmer, The Ancient Khmer Empire, Philadelphia, 1951.

Vittorio Roveda. *Khmer mythology,* Printed and bounded in Thailand, 1997

Michael Freeman and Claude Jacques. *Book guide: Ancient Angkor*, Thailand, 1999
Lochtefeld, James G., *The illustrated encyclopedia of Hinduism*, New York, 2002

# "មរតកវប្បធម៌សិល្បៈខ្មែរ តាមសម័យកាល"

រៀបរៀងដោយ

លោក **ភុល សារុ** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ

នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងលោកសាស្ត្រាចារ្យ **ឡោ សាន**

## ១)សេចក្តីផ្តើម

ប្រវត្តិវិទូក្នុងពិភពលោកអះអាងស្រដៀងគ្នានូវពាក្យ **បុរេប្រវត្តិសាស្ត្រ** ដែលប្រជាជាតិនានាក្នុងពិភពលោកបានសិក្សាស្រាវជ្រាវ។

ជាក់ស្តែង នៅប្រទេសកម្ពុជា ក្រុមបុរាណវិទូ បានធ្វើកំណាយនៅស្ថានីយ៍មួយចំនួនមានៈ

**សំរោងសែន** គឺលោក **ម៉ាន់ ស៊ុយ** ឆ្នាំ១៨៧០-១៨៧៩និង

**ម្លូព្រៃ** គឺលោក**ម៉ូឡេរី** ឆ្នាំ១៨៧០-១៨៧៩ ។

**ល្អាងស្ពាន** គឺលោក **ម៉ួលរ៉េ** ឆ្នាំ១៨៧០-១៨៧៩។

**នៅឆ្នាំ១៩៥៩** លោក **លីម៉ាឡឺរ** រកឃើញភូមិមូលចំនួន១៧ ទីតាំងមេមត់(ដីក្រហម)[16]។

**នៅឆ្នាំ១៩៦២** លោក **ប៉ែកណាហ្វីលីប ហ្គ្រោលីយេ** ដាក់ឈ្មោះ "អរិយធម៌មេមត់" ភូមិមូលបុរេប្រវត្តិសាស្ត្រមានចំនួន ៣៦កន្លែង មានអាយុជិត ១.០០០ឆ្នាំមុន គ.ស។ ភូមិមូលនេះមានអង្កត់ផ្ចិត ១៥០ម។

**នៅឆ្នាំ២០០៣** បារាំងមួយក្រុម តាមរូបពីអាកាស បានរុករកឃើញនៅជើងឯកជិតមជ្ឈមណ្ឌលប្រល័យពូជសាសន៍ខ្មែរក្រហម សល់ស្នាមភូមិមូលយ៉ាងធំមានអង្កត់ផ្ចិត៨០០ម។ បុរេប្រវត្តិសាស្ត្រ បន្សល់វប្បធម៌ភូមិមូល បញ្ជាក់នូវស្មារតីសាមគ្គី ផ្លូវកាយ ផ្លូវចិត្ត ផ្លូវវាចា និងផ្លូវសម្ភារៈទៀតផង ពិតជាមានផែនការ មានវិន័យ និងការគ្រប់គ្រងហ្មត់ចត់ ដើម្បីសមូហភាព ទេពកោសល្យនិម្មាបនកម្ម និងសំណង់។

## ២)សម័យប្រវត្តិសាស្ត្រ

សម័យប្រវត្តិសាស្ត្រកម្ពុជាមានប្រវត្តិសាស្ត្រចាប់ពីស.វ.ទី១នៃគ.ស. ហើយត្រូវបានបែងចែកជាបីសម័យកាលៈ

I)សម័យមុនអង្គរ ស.វ.ទី១-គ.ស.៨០២

II)សម័យអង្គរ គ.ស.៨០២-គ.ស.១៤៣១

[16]គណៈកម្មាការវប្បធម៌កម្ពុជា ប្រវត្តិសាស្ត្រកម្ពុជា ឆ្នាំ២០០៨

III)សម័យក្រោយអង្គរ គ.ស.១៤៣១ មក

**I. សម័យមុនអង្គរ (បុរេអង្គរ) ចែកជាពីរសម័យៈ**

១.១. សម័យនគរភ្នំ ឬ ហ្វូណន ពីស.វ.ទី១-គ.ស.៥៥០

១.២. សម័យចេនឡា គ.ស.៥៥០-គ.ស.៨០២

ខ្មែរហៅប្រទេសរបស់ខ្លួនថា "**នគរភ្នំ**"។

ចិនអាន ឬក៏ហៅតាមភាសាខ្មែរមិនច្បាស់ទៅជាឮសូ "**ហ្វូណន**" វិញ។

នៅស.វ.ទី២ ភូមិវិទូ រ៉ូម៉ាំង បានចូលមកស្នាក់នៅកំពង់ផែខ្មែរ មួយរយៈក៏ផ្សាយ ថាអូកែវជាកិត្តិនគរ ផែអន្តរជាតិរកស៊ីជាមួយមហាប្រទេសចិន មហាប្រទេសឥណ្ឌា និងចក្រភពរ៉ូម៉ាំង តាមផ្លូវសមុទ្រ។

នៅស.វ.ទី៣ ការទូតចិន ឈ្មោះ កាំង តៃ និងជូ យិង ស្នាក់នៅអង្គរបុរី កត់ត្រាកំពែងទីក្រុង សំណង់រាជវាំង ទំនប់ជារាសាស្ត្រ ព្រែកជីក កសិកម្ម សិប្បកម្ម ជំនឿសាសន៍ បង់ពន្ធ ចេះធ្វើសំពៅ ហើយមានស្តេចស្រី ព្រះនាម **នាងនាគ** (លីវ យី ឬសោមា) និងស្តេចប្រុសព្រះនាម **ព្រះថោង** (ហ៊ុនទៀន ឬកៅណ្ឌិន្យ)។

**ចំណុចទី១** បាននិមន្តព្រះសង្ឃពីអេង្គ សង្ឃបាល **នាគសេន** ទៅជួយបកគម្ពីរព្រះត្រៃបិដករយៈពេល១៦ឆ្នាំ។

**ចំណុចទី២** ខ្មែរបានបញ្ជូនវង់ភ្លេងទៅចិន ប្រគុំថ្វាយអធិរាជចិន ដោយរាំកើបជាមួយបទភ្លេងនិងចម្រៀង បន្ទាប់មកស្តេចក៏បញ្ជារឲ្យបង្កើតវិទ្យាស្ថានតន្ត្រី **ហ្វូណន** នៅជិតក្រុង។

**១.១.សម័យនគរភ្នំ ឬ ហ្វូណាន ពីស.វ.ទី១-គ.ស.៥៥០**

លោក **គ្រូលីយេ** អះអាងថា កោះគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ ជាមជ្ឈមណ្ឌលផ្សព្វផ្សាយ ជំនឿ សាសនាសម័យ **នគរភ្នំ** មានៈ

-បដិមាព្រះពុទ្ធ ប្រក់នាគ (ពុទ្ធនិយម)

-ខ្ទមអ្នកតា (ជីវចលនិយម)

-លិង្គព្រះឥសូ (ព្រហ្មនិយម និងវិស្ណុនិយម)

-បដិមាវិស្ណុដៃ៨ពីថ្មកក់ ២.៧០ម និងប្រាសាទភ្នំដា ប្រាសាទអាស្រមមហាឥសី មានវត្ត រំលកវត្តគំនូរ ជាទីកន្លែងកសាងធនធាននបញ្ញាញាណ ។ កត្តាចម្បងៗទាំងនេះទើបអ្នក នគរភ្នំ ជោគជ័យលើគ្រប់ វិស័យទាំងចំណេះដឹង ចំណេះគិត តាមនយោបាយ "**សុខដុមនីយកម្មខាងជំនឿជីវចលនិយម និងសាសនា**"[17]។

---

[17] គណៈកម្មាការវប្បធម៌កម្ពុជា ប្រវត្តិសាស្ត្រកម្ពុជា ឆ្នាំ២០០៨

**១.២. សម័យចេនឡា គ.ស.៥៥០-គ.ស.៨០២**

គឺជាអាណាចក្ររបស់ជាតិខ្មែរ នៅខាងជើងជួរភ្នំដងរែក និងវាលទំនាបភាគកណ្តាលនៃទន្លេមេគង្គ។ រាជធានី **ស្រេដ្ឋបុរៈ** នៅតំបន់ចម្ប៉ាសាក់ លាវសព្វថ្ងៃ។ ចាប់ពីគ.ស.៥៥០ សម័យនគរភ្នំ ត្រូវបានជំនួសដោយសម័យចេនឡា ពីព្រោះស្តេចមានបញ្ញាញាណខ្ពស់រួមរស់ឯកភាពគ្នា ទឹកដីធំទូលំទូលាយទល់មហាសាគរប៉ាស៊ីហ្វិក នៅទិសខាងត្បូង និងប្រទេសចិននៅទិសខាងជើង។ មរតកវប្បធម៌ទី១ គឺកំណើតពាក្យ **ខ្មែរ** មកពីការផ្សំគ្នារវាងពាក្យ **កម្ពុ** និង **មេរា** ឥសី **កម្ពុ** និងនាងទេពអប្សរ **មេរា** បង្កើតរាជវង្សចេនឡា ប្រកបដោយកិត្យានុភាពដ៏អស្ចារ្យ (កម្ពុ +មេរា > កម្ពុ+មេរ > កមព+មេរ > កម+មេរ > កមេរ > ក្មេរ =ខ្មែរ)។

មរតកវប្បធម៌ទី២ របាំអប្សារា ឬរបាំទេពអប្សរ ប្រភពចេញពីនាងទេពអប្សរ "**មេរា**" មហេសីរបស់ឥសី "**កម្ពុស័យម្ភូវ**" ដែលប្រកបដោយលក្ខណៈអច្ឆរិយៈ។

ដូច្នេះ**មរតកវប្បធម៌ខ្មែរ** មុនសម័យអង្គរមានច្រើន ខ្ញុំសូមបង្ហាញបីពេលនេះ៖

១)កំណាព្យ មានរបៀបសរសេរ ៥៣បែប និងរបៀបសូត្រ៦០បែប។ ចំពោះ **បទបឋ្យាវត្ត** គឺជាបទមេបួន មានតែមួយគត់មុនសម័យអង្គរៈ ខ្ញុំសូមដកស្រង់មួយល្បះដូចខាងក្រោះ

ខ្ញុំសូមបង្គំ ចំពោះព្រះពុទ្ធ
ទ្រង់គង់ខ្ពស់ផុត លើត្រៃលោកា។

២)បទភ្លេងអារក្ខ មានចំនួន ៥៦ បទ សម្រាប់ជំនឿអារក្ខ អ្នកតា លៀងអារក្ខ...

៣)បទភ្លេងប្រពៃណី ឬភ្លេងការមាន១៣៣បទសម្រាប់ពិធីអាពាហ៍ពិពាហ៍ដ៏សំខាន់បំផុតសម្រាប់ជីវិតកូនប្រុស-កូនស្រី ឧទាហរណ៍៖ បទព្រះថោងនាងនាគ។

**II. សម័យអង្គរ គ.ស.៨០២-គ.ស.១៤៣១**

**គូលេន** ជាចំណុចចាប់ផ្តើមនៃសម័យអង្គរ។

ជ័យវរ័ន្មទី២ ជាមហាក្សត្រសម័យអង្គរមុនដំបូងគេបានរៀបចំ "**ឯកភាព**" ជំនឿ សាសនា ទឹកដី។ **រាជធានីទី១** (មហេន្ទ្របព័ត) ប្រកាសឯករាជលើភ្នំធម្មជាតិ។

-ប្រកាន់របបនយោបាយ "**លទ្ធិទេវរាជ**"

-ឋានៈជាស្តេចលើស្តេចនានា(ស្តេចចក្រវាឡ) កសាងទំនប់ទឹក ចម្លាក់ កូនបដិមា លិង្គព្រះឥសូរ លិង្គ១ពាន់ និងសំណង់ប្រាសាទជាង៤០ទីតាំង។

-រុក្ខជាតិនៅភ្នំគូលេនជាឱសថបុរាណចាំបាច់

-ទឹកពីលើភ្នំគូលេនផ្តល់មកស្ទឹងសៀមរាបជានិច្ច ជាស្ទឹងស័កសិទ្ធិ

-តម្លៃនៃរបាំត្រុដិរបស់ជនជាតិសម្រែ មុនពេលចូលឆ្នាំកាន់ចិត្តបរិសុទ្ធ ។

**ក-ប្រាសាទព្រះគោ រាជស្តេច ឥន្ទ្រវរ័ន្មទី១** រាជធានីហរិហរាល័យ (**រលួស**)

-ជីកបារាយណ៍ ៣០០០x ៨០០ " **ឥន្ទ្រតដាក**"

-កសាងប្រាសាទព្រះគោ " វប្បធម៌កតញ្ញូ"

-ការដឹកនាំ គិតគូរប្រជារាស្ត្រ(បារាយណ៍)

-រំលឹកគុណមាតាបិតា

-រាជគ្រូ

-កសាងប្រាសាទរាជ "**បាគង**" ថ្មភក់មុនគេប្រាសាទនៅវាលទំនាបជាប្រាសាទភ្នំមុនគេ ប្លង់Pyramide ៥ជាន់ កំពែង និងកសិណទឹកព័ទ្ធជុំវិញ។

**ខ-ប្រាសាទអង្គរវត្ត សូរិយាវរ្ម័នទី២** (១១១៣-១១៥០)

ជាប្រាសាទដ៏អស្ចារ្យដែលមានកសិណទឹកព័ទ្ធជុំវិញ៖

-លិច-កើត=១.៥០០ម

-ជើង-ត្បូង=១.៣០០ម

-ទទឹងផ្ទៃទឹក១៩០ម

-មានកំពូលប្រាំ

-មានបីជាន់

-កំពូលកណ្តាលកម្ពស់ ៦៥ ម

-ស្ពានថ្ម=២៥០ម។

-ឆាកសម្តែងសិល្បៈ (ក្តាបែនឬសញ្ញាជើងក្អែកឬសញ្ញាកាកបាតក្រហម)។

ដូច្នេះ**មរតកវប្បធម៌សិល្បៈខ្មែរ និងកិត្យានុភាពជាតិ** សម័យអង្គរមានច្រើន ខ្ញុំសូមបង្ហាញពីរ ពេលនេះ៖

**១)របាំអប្សរា**





**២)សិលាចារិក** K 292 ទាក់ទងនឹងពិធីសច្ចាប្រណិធាន និងផឹកទឹកសម្បថសូរិយាវរ្ម័នទី១ (១០១០-១០៥០)





## III. សម័យក្រោយអន្តរចាប់ពីគ.ស.១៩៣១ មក

### ៣.១. ប្រវត្តិបទភ្លេង "នគរពទង់ជាតិ"

ខ្ញុំសូមដកស្រង់នូវប្រវត្តិបទភ្លេង "**នគររាជ**" មកធ្វើបង្ហាញនាពេលនេះ ព្រោះវាជាមរតកសិល្បៈវប្បធម៌។ តើប្រវត្តិបទភ្លេង"**នគររាជ**" មានន័យយ៉ាងណា? ប្រភពមកពីណា? នរណាជាអ្នកនិពន្ធ?

ប្រទេសខ្មែរយើងមានបទភ្លេង "ជាតិផ្ទាល់" មិនចាញ់ប្រទេសនានាលើសកលលោកឡើយ ។ បទភ្លេងនេះមានឈ្មោះថា "បទនគររាជភ្លេងជាតិ"។ បទនេះកើតមានជាដំបូងក្នុងរជ្ជកាលរបស់ព្រះបាទ **ស៊ីសុវត្ថិ មុនីវង្ស** ក្នុងរវាងគ.ស.១៩៣៨។ អ្នកដែលបង្កើតបទភ្លេងនេះគឺ**សម្តេចព្រះនរោត្តម សុរាម្រឹត** សហការជាមួយជនជាតិបារាំងម្នាក់ឈ្មោះ "**ហ្សីគីល**" មាននាទីជាអ្នកបង្ហាត់ភ្លេងនៅបរមរាជវាំង ប៉ុន្តែពេលនោះរកពាក្យតម្រូវឲ្យបានត្រឹមត្រូវនឹងបទភ្លេងនេះពុំបាន។

រីឯពាក្យ **បទនគររាជ** ដែលជាភ្លេងជាតិ បានកើតឡើងក្នុងរជ្ជកាល ព្រះបាទនរោត្តមសីហនុវរ្ម័ន ហើយដែលត្រូវបានតាក់តែងនិពន្ធដោយ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ គឺព្រះសង្ឃរាជព្រះនាម ជោតញ្ញាណោ "ជួន ណាត" ។ ចំពោះសម័យកាលតាក់តែងពាក្យកាព្យនេះគឺៈ នៅថ្ងៃ ១២រោច ខែអាសាឍ ឆ្នាំម្សាញ់ ត្រីស័ក ព.ស.២៤៨៤ ត្រូវនឹងថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៤១។

ពេលនិពន្ធ គឺព្រះករុណាព្រះបាទនរោត្តមសុរាម្រឹត កាលទ្រង់នៅជាសម្តេចព្រះបរមរាជបិតា ព្រះរាជានុសិដ្ឋ។ ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ទ្រង់ជាឧបយុវរាជ។ បទនគររាជ ប្រែថា "**បទស្តេចអង្គរ**"។ បទនេះពីបុរាណគេច្រៀងចាប៉ី សម្រាប់និទានរឿង ឬចម្រៀងរាយការណ៍ផ្សេងៗពីព្រឹត្តិការណ៍នានា។ ប៉ុន្តែនៅពេលបច្ចុប្បន្ន (នរោត្តមសីហនុ) ទ្រង់បានបំប្លែងមកធ្វើជាបទភ្លេងជាតិវិញ[18]។

**វគ្គទី១៖** *សូមពួកទេវតា រក្សាមហាក្សត្រយើង ឲ្យបានរុងរឿងដោយជ័យមង្គល សិរីសួស្តី យើងខ្ញុំព្រះអង្គសូមជ្រកក្រោមម្លប់ព្រះបារមី នៃព្រះនរបតី វង្សក្សត្រាដែលសាងប្រាសាទថ្ម គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន។*

**អត្ថន័យរួមៈ "សរសើរព្រះបារមីព្រះមហាក្សត្រ"។**

**វគ្គទី២៖** *ប្រាសាទសិលា កំបាំងកណ្តាលព្រៃ គួរឲ្យស្រមៃនឹកដល់យសសក្តិ មហានគរ ជាតិខ្មែរដូចថ្មគង់វង្សនៅល្អរឹងប៉ឹងជំហរ យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា មហារដ្ឋកើតមានយូរអង្វែងហើយ។*

**អត្ថន័យរួមៈ "សរសើរពីការប៉ិនប្រសប់ក្នុងការតុបតែងតំណាងឲ្យអនុភាពនៃជាតិខ្មែរ"។**

**វគ្គទី៣៖** *គ្រប់វត្តអារាម ឮតែសូរសព្ទធម៌ សូត្រដោយអំណរ រំឭកគុណ ព្រះពុទ្ធសាសនា*

---

[18] ចាប ពិន ប្រវត្តិបទនគររាជភ្លេងជាតិខ្មែរ បោះពុម្ពឆ្នាំ១៩៥៩

*ចូរយើងជាអ្នក ជឿជាក់ស្មោះស្មគ្រតាមបែបដូនតា គង់តែទេវតា នឹងជួយជ្រោមជ្រែង ផ្គត់ផ្គង់ប្រយោជន៍ឲ្យ ដល់ប្រទេសខ្មែរ ជាមហានគរ។*

**អត្ថន័យរួមៈ "លើកសរសើរ និងឲ្យតម្លៃលើព្រះពុទ្ធសាសនា"។**

### ៣.២. ទង់ជាតិខ្មែរ

ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ ១៩៩៣ បន្ទាប់ពីការបោះឆ្នោត។ ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា បានរចនាឡើងតាំងពីឆ្នាំ ១៨៥០ មកម្លេះ ដោយដាក់រូបប្រាសាទអង្គរវត្ត ពណ៌សនៅចំផ្ទៃកណ្តាល។

ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាមាន ៣ពណ៌ ដែលមានន័យដូចគ្នានឹងបាវចនាជាតិគឺ «ជាតិ សាសនា ព្រះមហាក្សត្រ»

១)ពណ៌ស តំណាងឲ្យ សាសនា សន្តិភាព

២)ពណ៌ក្រហម តំណាងឲ្យជាតិ គឺទឹកដី និងប្រជាជន

៣)ពណ៌ខៀវ តំណាងឲ្យ ព្រះមហាក្សត្រ និងព្រះអគ្គមហេសី

| ទង់ជាតិ | រំឭកពេល | សម័យកាលប្រើប្រាស់ |
|---|---|---|
|  | ១៨៦៣-១៩៥៣ | ក្រោមអាណានិគមបារាំង |
|  | ១៩៤២-១៩៤៥ | ក្រោមការត្រួតត្រារបស់ជប៉ុន |
|  | ១៩៤៨-១៩៧០ | សង្គមរាស្ត្រនិយម |
|  | ១៩៧០-១៩៧៥ | សាធារណរដ្ឋ |
|  | ១៩៧៥-១៩៧៩ | កម្ពុជាប្រជាធិបតេយ្យ(ប៉ុល ពត) |

| | | |
|---|---|---|
|  | ១៩៧៩-១៩៨៩ | សាធារណរដ្ឋប្រជាមានិតកម្ពុជា |
|  | ១៩៨៩-១៩៩១ | រដ្ឋកម្ពុជា |
|  | ១៩៩២-១៩៩៣ | អ៊ុន តាក់ |
|  | ១៩៩៣-បច្ចុប្បន្ន | បច្ចុប្បន្ន |

**ឯកសារយោង៖**


១) ចាប ពិន ប្រវត្តិបទនគររាជភ្លេងជាតិខ្មែរ បោះពុម្ពឆ្នាំ១៩៥៩

២) ម៉ាយឃើល វិកឃីរី ប្រវត្តិសាស្ត្រកម្ពុជា ឆ្នាំ២០០២

៣) គណៈកម្មាវប្បធម៌កម្ពុជា ប្រវត្តិសាស្ត្រកម្ពុជា ឆ្នាំ២០០៨

៤)ពេជ្រ ទុំក្រវិល តន្ត្រី របាំ និងល្ខោនខ្មែរ ឆ្នាំ២០១០

៥) រ៉ា សុវណ្ណារ័ត្ន ស្ថាបត្យកម្មពិភពលោក ឆ្នាំ២០០៧

៦) www.khmerapsara

# "អរិយធម៌បាហ្គាន និងអរិយធម៌ល្វៀសានបុរៈ"

រៀបរៀងដោយ

លោកបណ្ឌិត **ឆុយ ចាន់ឆួន** អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

នៃរាជបណ្ឌិត្យសភាកម្ពុជា

ទូលបង្គំខ្ញុំបាទសូមលើកយកបទពិសោធន៍មួយចំនួន ដែលទូលព្រះបង្គំខ្ញុំបាទធ្លាប់បានចុះសិក្សាស្រាវជ្រាវផ្ទាល់ ទៅលើទីតាំងស្ថានីយដែលជាសំណង់ប្រាសាទសាសនា។ ភស្តុតាងតាមរយៈវិស័យបុរាណវិទ្យានោះ គឺតំបន់ដែលលាតសន្ធឹងពីជ្រលងទន្លេប្រុត្រព្រាហ្ម (Brahmaputra River) នៅភាគឦសានប្រទេសឥណ្ឌា រហូតដល់ចុងនៃជ្រលងទន្លេក្រហម (Red River ចិន-យួន) ជាតំបន់ដែលអ្នកស្រាវជ្រាវស្គាល់ថា «ជ្រោយចន្លោះប្រទេសឥណ្ឌា និងចិន» ឬហៅថា «អាស៊ីអាគ្នេយ៍»។ ទូលបង្គំខ្ញុំបាទសូមលើកយកភស្តុតាងប្រាសាទព្រះពុទ្ធសាសនា និងបដិមាព្រះពុទ្ធសាសនា ដែលតំបន់ «អាស៊ីអាគ្នេយ៍» បានទទួលយកក្រោមឥទ្ធិពលពាណិជ្ជកម្មរវាងឥណ្ឌា និងចិន ដែលនាំឲ្យមានការសាយភាយ និងរីកចម្រើនជាតំបន់មានកាន់លិទ្ធិព្រហ្មនិយម និងពុទ្ធនិយម។ តាមដងទន្លេធំៗរវាងទន្លេប្រុត្រព្រាហ្ម (Brahmaputra River) និងទន្លេក្រហម មានអរិយធម៌មួយចំនួនទៀតនៅចន្លោះទន្លេធំៗទាំងពីរ ដែលមានអរិយធម៌រីកលូតលាស់ ដូចជាអរិយធម៌ផ្នែកពុទ្ធសាសនានៃទន្លេអ៊ីរ៉ាវ៉ាឌី (Irrawaddy River) នៃប្រទេសភូមា អរិយធម៌អង្គរនៃទន្លេសាបជាដើម។ ទូលបង្គំខ្ញុំបាទសូមលើកបង្ហាញ ប្រាសាទពុទ្ធសាសនា និងពុទ្ធបដិមា ក្នុងកំឡុងដើមសម័យនៃគ្រិស្តសករាជ មកដល់កំឡុងសតវត្សទី១៥នៃគ្រិស្តសករាជ តាមតំបន់ដីគោកពីម៉ានីពួ និងអាសាន (Manipure and Assam) ភាគឦសានប្រទេសឥណ្ឌា ចូលមកភូមា មន ខ្មែរ និងចម្ប៉ា មួយផ្នែកជើងទឹកចេញពីឥណ្ឌា ចូលមកជ្វា ម៉ាឡាយូ ខ្មែរ និងចម្ប៉ា។

ការពង្រីកដែនដីពាណិជ្ជកម្ម តាមដែនសមុទ្ររបស់ចិន និងឥណ្ឌា នៅដើមគ្រិស្តសករាជ បានធ្វើឲ្យប្រទេសអាស៊ីអគ្នេយ៍មួយចំនួនបានរីកចំរើនដូចជា អាណាចក្រភ្នំ (អង្គរបុរី អូរកែវ), អាណាចក្រណាមវៀត, ចម្ប៉ា(លិនយី) ,ភូមា មន ជ្វា ម៉ាឡាយូ ...

នគរភ្នំ (FUNAN ហ្វូណន) ត្រូវបានបង្ហាញដោយអ្នកដំណើរជនជាតិឥណ្ឌា ក្នុងស.វទី១នៃគ.ស. បានបញ្ជាក់ថា ជារាជាណាចក្រ មានក្រុងព័ទ្ធដោយកំពែង មានប្រព័ន្ធបង់ពន្ធដារ មានការនាំចូលទំនិញមានតំលៃ និងមានអក្សរប្រើរបៀបហិណ្ឌូ ដែលមានកំពង់ផែអន្តរជាតិអូរកែវ ជាទីក្រុងកំពង់ផែរបស់ហ្វូណន។ ប្រភពចិនតាមរបាយការណ៍ និង ទីតាំងហ្វូណន នៅខាងលិចលីនយី (នគររបស់ចាម ដែលសព្វថ្ងៃនៅភាគ កណ្តាលប្រទេសវៀតណាម) ហើយ ហ្វូណន លាតសន្ធឹងតាមឈូងសមុទ្រទៅទិសខាងលិច ហើយមានទន្លេហូរកាត់ ហៅថាទន្លេមេគង្គ។ របាយការណ៍ចិននៅសតវត្សទី២នោះបានពិពណ៌នាអំពី រដ្ឋវូ របស់ចិនដែលស្ថិតនៅភាគខាងត្បូង និងអាគ្នេយ៍ ដែលស្វែងរកផ្លូវសមុទ្រថ្មីកាត់តាមអាស៊ីអាគ្នេយ៍ទៅឥណ្ឌានិងមជ្ឈឹមបូព៌ា ក្នុងពេលដែលច្រកផ្លូវគោកប្រទេសចិនទៅឥណ្ឌាត្រូវបានបិតដោយប្រជែងគីរដ្ឋវៃ និងរដ្ឋឈីង។ ភស្តុតាងបដិមាសាស្ត្របានបញ្ជាក់ថា អាណាចក្រភ្នំ កាន់សាសនាព្រាហ្មណ៍ និងមានការលាយឡំជាមួយពុទ្ធសាសនាផងដែរ។

ចាម ឬចម្ប៉ា Champa ជាប្រទេសមួយជាប់ព្រះរាជាណាចក្រខ្មែរបុរាណ ដែលមានទីតាំងស្ថិតនៅភាគខាងត្បូងយួន ឬវៀត ដែលមានទីក្រុងជាប់ឆ្នេរសមុទ្រនៅខាងជើង។ រាជាណាចក្រចាមបុរាណ គេឲ្យឈ្មោះថា នគរចម្ប៉ា (nagara Campa Sanskrit; Khmer: ចាម្ប៉ា) ប្រទេសនេះមានអរិយធម៌ ជាអ្នកកាន់ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ប្រជារាស្ត្រនិយាយភាសា ម៉ាឡាយូ ឥណ្ឌូនេស៊ី ដែលជាប្រភពនៃអំបូរភាសាបាលី សំស្ក្រឹត ទីក្រុងបុរាណរបស់រាជាអាណាចក្រនេះឈ្មោះថា លិនយី ដែលមានតាំងពីឆ្នាំ១៩២ នៃគ្រិស្តសករាជ រាជាណាចក្រនេះរីកលូតលាស់ខ្លាំងនៅអំឡុងសតវត្សរ៍ទី៩ និងទី១០ នៃគ្រិស្តសករាជ នៅតំបន់មីសឺន។ ពោធិ៍នគរ ជាក្រុមប្រាសាទរបស់ចាមដែលបានសង់សម្រាប់ព្រហ្មញ្ញសាសនា សម្រាប់ព្រះភកវាទី (Hindu goddesses Bhagavati) នៅភាគខាងត្បូងសព្វថ្ងៃគឺនៅក្នុងខេត្តញ៉ាត្រាង។ នៅអំឡុងសតវត្សរ៍ទី៩ និងទី១០ នៃគ្រិស្តសករាជ រាជជាអាណាចក្រនេះ បែរកាន់ព្រះពុទ្ធសាសនា ដោយយើងឃើញមានភស្តុតាងនៅដុងយឿង (Dong Duong) ដែលសព្វថ្ងៃសល់តែគំនរឥដ្ឋនៃក្រុងបុរាណប្រមាណជា២០គ.ម ខាងត្បូងទីក្រុងមីសឺន។ សតវត្សរ៍ទី១៥ ដល់ទី១៩ នៃគ្រិស្តសករាជ ប្រទេសចាមបានប្តូរសាសនា មកមានជំនឿលើឥស្លាមសាសនាវិញ។ ទីក្រុងលិនយី /មីស៊ឺន/ ឥន្ទ្របុរ (Indrapura) ទីក្រុងចាមសម័យបុរាណ៖ ជាទីក្រុងព្រហ្មញ្ញសាសនា ដែលមានប្រាសាទបុរាណជាច្រើនសង់អំពីឥដ្ឋ ពីអំឡុងសតវត្សទី៤ ដល់ទី១៤ នៃគ្រិស្តសករាជ ដែលឧទ្ទិសដល់ព្រះឥសូរ។ មីស៊ឺននេះមានចម្ងាយប្រមាណជា៦៩គីឡូម៉ែត្រ ខាងនិរតីនៃទីក្រុងដាណាងសព្វថ្ងៃនេះ។ ទីក្រុងបុរាណនេះមានប្រាសាទបុរាណដែលសង់អំពីឥដ្ឋ ថ្មភក់ និងថ្មបាយក្រៀមចំនួនជាង៧០ប្រាសាទ និងផ្នូរស្តេចផងដែរ ព្រមទាំងមានសិលាចារឹកជាច្រើនផ្ទាំងទៀតផង។ ក្នុងសម័យសង្គ្រាមអាមេរិកាំង ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និង១៩៧០ ប្រាសាទមួយចំនួនត្រូវបានទំលាក់គ្រាប់បែកបំផ្លាញ។ សម័យអាណានិគមនិយមបារាំងបានធ្វើការសិក្សាយ៉ាងស៊ីជម្រៅនៅក្នុងទីក្រុងបុរាណនេះ គេបានចែកទីក្រុងបុរាណនេះទៅជា៨ក្រុមផ្សេងៗគ្នា ក្នុងចំណោមប្រាសាទជាង៧០នោះ គឺក្រុម A, B, C, D, E, F, G និង ក្រុម H។ ព្រះនាមរាជាច្រើនអង្គ ដែលមានព្រះនាមស្រដៀងនិងព្រះរាជាខ្មែរសម័យបុរេអង្គរដែរ ដូចជា៖ Bhadravaman, Sambhuvarman,Vikrantavarman.... ព្រះរាជាទាំងនោះមានកំណត់ត្រាក្នុងសិលាចារឹកជាភាសាសំស្ក្រឹត។ រាជាណាចក្រនេះមានទំនាក់ទំនងជិតស្និតជាមួយ រាជាណាចក្រចិន ដោយមានទីក្រុងជាប់មាត់សមុទ្រ។ ក្រុងបុរាណទីក្រុងលិនយី /មីស៊ឺន/ ឥន្ទ្របុរ (Indrapura) នេះត្រូវបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោក ដោយអង្គការយូណេស្កូ នៅក្នុងឆ្នាំ១៩៩៩ តាមសំណើររបស់សាមីប្រទេសវៀតណាម បច្ចុប្បន្ន។ រាជាណាចក្រចាមនេះធ្លាក់ចុះ គឺដោយសាអាណាចក្រយួន ឬវៀត ឬអណ្ណាម ។ នៅឆ្នាំ១៨៣២ រាជាណាចក្រនេះរលត់បាត់ ដោយសារស្តេច មិង ម៉ាង (Minh Mạng) របស់វៀតណាម បានវាយប្រទេសចម្ប៉ា ធ្វើជាចំណុះរបស់ខ្លួន។ ជនជាតិចាមបានភៀសខ្លួនចូលមកប្រទេសខ្មែរ ប្រទេសសៀម ប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីផងដែរ ទាំងតាមជើងគោក និងតាមផ្លូវទឹកសមុទ្រ។

**ជ្វា** /Java រាជាណាចក្រជ្វាបុរាណ មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការនាំចេញទំនិញតាមសមុទ្រទាក់ទងនិងវិថីពាណិជ្ជកម្មសមុទ្រ វិថីសូត្រ(Silk Road)។ តំបន់កោះជ្វាមិនត្រឹមតែជាកន្លែងផលិតធុញ្ញជាតិ ប៉ុណ្ណោះទេ តែថែមទាំងជាទីតាំងស្តុកទំនិញ និងជាឃ្លាំងស្រូវរបស់ជនជាតិជ្វាផងដែរ។ តំបន់មាចាប៉ាហិត ជាកន្លែងផលិតផលកសិកម្ម ហើយក៏ជាតំបន់ចំណតសំពៅពាណិជ្ជកម្ម

នាសម័យបុរាណជាមួយបរទេសផងដែរ។ សំណង់ប្រាសាទបាក់បែកនៅមានស្លាកស្នាមនៅតំបន់ ត្រូវលែន (Trowulan) នៅឡើយ។ ប្រជាជនកាន់សាសនាហិណ្ឌូ និងព្រះពុទ្ធសាសនា តាមរយៈពាណិជ្ជកម្ម ដែលបានភ្ជាប់ពីតំបន់កោះជាប់ៗគ្នាដែលជាប់និងឧបទ្វីបឥណ្ឌា។ សាសនាហិណ្ឌូបានចូលមកប្រទេសនេះតាំងពីសតវត្សទី៤នៃគ្រិស្តសករាជ ព្រហ្មញ្ញសាសនា និងពុទ្ធសាសនាបានចូលមកប្រទេសនេះ ហើយបានរួបរួមគ្នាជាលទ្ធិទស្សនៈជំនឿរបស់ប្រជាជន។ ប្រាសាទបូរូបុឌួ (Borobudur) ត្រូវបានអ្នកស្រាវជ្រាវកត់សំគាល់ថា ជារមណីយដ្ឋានពុទ្ធសាសនាធំជាងគេមួយនៅអាស៊ីអាគ្នេយ៍ក្នុងសតវត្សទី១០នៃគ្រិស្តសករាជ ប្រាសាទថ្មតែមួយដែលមានតំកល់ពុទ្ធបដិមាដល់៥០៤អង្គ ក្នុងប្រាង្គផ្សេងៗគ្នា ...។

ប្រទេសភូមា ឬប្រទេសមីយ៉ាន់ម៉ា មានឈ្មោះផ្លូវការថាសហព័ន្ធមីយ៉ាន់ម៉ា។ សហព័ន្ធមីយ៉ាន់ម៉ា មានរដ្ឋជាចំណុះ ចំនួន៧រដ្ឋ និងមានតំបន់ចំនួន៧ផ្សេងទៀត រួមមាន១៤រដ្ឋ និងតំបន់ (1.Kachin State, 2.Kayah State, 3.Kayin State, 4.Chin State, 5.Sagaing Division, 6.Taninthayi Division, 7.Bago Division, 8.Magway Division, 9.Mandalay Division, 10.Mon State, 11.Rakhine State, 12.Yangon Divison, 13.Shan State, 14.Ayarwaddy Division )។ រដ្ឋនិងតំបន់ទាំង១៤នោះមានវប្បធម៌ និងភាសាផ្សេងៗគ្នា នៅភាគខាងត្បូងជនជាតិមនជាជនជាតិដែលបង្កើតរដ្ឋ ដំបូងក្នុងកំឡុងឆ្នាំ២០០ នៃគ្រិស្តសករាជ មានទំនាក់ទំនងនិងក្រោមឥទ្ធិពលនៃនគរភ្នំ ហើយជារដ្ឋដែលកាន់ព្រះពុទ្ធសាសនាថេរវាទមុនគេនៅអាស៊ីអាគ្នេយ៍ រហូតដល់កំឡុងសតវត្សទី៥ និងទី៦នៃគ្រិស្តសករាជ ទើបមនទទួលឯករាជភាពពីនគរភ្នំ។ បន្ទាប់មកគេឃើញជនជាតិទីបេភូមាបានមកដល់នាពេលបន្ទាប់នៅសតវត្សទី១មុនគ.ស ហើយបានកកើតជារដ្ឋព្យូនៅឆ្នាំ៥៧៣នៃគ្រិស្តសករាជ។ រដ្ឋតូចៗជាច្រើនដែលនៅក្នុងនោះរដ្ឋដែលមានឥទ្ធិពលជាងគេឈ្មោះ រដ្ឋស្រីក្សេត្រា នៅភាគកណ្ដាលជ្រលងអាយ៉េយ៉ាវ៉ាឌី។ ជនជាតិចាមដែលរស់នៅភាគខាងត្បូងភូមាត្រូវបានគេចាត់ទុកថាជាជនជាតិដំបូងបង្អស់ដែលបានធ្វើបំលាស់ទៅកាន់តំបន់ទំនាប នៅតាមជ្រលងអាយេយ៉ាវ៉ាឌី នៅពាក់កណ្ដាលសតវត្សទី៩មុនគ្រីស្តសករាជ បានមកតាំងទីនៅតំបន់ជ្រលងទន្លេអ៊ីរ៉ាវ៉ាឌី (Irrawaddy valley)ហើយបង្កើតជាអាណាចក្របាហ្កាន (Pagan Kingdom) ក្នុងទសវត្សកំឡុងឆ្នាំ១០៥០។ ភូមាបុរាណប្រកាន់យកព្រហ្មញ្ញសានា បន្ទាប់មកពុទ្ធសាសនាថេរវាទ ដែលបន្តរហូតដល់បច្ចុប្បន្ន។ អាណាចក្របាហ្កាន ត្រូវបានរលំបាត់ដោយសារការវាយលុកលុយដោយពួកម៉ុងហ្គោល។យោងតាមសៀវភៅអរិយធម៌មន ដែលបានបោះពុម្ពក្នុងឆ្នាំ១៩៩៩ (The Mons 1999) មានបញ្ជាក់ថា អរិយធម៌នគរភ្នំ (Funan) បានលាតសន្ធឹង និងគ្រប់គ្រងភាគខាងត្បូងភូមា។ បាហ្កានជាទីក្រុងបុរាណក្នុងតំបន់ម៉ាន់ដឺឡេ នៃប្រទេសភូមា សព្វថ្ងៃ។ បាហ្កាន ធ្លាប់ជាទីក្រុងរបស់ប្រទេស ឯករាជមួយឈ្មោះថារាជាណាចក្របាហ្កាន ពីសតវត្សទី៩ ដល់សតវត្សទី១៣នៃគ្រីស្តសករាជ ហើយជារាជាណាចក្រដំបូងដែលផ្ដើមបង្រួបបង្រួម បង្កើតជាប្រទេសសហព័ន្ធភូមាទំនើបដល់បច្ចុប្បន្ន។ នៅពេលដែលរាជាណាចក្រនេះ មានអំណាចឡើងដល់កំពូលនាសតវត្សទី១១ ដល់ទី១៣ នៃគ្រីស្តសករាជ មានប្រាសាទឥដ្ឋ

ជាងមួយម៉ឺនប្រាសាទ ត្រូវបានកសាងឡើង សម្រាប់ឧទ្ទិសដល់សាសនាព្រះពុទ្ធ។ បច្ចុប្បន្ន គេឃើញប្រាសាទជាង២២០០ ដែលនៅរាយប៉ាយសេសសល់ ក្នុងជ្រលងទន្លេអ៊ីរ៉ាវ៉ាឌី នៃតំបន់បាហ្កាននេះ។ បាហ្កាន បានក្លាយជាតំបន់បេតិកភណ្ឌពិភពលោក ដែលត្រូវបានចុះក្នុងបញ្ជីត្រូវការពារសម្រាប់មនុស្សជាតិ ដោយអង្គការយូណេស្កូ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦។ បាហ្កាន ជាតំបន់រមណីយដ្ឋានបុរាណវិទ្យាដ៏ធំមួយ របស់ពិភពលោក ដែលទាក់ទាញទេសចរណ៍ជាច្រើន ប្រហាក់ប្រហែលនឹងអង្គរវត្តរបស់កម្ពុជាយើងដែរ។

ជាយសមុទ្រខាងត្បូងរៀសានរបស់អាណាចក្រនគរភ្នំមានអរិយធម៌លិនយី របស់ជនជាតិចាម នៅទីក្រុងមីសឺន ជាណាងសព្វថ្ងៃ ជាអរិយធម៌ចំណាស់មានប្រាសាទឥដ្ឋរាប់សិប ពង្រាយតាមជ្រលង ក្បែរមាត់សមុទ្រ។ សូមបញ្ជាក់ថាអរិធម៌ចម្ប៉ាចាស់ គឺទទួលឥទ្ធិពលឥណ្ឌា ដូចអរិយធម៌នគរភ្នំ ដូចអរិយធម៌មន ដូចអរិយធម៌ព្យូ ផងដែរ ជាប្រទេសកាន់ព្រហ្មញ្ញ និងពុទ្ធសាសនា។ ប្រាសាទទាំងអស់ច្រើនជាប្រាសាទធ្វើអំពីឥដ្ឋដុត កំឡុងពីសតវត្សទី១ ដល់ទី៧នៃគ្រិស្តសករាជ។ ភាគខាងត្បូងមន និងខាងត្បូងនគរភ្នំគឺសហពន្ធរដ្ឋម៉ាឡាយូ មានភស្តុតាងប្រាសាទឥដ្ឋជាច្រើន ដូចជានៅកេដាស(Kedas) និងកោះជ្វា (Java Irland) (ម៉ាឡាយូបែងចែកទឹកដីជាពីរ នៅឆ្នាំ១៨២៤ ក្លាយជាប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីសព្វថ្ងៃ)។ ការផលិតឥដ្ឋធ្វើប្រាសាទរបស់ម៉ាឡាយូ ក្នុងសតវត្សទី២ និងទី៣ នៃគ្រិស្តសករាជ។

ពុទ្ធសាសនិកគ្រប់រូបតែងតែបានដឹងថា ព្រះពុទ្ធគោតម មានព្រះមាតានាមព្រះនាងមហាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ស្ថិតក្នុងត្រកូលព្រាហ្ម! សាសនាដែលបានសាយភាយពីឥណ្ឌាមកកាន់តំបន់អាស៊ីអាគ្នេយ៍ មុនគេនោះគឺព្រហ្មញ្ញសាសនា បន្ទាប់មកពុទ្ធសាសនា ដោយមានភស្តុតាងប្រាង្គប្រាសាទ និងបដិមា។ ចុះមូលហេតុអ្វីបានជាពុទ្ធសាសនាមានការរីកចម្រើនខ្លាំង នៅអាស៊ីអាគ្នេយ៍យើងនេះ?

ក. ព្រហ្មញ្ញសាសនា មានវណ្ណៈ

ខ. ពុទ្ធសាសនា គ្មានវណ្ណៈ

ចំពោះទូលព្រះបង្គំខ្ញុំបាទសួរថា៖ តើអ្នករាល់គ្នាសុខចិត្តសុខកាយឲ្យគេជិះជាន់ ឬចង់ទទួលបានសេរីភាព ?

សូមបញ្ជាក់ថា ស្រុកខ្មែរ ទើបលុបបំបាត់ខ្ញុំ ឬវណ្ណៈទាសករ នៅកំឡុងដើមសតវត្សទី២០នេះទេ!

លោកសាស្ត្រាចារ្យបណ្ឌិត **ឆុយ ចាន់ឆួន** អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា បានទៅចូលរួម បានសិក្សាស្រាវជ្រាវផ្ទាល់នៅតំបន់ប្រាសាទ នាភាគត្បូងរៀសានប្រទេសឥណ្ឌា ហើយបានបន្តដំណើរសិក្សា អរិយធម៌ព្យូ របស់ប្រទេសភូមា (តំបន់យ៉ង់ហ្គូន ម៉ាន់ដាឡេ និងបាហ្កាន) ម៉ាឡាយូ (ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី) អតីតមហានគរ (ដីខ្មែរនៅសៀម និងយួន)... ដើម្បីស្វែងយល់អំពី ជនជាតិ វប្បធម៌ និងភាសា ស្រដៀងគ្នាភ្ជាប់មកអាស៊ីអាគ្នេយ៍នេះ។ ស្ថាបត្យកម្មដែលប្រើប្រាស់ឥដ្ឋបានលាតសន្ធឹងពីទិសខាងលិច មកទិសខាងកើត តាមរយៈទំនាក់ទំនងពីរ ប្រភេទគឺ៖ ១/ ទំនាក់ទំនងតាមផ្លូវសមុទ្រ ២/ ទំនាក់ទំនងតាមផ្លូវគោក។ តើឥទ្ធិពលនៃទំនាក់ទំនងពីទិស

ខាងលិច មកទិសខាងកើត មានអ្វីខ្លះសម្រាប់ វប្បធម៌ សេដ្ឋកិច្ច សាសនា មកលើសង្គមខ្មែរ... សូមចងចាំថាតំបន់អាស៊ីអាគ្នេយ៍ទាំងមូល និងប្រទេសដែលនៅចន្លោះ ទន្លេប្រហ្មបុត្រ (Brahmaputra River) នៅភាគឦសានប្រទេសឥណ្ឌា រហូតដល់ចុងនៃជ្រលងទន្លេក្រហម (Red River) (ចិន-យួន) សុទ្ធតែជាតំបន់ ឬប្រទេសធ្លាប់បានកាន់ព្រហ្មញ្ញសាសនា និងពុទ្ធសាសនាក្នុងកំឡុង សតវត្សទី១ដល់ទី១៥ នៃគ្រិស្តសករាជ។ សូមមេត្តាជួយស្រាវជ្រាវទាំងអស់គ្នា!

លោកបណ្ឌិតសភាចារ្យស៊ន សំណាង ប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា មានប្រសាសន៍ថា ពិតពលោកបានប្តូរការសិក្សាពី «ប្រវត្តិសាស្ត្រតាមកាលប្រវត្តិ» (Chronological History) មកសិក្សា «ប្រវត្តិសាស្ត្រតាមប្រធានបទ» (Thematic History) វិញម្តង ពោលគឺសិក្សាផ្តោតលើប្រធានបទណាដែលមានប្រយោជន៍ដល់ការអភិវឌ្ឍសង្គមជាតិបច្ចុប្បន្ន។ លោកបណ្ឌិតសភាចារ្យ តែងតែរំលឹកថា៖ ជាតិសាសន៍មួយដែលមិនស្គាល់អតីតកាលនោះ គឺមិនស្គាល់បច្ចុប្បន្នកាល និងមិនដឹងថាខ្លួនកំពុងធ្វើអ្វី?

ដូច្នេះ យើងទាំងអស់គ្នាគប្បីសិក្សាប្រវត្តិសាស្ត្រជាតិ ឲ្យបានច្បាស់លាស់។

សូមជនរួមជាតិចូលរួមសិក្សាប្រវត្តិសាស្ត្រ និងស្វែងយល់ពីព្រឹត្តិការណ៍សង្គមជាតិយើងទាំងអស់គ្នា។

សូមថ្លែងអំណរគុណ បណ្ឌិតសភាចារ្យ ស៊ន សំណាង ដែលបានកែសម្រួលអត្ថបទ និងអរគុណ ធឿនធួន ម៉ាលីនដា, ធឿនធួន ម៉ារីណា និង ធឿនធួន ម៉ានីកា ដែលបានជួយកែអក្ខរាវិរុទ្ធ។

រាជធានីភ្នំពេញ, ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨

**ឯកសារយោង៖**


១/ 1996 Roger Bischoff,  A Short History Buddhism in Myanmar

២/ 1999 The Mons

៣/ 1996 Unesco

៤/ 1964 Than Tun

៥/ https://en.wikipedia.org/wiki/Bagan

៦/ អេង សុត ព្រះរាជពង្សាវតារខ្មែរ/មហាបុរសខ្មែរ, ភាគទី១ដល់ភាគទី៧ចប់ (បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ នៃក្រសួងអប់រំ យុវជន និងកីឡា គ.ស២០០៩ ព.ស ២៥៥៣)

៧/ 2010 Kyaw Lat, Arts and Architecture of Bagan

៨/អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ប៉ារីស ឆ្នាំ១៩១៤ (ប្រែសម្រួលដោយ ទេព ម៉េងឃាង, ភ្នំពេញ, ២០០៦)

៩/ HISTOIRE DU CAMBODGE DEPUIS LE 1er SIÈCLE DE NOTRE ÈRE D’APRÈS LES INSCRIPTIONS LAPIDAIRES LES ANNALES CHINOISES ET ANNAMITES ET LES DOCUMENTS EUROPÉENS DES SIX DERNIERS SIÈCLES PART ADHÈMARD LECLÈRE ANCIEN RÉSIDENT DE FRANCE AU CAMBODGE, PARIS, LIBRAIRIE PAUL GEUTHNER, 13, RUE JACON, 13, 1914.

១០/ ការចុះស្រាវជ្រាវផ្ទាល់ដល់ស្ថានីយរបស់អ្នកនិពន្ធ ឥណ្ឌា, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី, វៀតណាម, ថៃ, ភូមា...

# "រចនាបថនៃស្ថាបត្យកម្មខ្មែរ"

រៀបរៀងដោយ

សាស្ត្រាចារ្យ **ខៀវ កុសល** អនុប្រធានសមាគមអ្នកនិពន្ធខ្មែរ

និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃទីស្តីការគណៈរដ្ឋមន្ត្រី

## ១. សេចក្តីផ្តើម

នៅក្នុងរចនាបថនៃស្ថាបត្យកម្មខ្មែរ យើងគួរយល់អំពីពាក្យបីដែលផ្គុំចូលគ្នាមានពាក្យ រចនាបថ ពាក្យស្ថាបត្យកម្ម និងពាក្យខ្មែរ៖

**-ស្ថាបត្យកម្ម** គឺជាសិល្បៈមួយក្នុងការកសាងសង់ឡើងគឺប្រកបដោយការតុបតែងលម្អទៅតាមក្បួនខ្នាតដោយយើងខ្ញុំលើកជូនក្នុងអង្គសន្និសីទនេះដើម្បីបង្ហាញអំពីស្ថាបត្យកម្មខ្មែរ សម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរដែលមានឈ្មោះល្បីរន្ទឺពាសពេញ សាកលលោកត្រង់ពាក្យថា ន័យរបស់សិល្បៈ (សិល្បៈ- សំ- សិប្បៈ- បា) ដែលសំដៅលើការកសាងសំណង់ផ្សេងៗ ជំនាញ ហត្ថកម្ម ពលកម្ម ដោយប្រើបញ្ញាស្មារតី ចំណេះដឹង បច្ចេកទេសគ្រប់បែបយ៉ាងដើម្បីឱ្យមានសោភណភាព និងប្រកបដោយសិល្ប៍ ហើយក៏បានធ្វើឱ្យមនុស្សគាប់ចិត្តផ្តោតអារម្មណ៍ចង់មើល ចង់ឃើញ ចង់ស្តាប់។ល។

**-រចនាបថ** ដែលសំដៅទៅលើសិល្បៈនៃក្នុងការសាងសង់ ឬតាក់តែងលម្អតាមគំនិតរបស់ព្រះមហាក្សត្រក្នុងការស្ថាបនាប្រាង្គប្រាសាទបុរាណ ហើយក៏ផ្គួបផ្សំជាមួយនឹងគំនិត ស្ថាបត្យករ វិស្វករខ្មែរ និងអ្នកជំនាញផ្សេងៗដើម្បីស្ថាបនាប្រាសាទបុរាណ។

នៅក្នុងសម័យកាលនោះ (បុរាណ) គេបានបែងចែករចនាបថដាច់ដោយឡែកពីគ្នាដែលមានរហូតទៅដល់ចំនួន១៣រចនាបថឯណោះ។ ក្នុងរចនាបថនីមួយៗមានការកសាងលក្ខណៈពិសេសខុសៗគ្នាទៅតាមសម័យកាលនីមួយៗដែរ ទាំងភូមិសាស្ត្រ វត្ថុធាតុដើម រូបរាង ទ្រង់ទ្រាយ សោភណ្ឌភាពទៅតាមចំណង់ចំណូលចិត្ត ហើយក៏ស្របទៅតាមលក្ខណៈសម័យកាលនោះផង។

**-ខ្មែរ** ដែលជាម្ចាស់ប្រទេស (ទឹកដីភូមិសាស្ត្រមកពីពាក្យ "ខេមរៈ" ហើយក៏មកពីពាក្យ កម្ពុ+មេរា (កម្ពុ=បាឡីហៅថា ខ្យងសមុទ្រ) មេរាគឺជាមេរុ ហើយក៏ ជ ដែលឱ្យតម្លៃស្មើនឹង មេរា មេរុ មេរៈ មេន (អំណាន)។ បើតាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** បានផ្តល់ន័យ«ខ្មែរ»ថ្នាក់ពាក្យជានាមគឺជាមនុស្សដែលកើត ឬក្នុងដែនកម្ពុជា ហើយលុះនៅក្នុងអំណាចច្បាប់ខ្មែរ (ខេមរៈ) ជាតិខ្មែរ។ ក្នុងសម័យបុរាណព្រេងនាយ សរសេរជា ខ្មេរ ក៏មាន។ ពាក្យ «ខេមរៈ» មានន័យថា "ខ្មែរ" ជាបាលីជាតិសព្ទបានន័យថា មនុស្សមានសេចក្តីក្សេម។

## ២. បទបង្ហាញ

រចនាបថនៃស្ថាបត្យកម្មខ្មែរ ដែលប្រជាពលរដ្ឋលើពិភពលោក រួមទាំងប្រជាពលរដ្ឋខ្មែរផងពោលគឺអ្នកដែលមាននិស្ស័យ និងវប្បធម៌ក្នុងមែកធាងរចនាបថ និងស្ថាបត្យកម្ម។ បច្ចុប្បន្ននេះក្នុងអ្នកជំនាញក៏ដូចជារូបខ្ញុំបាទដែលមាននិស្ស័យនឹងប្រធានបទខាងលើឃើញថា ប្រទេសខ្មែរយើងក៏តែងតែជួបនូវបញ្ហាខ្លះៗជៀសមិនផុតឡើយពីការឆ្លងទៅឆ្លងមកបែបបទសំណង់ (រចនាបថស្ថាបត្យកម្ម) នៅតាមប្រាសាទនានាហើយក៏មាននៅតាមអគារតូចធំគ្រប់ខ្នាត វិមាន ភូមិគ្រឹះ លំនៅឋាន ដែលប្រជា

ពលរដ្ឋជាម្ចាស់ (បុគ្គល) គេស្រឡាញ់ និងចូលចិត្ត។ ចំពោះបុរាណកាល រចនាបថនៃស្ថាបត្យកម្មខ្មែរបុរាណវិទូគេបែងចែកតាំងពីសតវត្សរ៍ទី១ រហូតមកដល់ដើមសតវត្សរ៍ទី១៣ ៖

**២.១. មាតិកា**

១. រចនាបថភ្នំដា (គ.ស.ទី១ ដល់ស.វ.ទី៦)

២. រចនាបថសម្បូណ៌ (ពាក់កណ្តាលស.វ.ទី១ នៃគ.ស.ទី៧)

៣. រចនាបថព្រៃក្មេង (ពាក់កណ្តាលស.វ.ទី២ នៃគ.ស.ទី៧)

៤. រចនាបថកំពង់ព្រះ (គ.ស.ទី៨)

៥. រចនាបថគូលែន (ពាក់កណ្តាលស.វ.ទី១-ស.វ.ទី៩)

៦. រចនាបថព្រះគោ (ចុងនៃស.វ.ទី១- ស.វ.ទី៩)

៧. រចនាបថបាខែង (ចុងនៃស.វ.ទី៩- និងដើមស.វ.ទី១០)

៨. រចនាបថកោះកែ (គ.ស.វ.ទី១០)

៩. រចនាបថបន្ទាយស្រី (ពាក់កណ្តាលទី២នៃគ.ស.វ.ទី១០)

១០. រចនាបថឃ្លាំង (ចុងស.វ.ទី១០ និងពាក់កណ្តាលទី១នៃគ.ស.វ.ទី១១)

១១. រចនាបថបាពួន (ពាក់កណ្តាលទី២ នៃគ.ស.វ.ទី១១)

១២. រចនាបថអង្គរវត្ត (ពាក់កណ្តាលទី១ នៃគ.ស.វ.ទី១២)

១៣. រចនាបថបាយ័ន (ពាក់កណ្តាលទី១ នៃគ.ស.វ.ទី១២ និងដើមគ.ស.វ.ទី១៣)

**២.២. បំណកស្រាយ**

**១. រចនាបថភ្នំដា (គ.ស.ទី១ ដល់ស.វ.ទី៦)**

តាមបុរាណវិទូដែលបានធ្វើកំណាយត្រង់ទីតាំងប្រវត្តិសាស្ត្រនៅលើទឹកដីអង្គរបុរី និងនៅអូរកែវដែលស្ថិតនៅលើទីតាំងទឹកដីកម្ពុជាក្រោមបានបង្ហាញថា សិល្បៈនៅសម័យហ្វូណន នោះត្រូវបានគេបញ្ចូលនៅក្នុងរចនាបថភ្នំដា ព្រោះមានតឹកតាងមួយគឺយកប្រាសាទនៅភ្នំដាធ្វើជាគោល។ ភ្នំដាជាទីតាំងមួយដែលស្ថិតនៅជិតអង្គរបុរីក្នុងខេត្តតាកែវ ហើយក្នុងសម័យនោះខ្មែរមានទំនាក់ទំនងជាមួយនឹងប្រទេសនានាជាពិសេសជាមួយឥណ្ឌាខាងផ្នែកសិល្បៈ។

ក្រៅពីសំណង់ស្ថាបត្យកម្មបុរាណខ្មែរនៅសម័យនគរភ្នំនោះ បុព្វបុរសដូនតាបានទុកស្នាដៃជាច្រើនខាងក្នុងរូបបដិមា ហើយត្រូវបានគេប្រទះឃើញនៅស្រុកអង្គរបុរី និងទីតាំង ដែលជាស្ថានីយ៍បុរេប្រវត្តិសាស្ត្រក្នុងប្រទេសខ្មែរយើង។ ដោយឡែកកំណាយនៅអូរកែវវិញ បានធ្វើឱ្យយើងស្គាល់នូវឧបករណ៍ប្រើប្រាស់ និងមានគ្រឿងលម្អជាអលង្ការ ដែលខ្មែរយើងនាជំនាន់នោះបានប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។

**២. រចនាបថសម្បូណ៌ (ពាក់កណ្តាលស.វទី១ នៃគ.សទី៧)** ដែលស្ថិតនៅក្នុងរជ្ជកាលនៃព្រះបាទឥសានវរ្ម័នទី១ (គ.សទី៦១៦-៦៣៥) ហើយដែលមានរាជធានីដ៏ល្បីឈ្មោះមួយនា សម័យកាលនោះគឺ ឥសានបុរៈ គឺសម្បូរព្រៃគុកនាសព្វថ្ងៃដែលស្ថិតនៅក្នុងខេត្តកំពង់ធំ។ ស្ថិតនៅក្នុងរចនាបថនេះមានប្រាសាទនានាដែលមានស្ថាបត្យកម្មល្អប្រកបទៅដោយសោភ័ណ បន្តរហូតដល់ស.វទី១០ ដែលមានប្រាសាទរាងតូចៗធ្វើអំពីភ្នំដាបូកបាយអនិងធ្វើអំពីកំបោរ លាយស្ករ ប៉ុន្តែបច្ចុប្បន្ននេះរបេះធ្លាក់ស្ទើរអស់ទៅហើយគឺនៅសល់តែឥដ្ឋទទេ។ ដោយឡែកផ្តែរវិញ និងសសរពេជ្រធ្វើអំពីថ្មភក់ ហើយ

ប្រាសាទទាំងឡាយភាគច្រើនសង់គ្មានរបៀបរៀប រយដែលម្តងត្រង់នេះ ម្តងត្រង់នោះ។ ជាការកត់សម្គាល់ក្នុងរចនាបថនេះ គេបានប្រទះឃើញ បដិមាភេទស្រី មានរាងតូច ត្រគាកសាយ ហើយមានពាក់មុដរាងមូល។ ចំណែកឯបដិមាភេទ ប្រុសវិញនោះ ច្រើនមានរាងធំហើយមាំថែមទៀតផង។

**៣. រចនាបថព្រៃក្មេង (ពាក់កណ្តាលស.វ ទី២ នៃគ.សទី៧)** ដែលស្ថិតនៅក្នុងរចនាបថព្រៃក្មេង គឺស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ នៃគ.ស ទី៦៥៥ - ៦៨១ ដែលមានរាជធានី នៅអង្គរបុរី ដែលស្ថិតក្នុងខេត្តតាកែវ។ ស្ថាបត្យកម្មខ្មែរមានលក្ខណៈប្រហាក់ប្រហែលគ្នានឹង ស្ថាបត្យកម្មក្នុងរចនាបថសម្បូណ៍ដែរ ព្រោះមានក្បាច់នៃរចនាបថភាគច្រើនតែក្បាច់ភ្ញីទេស ដែលលម្អដោយផ្កាចន្ទន៍។ នៅក្នុងរចនាបថនេះ មនុស្សម្នាភាគច្រើនគេនាំគ្នាកោតសសើររូប ហរិហរៈប្រាសាទអណ្តែត ហើយគេបានចាត់ទុកថានេះជាស្នាដៃឯកមួយក្នុងសិល្បៈខ្មែរបុរាណខាងផ្នែកស្ថាបត្យកម្ម។ ព្រោះគេបានពិនិត្យមើលឃើញថា ស្ថាបត្យករខ្មែរយើងមានទេពកោសល្យ ឬបច្ចេកទេសគ្រប់គ្រាន់ ឬសមត្ថភាពខ្ពង់ខ្ពស់ដោយចេះធ្វើបដិមានេះប្រកបទៅដោយសោភណភាពពេញជាទីមោទនៈជាទីបំផុត។

**៤. រចនាបថកំពង់ព្រះ (គ.ស.ទី៨)** គឺស្ថិតនៅក្នុងសម័យកាលចេនឡាបែកបាក់ជាពីរ។ ប្រាសាទនានា ដែលត្រូវបានគេបញ្ចូលរួមមានប្រាសាទមាកយំ(ផ្នែកបុរាណ) ប្រាសាទត្រពាំងផុង (ផ្នែកបុរាណ) ហើយប្រាសាទទាំងអស់គឺសង់រាបនឹងដី លើកលែងតែប្រាសាទអកយំមួយ ទេដែលគេសង់ជាច្រើនជាន់ មានរាងដូចចេតិយ។ ហើយរូបបដិមាក្នុងរចនាបថនេះមានល្អខ្លះ អាក្រក់ខ្លះ ប៉ុន្តែសិល្បៈខ្មែរមានវិវត្តពិសេសរបស់ខ្លួនគឺត្រង់សិល្បករខ្មែរបានកសាងល្បង បំបាត់គោលទំរនិងទំនប់របស់បដិមាខ្លះៗ។

**៥. រចនាបថគូលែន (ពាក់កណ្តាលស.វ.ទី១ - ស.វ.ទី៩)** ដែលស្ថិតនៅក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី២ (គ.ស ៨០២-៨៥០) និងមានរាជធានីជាច្រើនកន្លែង។ ប្រាសាទមួយដែលត្រូវបានរាប់បញ្ចូលក្នុងនេះមានប្រាសាទព្រៃប្រាសាទ ប្រាសាទភ្នំគូលែន ប្រាសាទដំរីក្រាប ប្រាសាទអូរបាងប្រាសាទខ្ទីងងាប់។ល។ ព្រះបាទជ័យវរ្ម័នទី២ បានប្រារព្ធពិធីទេវរាជ ទើបបណ្តាលឱ្យសិល្បករខ្មែរទទួលយកនូវឥទ្ធិពលសិល្បៈជាហេតុធ្វើឱ្យខ្មែរកសាងប្រាសាទ កាន់តែច្រើនឡើងៗ (ប្រាសាទភ្នំ)។ នៅក្នុងនោះបានបង្កើតទៅជារូបភាពថ្មីៗជាច្រើនដែលគេ ហៅថា បុព្វកាលក្នុងប្រវត្តិសិល្បៈខ្មែរ។

**៦. រចនាបថព្រះគោ (ចុងនៃស.វ.ទី១ - ស.វ.ទី៩)** ដែលស្ថិតនៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១ (៨៧៧-៨៨៩) និងព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩-៩០០) ដែលដំបូងបានស្ថិតនៅក្នុងរាជធានី ហរិហរល័យដែរពោលគឺស្ថិតនៅក្នុងរលួសខេត្តសៀមរាប។ យើងបានឃើញថាមានប្រាសាទមួយចំនួនត្រូវបានគេបញ្ចូលក្នុងរចនាបថនេះគឺ ប្រាសាទព្រះគោ ប្រាសាទបាគង ដែលកសាងឡើងដោយព្រះបាទឥន្ទ្រវរ្ម័នទី១។ ដោយឡែកចំពោះប្រាសាទលលៃវិញដែលជាស្នាដៃរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ នោះភាគច្រើនសង់អំពីឥដ្ឋបូកបាយអដោយមានប្រាង្គជាច្រើនលើខឿនតែមួយ (ព្រះលលៃ) ដើម្បីឧទ្ទិសជូនដល់បុព្វជនរួមមានអ្នកមានគុណពោលគឺមាតាបិតាជាដើម។

**៧. រចនាបថបាខែង (ចុងនៃស.វ.ទី៩-ដើមស.វទី១០)** ដែលស្ថិតនៅក្នុងរចនាបថ ព្រះបាទយសោវរ្ម័នទី១ នៃគ.ស ៨៨៩-៩០០ ដែលមានរាជធានីនៅយសោបុរៈដែលបច្ចុប្បន្នគឺ ភ្នំបាក់ខែង។ យើងឃើញថាមានប្រាសាទមួយចំនួនត្រូវបានគេបញ្ចូលក្នុងរចនាបថនេះរួមមាន ប្រាសាទភ្នំបាក់ខែង ប្រាសាទភ្នំក្រោម ប្រាសាទភ្នំបូកជាដើម។ គេសង្កេតឃើញថាមាន បដិមានានាមានរាងត្រង់ៗ មាន

មាឌធំហើយរឹងមាំ ចិញ្ចើមទាំងពីរត្រង់ហើយជាប់គ្នា បបូរមាត់ ត្រូវបានសិល្បករបានឆ្លាក់ឱ្យឃើញជាវង្វង់ពីរផ្ទេត់យ៉ាងច្បាស់ ជើងសក់និងពុកចង្កាឆ្លាក់ជាប់ គ្នាតែម្ដង។ រូបបដិមាទាំងនេះស្លៀកសំពត់ជីពជាផ្នត់ជុំវិញខ្លួនហើយមានជាយខាងលើ ដែលបត់ជាផ្នត់ទម្លាក់ចុះមកក្រោមវិញប្រកបទៅដោយសោភណ្ឌភាព។

**៨. រចនាបថកោះកែ (គ.ស.វទី១០)** នេះស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤នៃគ.ស៩២៨-៩៤១ មានទីតាំងនៅកោះកែ ហើយស្ថិតនៅចម្ងាយប្រមាណជា ១០០ គីឡូម៉ែត្រ នៅ ទិសឥសាននៃភូមិភាគអង្គរ។ ជារួមប្រាសាទនៅកោះកែទាំងអស់ត្រូវបានគេរាប់បញ្ចូលថា ស្ថិតនៅក្នុងរចនាបថនេះព្រោះយើងអាចឃើញប្រាសាទមួយសង់នៅលើខឿនប្រាំពីរជាន់ ដែលមានកម្ពស់ប្រមាណ ៣៥ម៉ែត្រ។ ចំពោះរូបបដិមាវិញមានសភាពប្រហាក់ប្រហែលគ្នាទៅ នឹងសម័យមុនៗដែរ មានមាឌធំ ប្រកបដោយចលនាដែលមានរូបដើរ រូបរាំ ឬរូបប្រយុទ្ធគ្នា ក្នុងរឿងរាមកេរ្តិ៍គឺចម្បាំងរវាងសុគ្រីពនិងពាលី ដើម្បីស្ដែងឱ្យឃើញពីអំណាចនិងថាមពលឱ្យស្របទៅតាមទឹកព្រះទ័យនៃព្រះបាទជ័យវរ្ម័នទី៤ព្រោះព្រះអង្គជាស្ដេចជ្រែករាជ្យ។

**៩. រចនាបថបន្ទាយស្រី (ពាក់កណ្ដាលទី២ នៃគ.ស.វ ទី១០)** ស្ថិតនៅក្នុងរជ្ជកាលព្រះ បាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៨) ដែលព្រះមហាក្សត្រលោកបានតាំងរាជធានីនៅអង្គរវិញ។ ចំពោះប្រសាទដែលស្ថិតនៅក្នុងរចនាបថនេះរួមមានប្រាសាទមេបុណ្យខាងកើត ប្រាសាទប្រែ រូបនិងប្រាសាទបន្ទាយស្រី(គ.ស.៩៦៧) ដែលប្រាសាទនេះបានកសាងឡើងដោយព្រាហ្មណ៍ ម្នាក់ព្រះនាមយជ្ញវរាហៈ ពោលគឺជាប្រាសាទបុរាណដែលមានក្បូរក្បាច់រចនាល្អល្អះ និងមានសោភ័ណក្រៃលែងមកដល់បច្ចុប្បន្ននេះ។ បើយើងសង្កេតមកមើលរូបបដិមាវិញគឺមានរាងតូចៗ ទឹកមុខសុភាពរាបសា មានបបូរមាត់ក្រាស់ហើយខ្លី មានរបៀបតុបតែងសក់ថ្មីនិងពុំមានពាក់មុ្កដឡើយ។ បដិមាទាំងអស់នេះមានស្លៀកពាក់សំពត់ជីបជាផ្នត់ផង សំពត់លាតរលីងផងដែរ។

**១០. រចនាបថឃ្លាំង (ចុងស.វ.ទី១០និងពាក់កណ្ដាលទី១នៃគ.ស.វ.ទី១១)** ស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៦៨-១០០១) និងព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) ដែលសម័យនោះគឺរាជធានីនៅអង្គរវត្ត។ ប្រាសាទមួយចំនួនដែលត្រូវបានរាប់បញ្ចូល ក្នុងរចនាបថនេះរួមមានប្រាសាទឃ្លាំងខាងជើង ប្រាសាទវិមានអាកាស។ ដោយឡែកបើសង្កេតចំពោះរូបចម្លាក់វិញមានទឹកមុខសុភាពដូចសម័យបន្ទាយស្រីដែរ សម្លៀកបំពាក់ជីបជា ផ្នត់ជាជរាប និងមានសំពត់ខាងក្រោយសំពត់ឡើងរហូតដល់ខ្នង ឯមុខឆ្លាក់សំយេះមកក្រោម បញ្ចេញក្បាលពោះកណ្ដាលវាល។ ត្រង់នេះជាស្នាដៃរបស់ដូនតាខ្មែរយើងនាសម័យនោះ។

**១១. រចនាបថបាពួន (ពាក់កណ្ដាលទី២នៃគ.ស.វ.ទី១១)** ស្ថិតនៅក្នុងរជ្ជកាលព្រះបាទឧទយទិត្យវរ្ម័នទី២ (គ.ស.១០៥០-១០៦៦) និងព្រះបាទហ៍សវរ្ម័នទី៣ (គ.ស.១០៦៦-១០៨០) ដែលមានរាជធានីនៅអង្គរដែរ។ ប្រាសាទបុរាណទាំងនេះមានសោភណភាពល្អដែលរួមមានប្រាសាទបាពួន មេបុណ្យខាងលិច និងប្រាសាទវត្តខ្នារ។ ជាមួយគ្នានេះប្រាសាទភ្នំមានការរីកចម្រើនឡើងដែលក្នុងនោះប្រាសាទបាពួនមានថែវពីរជាន់ ប្រក់ថ្មភក់ព័ទ្ធជុំវិញ ព្រមទាំងមានប្រាង្គនៅគ្រប់ជ្រុងថែវនៃប្រាសាទ និងមានគោបុរៈនៅត្រង់ជណ្ដើរគ្រប់ទិសទាំងបួនប្រាសាទទៀតផងដែរ។ តាមការសង្កេតយើងច្បាស់ជាបានឃើញនូវជញ្ជាំងគោបុរៈនិងជញ្ជាំងជ្រុងជាន់ ទីពីរក្បាច់រឿងទាំងនោះ ចែកជាផ្ទាំងតូ

ចៗដាច់ចេញពីគ្នាមានរាងជាចតុកោណកែងស្មើ ហើយភាគច្រើនមានតំណាលពីព្រះវិស្ណុនិងរូបបដិមាវិញពុំខុសពីរចនាបថឃ្លាំងឡើយ។

**១២. រចនាបថអង្គរវត្ត (ពាក់កណ្ដាលទី១នៃគ.ស.វ.ទី១២)** នេះជារចនាបថដ៏ល្បីល្បាញពាសពេញសាកលលោក។ ព្រោះជាតិ-អន្តរជាតិបានស្គាល់ឈ្មោះប្រាសាទអង្គរវត្តនេះយ៉ាង ច្បាស់ជាទីបំផុត។ ពោលគឺស្ថិតនៅក្នុងរចនាបថព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៥០) មានរាជធានីនៅអង្គរ។ ជាការពិតណាស់មានប្រាសាទមួយចំនួនដែលត្រូវបានរាប់បញ្ចូលគឺ ប្រាសាទបឹងមាលា ប្រាសាទព្រះបាលិលេយ្យ ប្រាសាទកំពូល ប្រាសាទបាគង។ល។ ពោលគឺជាសម័យកាលមួយនៃការរីកចម្រើនដល់កំពូលនៃប្រវត្តិស្ថាបត្យកម្មខ្មែរ។ នៅលើជញ្ជាំងថែវ ទី១ មានក្បាច់រឿងដែលចែកចេញជា ៨ផ្ទាំងធំៗ ហើយវែងៗ ដែលក្បាច់ទាំងនោះមានចម្លាក់រឿងដោយឡែកៗពីគ្នាដែលបង្ហាញពីចម្បាំង ពីព្យុហយាត្រាកងទ័ព អធិប្បាយពីស្ថានសួគ៌ និងស្ថាននរក ចែងពីការកូរសមុទ្រទឹកដោះ ពណ៌នាពីចម្បាំងរវាងពួកទេវតានិងអសុរៈ ចម្បាំងរវាងក្រឹស្ណៈនិងសុរពាណៈ ចម្បាំងរវាងពួកទេវតានិងអសុរៈក្នុងព្រាហ្មសាសនា និងចម្បាំងរវាង ព្រះរាម និងក្រុងរាពណ៍ក្នុងរឿងរាមកេរ្តិ៍។

**១៣. រចនាបថបាយ័ន (ពាក់កណ្ដាលទី១នៃគ.ស.វ.ទី១២ និងដើមគ.ស.វ.ទី១៣)** ស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨១-១២១៨) ដែលមានរាជធានីនៅអង្គរ។ ប្រាសាទទាំងឡាយរួមមាន ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយស្រី ប្រាសាទព្រះខាន់ ប្រាសាទនាគព័ន្ធ។ ស្ថាបត្យកម្មនៅសម័យបាយ័នមានលក្ខណៈចុះអន់ថយបន្តិច ពីព្រោះដោយការកសាងមានលក្ខណៈប្រញាប់ប្រញាល់ពេក ហើយថ្មពុំសូវមានគុណភាព។ មានតែ ប្រាសាទបាយ័នមួយប៉ុណ្ណោះដែលមានប្លង់បែបប្រាសាទភ្នំ។ ស្ថិតនៅក្នុងសម័យកាលនេះប្រាសាទភាគច្រើនសង់ជាប់រាបស្មើនឹងដីបែបជាវត្តអារាមស្របទៅតាមទស្សនៈនៃព្រះពុទ្ធសាសនា។ ពោលគឺលក្ខណៈពិសេសប្រកបទៅដោយប្រជាប្រិយភាព ទឹកមុខស្រស់ស្រាយ មានខ្លោងទ្វារចូលធំៗ មាននាគអបសងខាងផ្លូវដែលឆ្លងចូលទៅក្នុងប្រាសាទ ក្បាលនាគបែរចេញមកក្រៅវិញ នាគម្ខាងមានពួកទេវតាជាអ្នកចាប់ទាញ នាគម្ខាងទៀតមានពួកអសុរៈជាអ្នកចាប់ទាញដែលជានិមិត្តរូបនៃការកូរសមុទ្រទឹកដោះ។

ប្រាសាទបាយ័ន និងប្រាសាទបន្ទាយឆ្មារ មានឆ្លាក់ក្បាច់រឿងដែលទាក់ទងទៅនឹងវីរបុរសជាតិប្រវត្តិសាស្ត្រព្រះមហាក្សត្រខ្មែរគឺព្រះបាទជ័យវរ្ម័នទី៧ ដែលស្ដីពីចម្បាំងខ្មែរ-ចាម ក៏ដូចជាបដិសណ្ឋារកិច្ចចំពោះគណៈប្រតិភូបរទេសជាដើម។ ក្រៅពីនេះមានកីឡា ការប្រដល់មាន់ សកម្មភាពស្ដីពីជីវភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរនាសម័យបុរាណកាល។

### ២.៣. បំណកស្រាយពិសេស

### រចនាបថស្ថាបត្យកម្មខ្មែរសម័យអង្គរ

អាណាចក្រ ខ្មែរឬសម័យអង្គរ ជាសម័យកាលដែលបានកសាងខឿនប្រវត្តិសាស្ត្ររបស់ជាតិសាសន៍របស់ខ្លួនឱ្យបានរីកចម្រើនដល់កំពូល។ ជាពិសេសវាបានផ្សព្វផ្សាយអំណាច និងឥទ្ធិពលរបស់ខ្លួនពាសពេញអាស៊ីអាគ្នេយ៍ថាជាតិសាសន៍មួយខ្លាំងរឹងប៉ឹង និងមានសិល្បករចំណានៗ ដែលបានកសាងប្រវត្តិសិល្បៈរបស់ខ្លួនឱ្យលេចធ្លោនៅក្នុងពិភពលោក។

កេរតំណែលដ៏អស្ចារ្យនេះ គឺប្រាង្គប្រាសាទរាប់សិបពាន់រមនីយដ្ឋានប្រកបទៅដោយសោភណ្ឌភាព និងវិចិត្រកម្មដ៏សំបូរបែបជាផ្ទាំងទស្សនីយភាពមួយមិនអាចកាត់ថ្លៃបាន។ ព្រោះវាបានផ្សព្វផ្សាយ

ល្បាញល្បីពាសពេញសាកលទ្វីប។ ខ្មែរមានប្រព័ន្ធជំនឿមួយដែលជា ការស្លបញ្ចូលគ្នារវាងពុទ្ធរាជ និង ទេវរាជ។ ពោលគឺទាំងព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា ដែលបានចាក់គ្រឹះយ៉ាងមាំដល់ឫសកែវនៃ ឃ្លាំងអត្តសញ្ញាណជាតិ។ ម្ល៉ោះហើយទើបក្នុងជីវិត នៃមនុស្សខ្មែរមិនអាចកាត់ផ្ដាច់ពីសំណុំនៃប្រព័ន្ធ ជំនឿនេះបានឡើយតាំងពីដើមរហូតមកដល់សម័យកាលបច្ចុប្បន្ននេះ។ អរិយធម៌ខ្មែរតាមប្រវត្តិសាស្ត្រ ត្រូវបានយកចេញមកពីះ

១. កំណាយបុរាណវត្ថុ ការសាងសង់ឡើងវិញ និងអង្កេតកម្ម

២. សិលាចារឹកដែលជាឯកសារស្តីពីការកសាងប្រាសាទ តង្វាយ និងរាជពិធីនានា

៣. ក្បាច់ក្រឡោតជាច្រើនដែលនៅបន្តគ្នាលើជញ្ជាំងប្រាសាទ

៤. របាយការណ៍ និងកាលប្បវត្តិនៃអង្គទូតក៏ដូចជាពាណិជ្ជករ និងអ្នកដំណើរចិន

អរិយធម៌ខ្មែរសម័យអង្គរ ជាសម័យកាលមួយដ៏រុងរោចន៍ជាទីបំផុត។ អរិយធម៌ខ្មែរ បានឡើង ដល់កម្រិតកំពូលនៅសតវត្សរ៍ទី៩ ដល់ទី១៣។ ភាពរុងរឿងនេះគឺបានលាតសន្ធឹងយ៉ាងល្បីល្បាញ ពាសពេញអាស៊ីអាគ្នេយ៍ បន្សល់ទុកនូវប្រាង្គប្រាសាទរាប់ពាន់ ផ្ទៃដីលាតសន្ធឹងយ៉ាងធំល្វឹងល្វើយ ដែលមានតឹកតាងគឺសិលាចារឹកដែលបានបង្ហាញពីប្រវត្តិ និងការកសាងប្រាសាទរបស់ព្រះរាជាខ្មែរ។ សាសនាសម័យកាលនោះគឺគោរពព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាដែលជាសាសនាមួយជាឫស កែវនៃអត្តសញ្ញាណជាតិ។

### ២.៤. បញ្ហានៃអត្តសញ្ញាណ

ដោយសម័យកាលជឿនលឿនគឺជាសម័យវិទ្យាសាស្ត្ររុងរឿងខ្លាំងពេក និងក៏អាចបង្កឱ្យមាន ជាបញ្ហាខ្លះៗក្នុងវិស័យស្ថាបត្យកម្មខ្មែរ ក្នុងនោះរចនាបថក៏កម្លាយក៏ដូចជាការកម្លាយអត្តសញ្ញាណ ជាតិមួយដែរ តែយើងម្នាក់ៗត្រូវមានគំនិតនិងស្មារតីមនសិការជាតិនិយមហើយក៏មិនអាចចោលទាំង ស្រុងនូវរចនាបថរបស់ប្រទេសនានា ដែលជឿនលឿននៅលើសាកលលោកបានដែរ។ អត្តសញ្ញាណ ជាតិនេះហើយបានស្តែងឱ្យឃើញពីគ្រឿងសម្គាល់របស់ជាតិ ជាលក្ខណៈពិសេសសម្រាប់សម្គាល់នូវអ្វី ដែលខ្មែរមាន និងជាព្រលឹងដួងជាតិរបស់ខ្មែរគ្រប់ប្រាណឱ្យបានស្គាល់ ឱ្យបានដឹង ឱ្យបានយល់ពីអ្វី ដែលហៅថាស្ថាបត្យកម្មខ្មែរ។

នេះសបញ្ជាក់ឱ្យឃើញថា ការចម្លងគ្នាទៅវិញទៅមកដូចបានរៀបរាប់ខាងលើខ្លះមិនថា ឡើយរចនាបថស្ថាបត្យកម្ម សូម្បីតែភាសា សម្លៀកបំពាក់ សម្ភារៈប្រើប្រាស់ផ្សេងៗព្រមទាំងកាយវិការ ឥរិយាបថរបស់មនុស្ស ក៏វិវត្តទៅរកការកម្លាយពីគ្នាទៅវិញទៅមកដែលបច្ចុប្បន្នប្រទេសយើង ហើយក៏ មានប្រទេសនានាឈានទៅធ្វើសាកលភាវូបនីយកម្ម។

## ៣. សន្និដ្ឋាន

រចនាបថស្ថាបត្យកម្មខ្មែរដែលកើតឡើងដោយគំនិតបញ្ញាស្មារតីរបស់ថ្នាក់ដឹកនាំប្រទេស ជា ពិសេសព្រះមហាក្សត្រក៏អាចមានទំនាក់ទំនងជាមួយនឹងពិធីទេវរាជ ព្រោះព្រះរាជា ក៏អាចមានឋានៈ ស្មើនឹងអាទិទេព។ រាជធានីរបស់ខ្មែរតាងដោយព្រះអង្គជាព្រះមហាក្សត្រជាតំណាងនៃចក្រវាលទាំង មូល ប្រាសាទនានាដែលបានកសាងឡើងតាំងពីសតវត្សរ៍ទី១ រហូតមកដល់ដើមសតវត្សរ៍ទី១៣ ឃើញថារចនាបថទាំងនោះ ស្ថាបត្យកម្មទាំងនោះ ប្រាសាទទាំង នោះមានភាពខុសគ្នាខ្លះៗដូចគ្នាខ្លះៗ

ទៅតាមបែបផែនសម័យកាលភូមិសាស្ត្រ របបគ្រប់គ្រង និងការយល់ដឹងរបស់អង្គមហាក្សត្រ។ លោក ជីវតាក្វាន់ដែលបានមកទស្សនាស្រុកខ្មែរនៅចុងសតវត្សរ៍ទី១៣ បានធ្វើការព័ណ៌នាពីការយាងចេញរបស់ព្រះរាជាដែលគួរឱ្យយើងចាប់អារម្មណ៍យ៉ាងខ្លាំង។ នេះគឺបញ្ជាក់ថា ការយាងចាកចេញរបស់ព្រះអង្គ គឺជាការយាងចេញពីបល្ល័ង្កដើម្បីចុះធ្វើសឹកសង្គ្រាមបំណងចង់រក្សាកេរដំណែលប្រាង្គប្រាសាទនានារបស់ខ្មែរ រក្សា បូរណភាពទឹកដី រក្សាសេចក្តីសុខសន្តិភាពរបស់ប្រជាពលរដ្ឋ តែក្រោយមកតាំងពីពេលនោះ មកទល់បច្ចុប្បន្នគេតែងសង្កេតឃើញរចនាបថស្ថាបត្យកម្មខ្មែរចេះតែកម្លាយបន្តិចម្តងៗមិនថាឡើយវិមាន ភូមិគ្រឹះ អគារធំៗ វត្តអារាម ព្រះវិហារ កុដិព្រះសង្ឃ រួមទាំងសមិទ្ធផលជាតិនិង ឯកជន ក៏នឹងមានកម្លាយជាបន្តបន្ទាប់ក្នុងរចនាបថស្ថាបត្យកម្មខ្មែរ។ ដោយហេតុនេះទើបការសិក្សារបស់និស្សិតផ្នែកស្ថាបត្យកម្ម រួមទាំងវិស្វករខ្មែរត្រូវតែសិក្សារៀនសូត្រ និងស៊ីជម្រៅឱ្យខាងតែបាននូវវប្បធម៌របស់ជាតិខ្លួនទើបសមនូវតម្លៃដូចម្តេចដែលហៅថា ម្ចាស់ប្រទេស ម្ចាស់ទឹកដី ម្ចាស់ស្ថាបត្យកម្ម និងសំណង់ផ្សេងៗ។

**ឯកសារពិគ្រោះ**


១. អាដេម៉ា ឡឺក្លែរ *"ប្រវត្តិសាស្ត្រប្រទេសកម្ពុជា"* ប៉ារីស ឆ្នាំ១៩១៤
២. ចាប ពិន *"ប្រវត្តិបទនគររាជភ្លេងជាតិខ្មែរ"* បោះពុម្ពឆ្នាំ១៩៥៩
៣. វ៉ា សុវណ្ណារ័ត្ន *"ស្ថាបត្យកម្មពិភពលោក"* ឆ្នាំ២០០៧
៤. ពេជ្រ ទុំក្រវិល *"តន្ត្រី របាំ និងល្ខោនខ្មែរ"* ឆ្នាំ២០១០
៥. ទៀ វិចិត្រ *"ចម្លាក់រឿងជាតកនៅប្រាសាទបុរាណខ្មែរ គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត"* ឆ្នាំ២០១១
៦. ឃីង ហុកឌី *"ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ"* បណ្ណាគារអង្គរ ឆ្នាំ២០០៣
៧. ជី រដ្ឋា *"ប្រវត្តិសាស្ត្រ-ប្រវត្តិសិល្បៈខ្មែរ"* ឆ្នាំ២០១០
៨. ត្រឹង ងា *"ប្រវត្តិសាស្ត្រខ្មែរ"* ភាគ១ ២ ឆ្នាំ១៩៧៣
៩. ពៅ សាវរស *"សទ្ទានុក្រម សំស្ក្រឹត ខ្មែរ បារាំង"* បណ្ណាគារអង្គរ ឆ្នាំ២០១៣
១០. ម. ត្រាណេ និងអ៊ួង វន *"ប្រាសាទបាពួន"* ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ១៩៩០
១១. ម. ត្រាណេ *"វប្បធម៌ អរិយធម៌ មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ"* ភាគ២ ឆ្នាំ២០១៤
១២. យិន គឹមវាណ *"ប្រភពវប្បធម៌ អរិយធម៌ ចរិតខ្មែរ"* ឆ្នាំ២០១០
១៣. លាង ហាប់អាន *"សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ សម័យនគរភ្នំដល់សម័យឧដុង្គ"* ឆ្នាំ១៩៦៧
១៤. សរ សារុន *"វប្បធម៌ និងអរិយធម៌ខ្មែរ"* ឆ្នាំ១៩៧០
១៥. ហួត រេចស្ទួ *"អត្ថាធិប្បាយ វប្បធម៌ អរិយធម៌ទូទៅ"* ឆ្នាំ១៩៧៤



ដោយសាស្ត្រាចារ្យបណ្ឌិត **ខៀវ កុសល**
និងកុំព្យូទ័រការី លោក **មី សុវណ្ណា** និងលោក **ឈឿន ម៉ុននា**


***សូមអរគុណ !***